ISSN 1560 9812

# ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា

## ការប្រឈម ការគំរាមកំហែង និងឱកាសល្អសំរាប់ជំរើក

ឯកសារពិភាក្សាលេខ ២៨

ព្រុំ តុលា និង Bruce McKenney

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឯកសារ
ពិភាក្សា
លេខ ២៨

# ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា

## ការប្រឈម ការគំរាមកំហែង និងឱកាសល្អសំរាប់ជ័រទឹក

ឯកសារពិភាក្សាលេខ ២៨

ព្រុំ តុលា និង **Bruce McKenney**

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ខែធ្នូ ឆ្នាំ២០០៣

Trading Forest Products in Cambodia: Challenges, Threats, and Opportunities for Resin — Working Paper 28

December 2003

*Prom Tola and Bruce McKenney*

© រក្សាសិទ្ធិឆ្នាំ២០០៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជាឡើយ ។

**ISSN 1560 9812**

**ពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមកំហែង និងឱកាសល្អ សំរាប់ជ័រទឹក ~ ឯកសារពិភាក្សាលេខ ២៨**

ខែធ្នូ ឆ្នាំ២០០៣

ព្រុំ តុលា និង Bruce McKenney

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជាទេ ។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@camnet.com.kh **website:** http://www.cdri.org.kh

បកប្រែដោយ: អែម សូវ៉ានី
កែសម្រួល និងរចនាដោយ: យូ សិទ្ធីរិទ្ធ និងអ៊ុំ ចាន់ថា
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន ផ្ទះលេខ៧៤ ផ្លូវលេខ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា


សេចក្តីសង្ខេប .......... i

បញ្ជីអក្សរកាត់ .......... v

សេចក្តីថ្លែងអំណរគុណ .......... vii

**ជំពូកទី ១. សេចក្តីផ្តើម** .......... ១

១.១. កម្មវត្ថុនៃការស្រាវជ្រាវ .......... ៣

១.២. វិធីសាស្ត្រ .......... ៣

**ជំពូកទី ២. ការដងជ័រ ការកាន់កាប់ដើមឈើ និងផលិតផល** .......... ៧

២.១. ទិន្នផល និងវិធីដងជ័រទឹក .......... ៧

២.២. ការកាន់កាប់ដើមឈើផ្តល់ជ័រទឹកតាមទំលាប់ និងបទប្បញ្ញត្តិច្បាប់ជាប់ទាក់ទិន .......... ៨

២.៣. ផលិតផលជ័រទឹកចំបងៗ .......... ១០

**ជំពូកទី ៣. ការកាប់ឈើគំរាមកំហែងដល់ដើមឈើផ្តល់ជ័រទឹក** .......... ១៥

**ជំពូកទី ៤. ផលិតកម្មជ័រទឹក និងការរកទីផ្សារ** .......... ១៩

**ជំពូកទី ៥. បទប្បញ្ញត្តិពាណិជ្ជកម្មជ័រទឹក និងការអនុវត្តន៍ជាក់ស្តែង** .......... ២៣

៥.១. ការតំរូវផ្សេងៗក្នុងបទបញ្ញត្តិជាផ្លូវការ .......... ២៣

៥.២. ដំណើរការជាក់ស្តែងនៃប្រព័ន្ធ .......... ២៥

**ជំពូកទី ៦. ការវិភាគពីបន្ទុកចំណាយ និងប្រាក់កំរៃឈើពាណិជ្ជកម្មជ័រទឹក** .......... ២៧

៦.១. ចំណែករបស់អ្នកដងជ័រ នៅក្នុងតំលៃទីផ្សារនៃជ័រទឹក .......... ២៨

៦.២. បន្ទុកចំណាយលើពាណិជ្ជកម្ម .......... ២៩

៦.៣. ប្រាក់កំរៃ .......... ២៩

៦.៤. សង្ខេបពីប្រាក់កំរៃៈ ពាណិជ្ជកម្មជ័រទឹកចេញពីព្រះវិហារ និងមណ្ឌលគីរី .......... ២៩

៦.៥. ផលប៉ះពាល់ទៅលើប្រសិទ្ធភាពពាណិជ្ជកម្ម .......... ៣២

៦.៦. ផលប៉ះពាល់ចំពោះការគោរពតាមបទប្បញ្ញត្តិផ្លូវការនាពេលអនាគត .......... ៣២

**ជំពូកទី ៧. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ...... ៣៥
៧.១. ផលប៉ះពាល់ចំពោះគោលដៅសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ...... ៣៥
៧.២. ផលប៉ះពាល់ចំពោះគោលដៅពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ ...... ៣៦
៧.៣. ផលប៉ះពាល់ចំពោះគោលដៅគ្រប់គ្រងព្រៃឈើ ...... ៣៧
៧.៤. អនុសាសន៍ ...... ៣៨

**ឯកសារយោង** ...... ៤១
**ឧបសម្ព័ន្ធ ក:** ផែនទីពាណិជ្ជកម្មជ័រទឹកដែលបានសិក្សា ...... ៤៥
**ឧបសម្ព័ន្ធ ខ:** មាត្រា ២៥ និង ២៦ នៃច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ...... ៤៧
**ឧបសម្ព័ន្ធ គ:** សារាចរស្តីពី ការកំណត់ថ្លៃផល - អនុផលព្រៃឈើ ...... ៥១
**ឧបសម្ព័ន្ធ ឃ:** បញ្ជីសំណួរ ...... ៥៧

**បញ្ជីឯកសារពិភាក្សារបស់ ទបសអ** ...... ៦៩

# សេចក្តីសង្ខេប

នៅកម្ពុជា ព្រៃឈើជួយទ្រទ្រង់ជីវភាពនៅជនបទបានច្រើនមុខសំខាន់ៗ ។ ប្រជាជននៅតាមជនបទស្ទើរតែគ្រប់គ្នា បានប្រើប្រាស់ធនធានព្រៃឈើ ដើម្បីធ្វើសំភារៈសំណង់ និងធ្វើអុសដុត ។ ប្រជាជនជាច្រើនបានប្រមូលផលិតផលផ្សេងទៀត សំរាប់ប្រើប្រាស់ក្នុងគ្រួសារ និងបង្កើនប្រាក់ចំនូលតាមរយៈការធ្វើពាណិជ្ជកម្ម ដូចជា ឫស្សី ផ្តៅ ជ័រទឹក បន្លែនិងផ្លែឈើព្រៃផ្សេងៗ និងរុក្ខជាតិធ្វើឱសថបុរាណ ។ ក្រៅពីផលិតផល ព្រៃឈើក៏ផ្តល់ជំរកដល់ពពួកសត្វ និងរុក្ខជាតិដ៏សំបូរបែប និងសេវាកម្មដ៏ចាំបាច់ខាងអេកូឡូស៊ី ហើយក្នុងតំបន់ខ្លះ ព្រៃឈើមានសារៈសំខាន់ច្រើនណាស់ខាងជំនឿ និងវប្បធម៌ សំរាប់សហគមន៍ដែលនៅជុំវិញ ។

ការប៉ាន់ស្មានថ្មីៗបង្ហាញថា ប្រហែល ១ភាគ៤នៃប្រជាជនកម្ពុជារស់នៅក្នុង ឬនៅជិតតំបន់ព្រៃឈើ ហើយប្រជាជនជនបទជាច្រើនសែននាក់ រស់នៅដោយពឹងផ្អែកយ៉ាងហោចណាស់ក៏មួយចំណែកដែរ ទៅលើចំណូលបានពីការប្រមូលផលិតផលព្រៃឈើ (កម្មវិធីស្បៀងអាហារពិភពលោក ២០០១) ។ ការប៉ាន់ស្មានទាំងនេះ រួមទាំងករណីសិក្សាជាច្រើនទៀតដែលពិនិត្យពីតួនាទីធនធានព្រៃឈើនៅក្នុងជីវភាពជនបទបានបង្ហាញថា ពាណិជ្ជកម្មនិងការប្រមូលផលិតផលព្រៃឈើ ដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ចនៅជនបទកម្ពុជា ។ ដោយក្នុងវិស័យព្រៃឈើគេផ្តោតការយកចិត្តទុកដាក់ភាគច្រើនទៅលើប្រតិបត្តិការកាប់ឈើពាណិជ្ជកម្ម ដូច្នេះសកម្មភាពសេដ្ឋកិច្ចខាងលើនេះជារឿយៗត្រូវបានមើលរំលង ។

ដើម្បីស្រាវជ្រាវពីលក្ខខណ្ឌធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា និងផលប៉ះពាល់របស់វាទៅលើជីវភាពជនបទ ការសិក្សានេះបានផ្តោតលើផលិតផលព្រៃឈើមួយមុខដែលស្ថិតក្នុងចំណោមផលិតផលព្រៃឈើដ៏សំខាន់ៗបំផុតនោះ គឺជ័រទឹក ។ ជ័រទឹកគេយកអំពីដើមឈើទាលជាសំខាន់ *(dipterocarpus alatus)* ប៉ុន្តែក៏អាចយកពីប្រភេទឈើផ្សេងទៀតមួយចំនួនដែរ ហើយគេប្រើនៅក្នុងស្រុកសំរាប់បិទស្នាមប្រេះក្តារទូក និងលាបទូកកុំឱ្យជ្រាបទឹក និងនាំចេញទៅប្រទេសក្រៅសំរាប់ការប្រើប្រាស់ដូចគ្នា និងសំរាប់ធ្វើថ្នាំពណ៌និងវ៉ែរនី ។ សកម្មភាពដងជ័រទឹក ឃើញមាននៅតាមតំបន់ព្រៃឈើភាគច្រើននៃកម្ពុជា (ក្នុង ១០ខេត្តយ៉ាងតិច) ហើយមានច្រើនបំផុតនៅតំបន់ខាងជើង និងឦសាននៃកម្ពុជា ។ ការកែលំអលក្ខខណ្ឌធ្វើពាណិជ្ជកម្មជ័រទឹកតាមបែបបទមួយដែលបង្កើនផលកំរៃដល់អ្នកដងជ័រ/ផលិតករ អាចផ្តល់ផលជាវិជ្ជមានដល់សហគមន៍ព្រៃឈើជាច្រើន ។

សំរាប់ការសិក្សានេះ បានធ្វើលើពាណិជ្ជកម្មជ័រទឹកចេញពី ៤តំបន់ដែលផលិតជ័រទឹកគឺ មណ្ឌលគិរី ព្រះវិហារ កំពង់ធំ និងឧត្តរមានជ័យ/សៀមរាប ក្នុងចន្លោះខែសីហា និងវិច្ឆិកា ២០០២ ។ ទិន្នន័យ និងពត៌មាន បានប្រមូលតាមរយៈជិត ៦០បទសំភាសន៍ពាក់កណ្តាលរៀបរយដោយធ្វើជាមួយ ពាណិជ្ជករជ័រទឹក អ្នកលក់ដុំ អ្នកដឹកជញ្ជូន អ្នកនាំចេញ អ្នកលក់រាយ/អ្នកបែងចែក និងមន្ត្រីមានសមត្ថកិច្ច, ការធ្វើដំណើរជាមួយការដឹកជញ្ជូនជ័រទឹកដើម្បីសង្កេតពិនិត្យ, និងការធ្វើអង្កេតយ៉ាងខ្លីលើតំណាងសហគមន៍មួយចំនួនមកពីតំបន់ផលិតជ័រទឹកក្នុង ៩ខេត្ត ។ គោលដៅសំខាន់ៗរួមមាន ការពិពណ៌នាពីការប្រើប្រាស់ និងវិធីយកជ័រទឹក, ការពិនិត្យពីការគំរាមកំហែងនៃសកម្មភាពកាប់ឈើដែលជះឥទ្ធិពលទៅលើការប្រមូលយកជ័រទឹក, ការវិភាគរចនាសម្ព័ន្ធទីផ្សារសំរាប់ផលិតកម្ម និងពាណិជ្ជកម្មជ័រទឹក, ការពិពណ៌នាពីក្របខ័ណ្ឌបទប្បញ្ញត្តិច្បាប់ និងការអនុវត្តន៍ជាក់ស្តែងក្នុងពេលសព្

ថ្ងៃ, ធ្វើការវាយតំលៃពីបញ្ហា ប្រឈមជាគន្លឹះនានាចំពោះពាណិជ្ជកម្មជ័រទឹក និងធ្វើការកំណត់ឡើងនូវអនុសាសន៍ទាក់ទងទៅនឹងជំរើសគោលនយោបាយមួយចំនួន ។

## ការជងជ័រ ការកាន់កាប់ ការគំរាមកំហែងពីការកាប់ឈើ

ដើម្បីប្រមូលជ័រទឹក គេត្រូវចោះរន្ធទេរចុះក្រោម (រន្ធច្បោះ) លើដើមឈើធំៗ, ដុតរន្ធនោះមួយរយៈខ្លីដើម្បីបង្កើនលំហូរជ័រទឹក នឹងប្រមូលដួសជ័រដាក់ក្នុងធុងប្លាស្ទិក (កានចំណុះ ៣០លីត្រ) នៅ ២-៣ថ្ងៃក្រោយពេលដុត ។ តាមវិធីនេះ ដើមឈើអាចបន្តផ្តល់ជ័របានជាច្រើនទសវត្សរ៍ បើតាមរបាយការណ៍ទទួលបាន ។ ការជងជ័រមិនធ្វើឱ្យខូចដើមឈើទេ ហើយហានិភ័យនៃភ្លើងឆេះព្រៃមានតិចតួចបំផុត ពីព្រោះគេដុតរន្ធដោយប្រុងប្រយ័ត្ន និងក្នុងពេលយ៉ាងខ្លី ។ តាមទំលាប់ ជនទី១ ដែលបានឃើញនិងដៅសញ្ញាសំគាល់លើដើមឈើផ្តល់ជ័រទឹកមុនគេ គឺក្លាយជាម្ចាស់លើដើមឈើផ្តល់ជ័រទឹកនោះ ។ ម្យ៉ាងទៀត ដោយសារតាមទំលាប់គេតែងចាត់ទុកដើមឈើផ្តល់ជ័រទឹកជាសម្បត្តិឯកជន ដូច្នេះគេអាចផ្ទេរកម្មសិទ្ធិដើមឈើ តាមរយៈការលក់ ការបន្តមរតក ការធ្វើអំណោយ, ឬក៏លក់សិទ្ធិជងជ័រក្នុងរយៈពេលកំណត់មួយ ។ ប្រព័ន្ធកាន់កាប់បែបនេះ ដូចឃើញមានតែចំពោះដើមឈើផ្តល់ជ័រទឹកទេ ឯដើមឈើនិងអនុផលព្រៃឈើផ្សេងៗទៀត គឺគ្មាន "ម្ចាស់" ទេ ហើយលទ្ធភាពប្រើប្រាស់ធនធានទាំងនេះ គឺបើកទូលាយសំរាប់ទាំងអស់គ្នា ។

"កម្មសិទ្ធិ" ដើមឈើផ្តល់ជ័រទឹក ខ្វះមូលដ្ឋានច្បាប់ជាផ្លូវការក៏ពិតមែន, តែច្បាប់កម្ពុជាបានផ្តល់សិទ្ធិប្រើប្រាស់ដល់អ្នកជងជ័រ និងបានហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹក (មាត្រា ២៩ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២) ។ ប៉ុន្តែមានរបាយការណ៍ថា ការកាប់ដើមឈើផ្តល់ជ័រទឹកកើតមានជាបន្តបន្ទាប់ ទោះបីវាខុសច្បាប់ក្តី ។ អ្នកធ្វើអាជីវកម្មឈើ គេប្រមូលកាប់ដើមឈើផ្តល់ជ័រទឹក ដោយសារវាមានលក្ខណៈទាក់ទាញខាងពាណិជ្ជកម្ម ។ ជាក់ស្តែង សៀវភៅកំណត់ត្រាឈើលើសម្បទានិកព្រៃឈើ ៦ ក្រុមហ៊ុន បង្ហាញថា ប្រភេទឈើផ្តល់ជ័រទឹក មានសមាមាត្រធំគួរកត់សំគាល់នៅក្នុងបរិមាណឈើដែលកាប់យកនៅឆ្នាំ២០០១ ។ ប៉ុន្តែគួរឱ្យស្តាយ នៅតាមតំបន់ព្រៃឈើមួយចំនួន គេមានលទ្ធភាពតិចតួចណាស់ក្នុងការរកបានដំណោះស្រាយ "ឈ្នះ-ឈ្នះ" ពោលគឺថែរក្សាចំណូលរកបានពីការជងជ័រទឹក និង បន្តការកាប់ឈើធ្វើពាណិជ្ជកម្ម ។ ត្រូវមានសេចក្តីសំរេចគ្រប់គ្រងព្រៃឈើច្បាស់លាស់មួយថា តើការកាប់ឈើធ្វើពាណិជ្ជកម្ម នឹងត្រូវអនុញ្ញាតក្នុងរូបភាពណាមួយនៅក្នុងតំបន់មានដើមឈើផ្តល់ជ័រទឹកឬយ៉ាងណា ។ បើគ្មានអន្តរាគមន៍យ៉ាងដូច្នេះទេ ដើមឈើផ្តល់ជ័រទឹកប្រហែលមានកាប់បន្តទៀត, ទំនាស់លើដើមឈើផ្តល់ជ័រទឹកនឹងកើនឡើង ហើយប្រជាជននៅជនបទកម្ពុជារាប់ពាន់នាក់ដែលពឹងផ្អែកលើការជងជ័រទឹក អាចបាត់បង់ប្រភពចំណូលដ៏សំខាន់បំផុតមួយ ហើយរឿងនេះវាផ្ទុយគ្នាស្រឡះទៅនឹងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ជាតិ ។

## ពាណិជ្ជកម្ម និងផលិតកម្មដើមឈើផ្តល់ជ័រទឹក

នៅទូទាំងប្រទេសកម្ពុជា គេបានប្រមូលជ័រទឹកប្រចាំឆ្នាំបានប្រហែល ២០.០០០តោន ហើយសកម្មភាពនេះគឺជាប្រភពចំណូលដ៏សំខាន់មួយសំរាប់ប្រជាជនរស់នៅ ក្នុង/ជិត តំបន់ព្រៃ ប្រមាណ ១០០.០០០នាក់ ។ អ្នកជងជ័រទឹកលក់ផលិតផលរបស់ខ្លួន ទៅឱ្យខ្សែរយៈរកទីផ្សារមួយដែលមានពាណិជ្ជករ អ្នកលក់ដុំ អ្នកដឹកជញ្ជូន អ្នកនាំចេញ និងអ្នកលក់រាយក្នុងស្រុក ។ ចេញពីព្រៃទៅ គេតែងដឹកជញ្ជូនជ័រទឹកក្នុងចម្ងាយផ្លូវឆ្ងាយៗ មកកាន់ទីផ្សារក្នុងស្រុកនៅជុំវិញបឹងទន្លេសាប មកភាគខាងត្បូងជាវាលទំនាបទន្លេមេគង្គ និងនាំចេញទៅវៀតណាម ថៃ និង ឡាវ (ដែលតាមដឹង បាននាំចេញបន្តទៅថៃ) ។ នៅកម្ពុជា ជ័រទឹកមានតំរូវការសំខាន់សំរាប់ជាង ២៥០.០០០គ្រួសារដែលយកទៅបិទទូកកុំឱ្យជ្រាបទឹក ជារៀងរាល់ឆ្នាំ ។ តំរូវការនាំចេញជ័រទឹកហាក់ដូចសំរាប់ប្រើការជាសំខាន់ក្នុងផ្នែកកម្មន្តសាលកម្មថ្នាំលាប និងវ៉ែរនី នៅវៀតណាម ប៉ុន្តែ វបសអ មិនអាចផ្តល់ការបញ្ជាក់ពីការប្រើប្រាស់ជ័រទឹកចំបងៗទាំងនេះបានទេ។ តំលៃផលិតកម្មជ័រទឹក នាំចេញ/ទីផ្សារ ប្រចាំឆ្នាំនៅកម្ពុជា គឺប្រហែល ៦លានដុល្លារ ។

## ក្របខ័ណ្ឌច្បាប់ និងការអនុវត្តន៍ជាក់ស្តែង

ប្រព័ន្ធបទប្បញ្ញត្តិបច្ចុប្បន្ន តំរូវឱ្យមាន លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងប្រាក់កំរៃសំរាប់ការស្តុក ការដឹកជញ្ជូន និងការនាំចេញជ័រទឹក ។ ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្តែង សឹងតែគ្មានអ្នកធ្វើសកម្មភាពក្នុងជំនួញនេះណាម្នាក់ដែលមានលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណត្រឹមត្រូវនោះទេ ។ ផ្ទុយទៅវិញ ជំនួញនេះបានប្រព្រឹត្តទៅតាមដំណើរការក្រៅផ្លូវការដែលមានការបង់កំរៃជាច្រើនទៅឱ្យស្ថាប័នផ្សេងៗ ដូចជា នាយកដ្ឋានរុក្ខាប្រមាញ់ ការិយាល័យរុក្ខាប្រមាញ់ខេត្ត ក្រសួងបរិស្ថាន ព្រមទាំងពួកមន្ត្រីស្រុក ប៉ូលីស ប៉ូលីសសេដ្ឋកិច្ច យោធា និង កងរាជអាវុធហត្ថ ។ របៀបអនុវត្តជាក់ស្តែងមួយដែលឃើញមានជាទូទៅ គឺការយកប្រាក់កំរៃនៅពេល "ពិនិត្យ" លិខិតដឹកជញ្ជូន ពីព្រោះគេដឹងថា អ្នកដឹកជញ្ជូន ឬមួយគ្មានលិខិតដឹកជញ្ជូន ឬមួយមានលិខិតដឹកជញ្ជូន តែមានចុះតួលេខប៉ាន់ស្មានទាប យ៉ាងច្រើនជាងបរិមាណដឹកជញ្ជូនជាក់ស្តែង ។

ការប្រតិបត្តិតាមប្រព័ន្ធបទប្បញ្ញត្តិផ្លូវការដែលគ្រប់គ្រងទីផ្សារជ័រទឹក គឺលំបាកបំផុត ជាពិសេសចំពោះពាណិជ្ជករតូចៗ ដែលខ្វះមធ្យោបាយបង់ប្រាក់កំរៃផ្លូវការ ធ្វើដំណើរទៅភ្នំពេញដើម្បីសុំលិខិតដឹកជញ្ជូន និង/ឬ អាជ្ញាប័ណ្ណនាំចេញ ។ ដូច្នេះ សឹងតែគ្រប់ការនាំចេញ និងពាណិជ្ជកម្មជ័រទឹក សុទ្ធតែត្រូវធ្វើឡើងលើមូលដ្ឋានមិនស្របច្បាប់ (ជាលក្ខណៈបច្ចេកទេស) ដូច្នេះហើយ ប្រព័ន្ធនេះសឹងតែគ្មានផ្តល់ចំណូលជាផ្លូវការអ្វីដល់រដ្ឋាភិបាលទេ ។

## ការវិភាគពីបន្ទុកចំណាយ និងប្រាក់កំរៃនៅក្នុងពាណិជ្ជកម្មជ័រទឹក

ឧបសគ្គសំខាន់ចំពោះពាណិជ្ជកម្មជ័រទឹកគឺ ចំណាយដឹកជញ្ជូន និងប្រាក់កំរៃក្រៅផ្លូវការច្រើនបែបយ៉ាង ។ ទោះបីចំនាយទាំងនេះ បានកើតមាននៅលើការរកទីផ្សារជ័រទឹក ជាជាងលើការដងជ័រទឹកក្តី ប៉ុន្តែវាមានផលប៉ះពាល់គួរកត់សំគាល់ទៅលើចំណូលរបស់អ្នកដងជ័រ ។ នៅពេលអ្នករកទីផ្សារជ័រទឹកមានបន្ទុកចំនាយច្រើន ពួកគេប្រហែលមិនអាចរ៉ាប់រងទាំងអស់ ហើយនៅតែមានចំនេញនោះទេ ។ ក្នុងករណីបែបនេះ ពួកគេត្រូវផ្ទេរបន្ទុកចំនាយដល់អ្នកដងជ័រដោយបញ្ចុះថ្លៃទិញជ័រ ដូចពាណិជ្ជករម្នាក់ថា "ពេលអាជ្ញាធរបង្កើនប្រាក់កំរៃ ខ្ញុំមិនអាចបង់វាទាំងអស់ហើយរកចំណេញបានទេ ដូច្នេះខ្ញុំត្រូវបញ្ចុះថ្លៃទិញជ័រពីអ្នកភូមិ" ។

រវាងផ្លូវពាណិជ្ជកម្មជ័រទឹកទាំងបួនដែលបានសិក្សា មានការប្រែប្រួលយ៉ាងច្រើនក្នុង របៀបរបបធ្វើពាណិជ្ជកម្ម កំរិតថ្លៃ ផលចំណេញ បន្ទុកចំណាយ និង ប្រាក់កំរៃ ។ ឧទាហរណ៍ នៅមណ្ឌលគិរី កំរិតថ្លៃជាមធ្យមដែលអ្នកដងជ័រទទួលបាន គឺស្មើនឹងបីដងនៃថ្លៃនៅកំពង់ធំ និងប្រហែលពីរដងនៃថ្លៃនៅខេត្តព្រះវិហារ និងឧត្តរមានជ័យ ។ ថ្លៃខុសគ្នាបែបនេះ អាចបណ្តាលពីកត្តាមួយចំនួន ដូចជា គុណភាពជ័រទឹក ចំងាយពីភូមិអ្នកដងជ័រទៅទីផ្សារចុងក្រោយ កំរិតប្រាក់កំរៃនៅតាមផ្លូវពាណិជ្ជកម្ម និងប្រភេទទីផ្សារចុងក្រោយ (ថ្លៃនាំចេញ ខ្ពស់ជាងថ្លៃនៅក្នុងស្រុក) ។

ថ្លៃទីផ្សារនៃជ័រទឹក មានពី ១៧២ដុល្លារ/តោន(ទីផ្សារក្នុងស្រុក) រហូតដល់៣២៥ដុល្លារ/តោន (ទីផ្សារនាំចេញ) ។ ការធ្វើពាណិជ្ជកម្មជ័រទឹកពីភូមិអ្នកប្រមូលជ័រ ទៅដល់ទីផ្សារចុងក្រោយទាំងនេះ អស់ចំនាយជាមធ្យម ៩៣ដុល្លារ/តោន ដែលមានចំណាយពាណិជ្ជកម្ម (៥៦ដុល្លារ/តោន) និងប្រាក់កំរៃ (៣៧ដុល្លារ/តោន)[១] ។ ដូច្នេះប្រាក់កំរៃអស់ច្រើនស្មើនឹង ៦៥% នៃចំណាយពាណិជ្ជកម្ម និងបានកាត់បន្ថយផលចំណេញជាខ្លាំង ។ បើគិតលើជ័រទឹកទាំង ២០.០០០តោនដែលផលិត និងធ្វើពាណិជ្ជកម្មប្រចាំឆ្នាំនៅកម្ពុជា ប្រាក់កំរៃសរុបលើជ័រទឹកមានប្រហែលពី ៥០០.០០០ដុល្លារ-១លានដុល្លារ/ឆ្នាំ ។

ប្រាក់កំរៃលើពាណិជ្ជកម្មជ័រទឹក ត្រូវបង់នៅតាមផ្លូវ និងតាមចំណុចធ្វើពាណិជ្ជកម្មនានា ។ កំរៃទាំងអស់ ត្រូវបង់ក្រៅផ្លូវការ ឬមួយបង់តាមមូលដ្ឋានផ្លូវការប៉ុន្តែមិនបង់ទៅតាមអត្រាកំណត់ជាផ្លូវការទេ ។ ការពិនិត្យលំអិតនៃការដឹកជញ្ជូនសំរាប់ផ្លូវ

---

[១] បន្ទុកចំណាយពាណិជ្ជកម្មសំដៅដល់គ្រប់ប្រតិបត្តិការទាំងអស់ ធន និងបន្ទុកចំណាយធនការងារទាក់ទិននឹងការផ្ទុក ការច្រោះ ការនាំចេញជ័រទឹកពីភូមិរបស់អ្នកដងជ័រ (ថ្លៃនៅក្នុងព្រៃ) ទៅទីផ្សារចុងក្រោយ ដកកំរៃនានាចេញ ។

ពាណិជ្ជកម្មចំនួនពីរ បានបង្ហាញពីការប្រែប្រួលក្នុង ទឹកប្រាក់កំរៃសរុប ចំនួនដងនៃការបង់ និង ប្រភេទស្ថាប័នប្រមូលប្រាក់កំរៃ ។ សំរាប់ការដឹកជញ្ជូនជ័រទឹក ២០តោន ពីព្រះវិហារទៅព្រំដែនវៀតណាម ប្រាក់កំរៃអស់សរុប ១.៣៤៤ដុល្លារ (ឬ ៦៧ដុល្លារ/តោន) ។ ក្នុងការធ្វើជំនួញនេះមានការបង់ប្រាក់ ៤៣ដង នៅ ១៤កន្លែងខុសគ្នា ។ មន្ត្រីរុក្ខាប្រមាញ់ប្រមូលយកកំរៃច្រើនជាងគេនៅតាមផ្លូវពាណិជ្ជកម្មនេះ គឺមានការបង់រហូតដល់ ២០ដង អស់ប្រហែល ៧៥%នៃប្រាក់កំរៃសរុប ។ ក្រៅពីនេះមានការបង់ ១៧ដងទៀតឱ្យដល់ ប៉ូលីស ប៉ូលីសសេដ្ឋកិច្ច កងរាជអាវុធហត្ថ និង កងទ័ព ។ ប្រាក់កំរៃមានតិចជាងនៅក្នុងពាណិជ្ជកម្មជ័រទឹកពីមណ្ឌលគិរី ទៅព្រំដែនវៀតណាម។ សំរាប់ការដឹកជ័រទឹក១,២តោន ប្រាក់កំរៃអស់ប្រហែល ៣០ដុល្លារ (ឬ២៥ដុល្លារ/តោន)។ ក្នុងពាណិជ្ជកម្មនេះ មានការបង់ប្រាក់តែ ១១ដងទេ នៅ ៣កន្លែងខុសគ្នា ។

បន្ថែមលើប្រាក់កំរៃបានបង់ជាក់ស្តែង ការគំរាមកំហែង នៃការប្រមូលប្រាក់កំរៃ នាំឱ្យមានការខាតបង់ខាងសេដ្ឋកិច្ចដោយសារអប្រសិទ្ធិភាពនៃពាណិជ្ជកម្ម ។ ពាណិជ្ជករជ័រទឹកតែងខិតខំខ្លាំងណាស់ដើម្បីជៀសវាងការបង់ប្រាក់កំរៃខ្ពស់ ពីព្រោះជារឿយៗវាធ្វើឱ្យជំនួញរបស់គេត្រូវខាតតែម្តង ។ ឧទាហរណ៍ ជាជាងដឹកជញ្ជូនជ័រទឹកយ៉ាងមានប្រសិទ្ធភាពតាមឡានធំៗ (ហើយបង់ប្រាក់កំរៃខ្ពស់) តាមធម្មតាគេច្រើនដឹកវាក្នុងបរិមាណតិចជាងក្នុងឃ្លុបឡានតាក់ស៊ីវិញ ដើម្បីគេចពីការបង់ប្រាក់បង់កំរៃ ។ ដូចគ្នានេះដែរ ពាណិជ្ជករចៀសវាងចំណុចព្រំដែនខ្លះដែលគេដឹងថាទារយកប្រាក់កំរៃខ្ពស់ ហើយសុខចិត្តធ្វើដំនើរតាមផ្លូវឆ្ងាយកាត់តាមចំនុចព្រំដែនផ្សេងទៀតវិញ ទោះត្រូវអស់សោហ៊ុយបន្ថែមទៅលើការដឹកជញ្ជូន និងប្រេងឥន្ធនៈក្តី ។ ប៉ុន្តែមិនគួរដាក់ពង្រឹងវិធានការដើម្បីទប់ស្កាត់ការគេចមិនបង់ប្រាក់កំរៃបែបនេះទេ ពីព្រោះវាធ្វើឱ្យពាណិជ្ជកម្មគ្មានចំនេញ ឬក៏ធ្វើឱ្យមុខជំនួញនេះដួលរលំទាំងស្រុងតែម្តង ។ ដូច្នេះមុននឹងប្រឹងប្រែងកែលំអការគោរពច្បាប់ ត្រូវធ្វើកំណែទំរង់លើប្រព័ន្ធនៃអត្រាប្រាក់កំរៃនេះសិន ។

## អនុសាសន៍

រដ្ឋាភិបាលបានបញ្ជាក់ក្នុង យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រជាតិឆ្នាំ២០០៣-២០០៥ ពីតំរូវការ ពិនិត្យឡើងវិញ និងកែលំអប្រព័ន្ធបទប្បញ្ញត្តិច្បាប់សំរាប់អនុផលព្រៃឈើ ដើម្បីជួយទ្រទ្រង់ឱ្យមានលក្ខខណ្ឌទីផ្សារកាន់តែល្អប្រសើរ ។ ការកែលំអទាំងនេះ គួរឱ្យបានស្របជាមួយគោលដៅរបស់ជាតិដើម្បី កាត់បន្ថយភាពក្រីក្រ, ធានាសន្តិសុខស្បៀង, បង្កើនពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ និងការអភិវឌ្ឍន៍ជនបទ, និង កែលំអការគ្រប់គ្រងព្រៃឈើ ។ ដើម្បីជួយទ្រទ្រង់ដល់ការកែលំអទាំងនេះ ការសិក្សាស្រាវជ្រាវបានធ្វើការកំណត់ឡើងនូវអនុសាសន៍ទាក់ទិននឹងជំរើសគោលនយោបាយមួយចំនួនដូចខាងក្រោម:

១. **កែលំអអភិបាលកិច្ច និងតម្លាភាពសំរាប់ការរកទីផ្សារជ័រទឹក រួមទាំងការសើរើពិនិត្យឡើងវិញទាំងស្រុង និងការធ្វើឱ្យសាមញ្ញ នូវប្រព័ន្ធបទប្បញ្ញត្តិបច្ចុប្បន្ន**
   - លុបបំបាត់លិខិតអនុញ្ញាតដឹកជញ្ជូន និងប្រាក់កំរៃនានាដែលជាប់ទាក់ទិន
   - លុបបំបាត់ការប្រមូលកំរៃនៅតាម ក្រុងត្រួល/ស្ថាប័ន នានាដែលគ្មានមូលដ្ឋានស្របច្បាប់ដើម្បីប្រមូលប្រាក់កំរៃ
   - លុបចោលពន្ធនាំចេញ និងធ្វើឱ្យសាមញ្ញនូវនីតិវិធីនានាសំរាប់សុំអាជ្ញាប័ណ្ណនាំចេញ

២. **កែលំអ និងផ្ទេរការគ្រប់គ្រងព្រៃឈើទៅឱ្យមូលដ្ឋាន តាមរយៈការធ្វើវិមជ្ឈការសិទ្ធិអំណាចត្រួតត្រាលើយន្តការរកប្រាក់ចំណូល**

៣. **ដាក់ពង្រឹងការអនុវត្តន៍មាត្រា២៩ នៃច្បាប់ស្តីពីព្រៃឈើ ដែលហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹក**

៤. **កំណត់ថា ជ័រទឹក/អនុផលព្រៃឈើ គឺជាវិស័យស្នូលមួយសំរាប់គំនិតផ្តួចផ្តើមធ្វើពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ និងការកែលំអលទ្ធភាពកែច្នៃដើម្បីបង្កើតតំលៃបន្ថែម**

៥. **ពិនិត្យ និងសើរើឡើងវិញ នូវក្របខ័ណ្ឌបទប្បញ្ញត្តិច្បាប់សំរាប់គ្រប់គ្រងអនុផលព្រៃឈើ ។**

# បញ្ជីអក្សរកាត់

| | |
|---|---|
| វបសអ/CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| DFW | នាយកដ្ឋានរុក្ខាប្រមាញ់ |
| *Dipterocarpus alatus* | ពូជឈើដែលផ្តល់ជ័រទឹកនៅក្នុងប្រទេសកម្ពុជា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NGO | អង្គការក្រៅរដ្ឋាភិបាល (Non Governmental Organisation) |
| NTFPs | អនុផលព្រៃឈើ (Non-Timber Forest Products) |
| PFO | ការិយាល័យរុក្ខាប្រមាញ់ខេត្ត (Provincial Forestry Office) |
| SADP | កម្មវិធីអភិវឌ្ឍន៍អាស៊ីអគ្នេយ៍ (Southeast Asia Development Programme) |
| *Shorea* | ពូជឈើដែលជាប្រភពផ្តល់ជ័រចុងនៅកម្ពុជា |
| WCS | អង្គការសមាគមអភិរក្សសត្វព្រៃ (Wildlife Conservation Society) |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក (World Food Programme) |

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បុគ្គលជាច្រើនដែលបានផ្តល់ពត៌មាន និងជួយគាំទ្រដល់ការសិក្សានេះ ។ ទី១ នៅពេលចាប់ផ្តើមធ្វើការស្រាវជ្រាវ អ្នកនិពន្ធបានសំភាសឈ្មួញលក់ដូរជ័រទឹក ៥៧នាក់ ដែលជាពាណិជ្ជករ អ្នកលក់ដុំ អ្នកដឹកជញ្ជូន អ្នកនាំចេញ អ្នកលក់រាយ/អ្នកចែកចាយ មន្ត្រីរដ្ឋាភិបាលពីនាយកដ្ឋានរុក្ខាប្រមាញ់ និងមន្ត្រីក្រសួងពាណិជ្ជកម្ម ។ បើសិនអ្នកទាំងនេះ គ្មានឆន្ទៈចូលរួមក្នុងបទសំភាសន៏ស៊ីជម្រៅ និងផ្តល់ពត៌មាននិងទិន្នន័យលំអិតអំពីអាជីវកម្ម និងសកម្មភាពរបស់ខ្លួន ព្រមទាំងបញ្ហាផ្សេងៗខាងច្បាប់ និងបទប្បញ្ញត្តិទេ នោះការសិក្សានេះក៏មិនអាចធ្វើទៅកើតដែរ ។ យើងខ្ញុំសង្ឃឹមថាការខិតខំប្រឹងប្រែងដ៏សប្បុរសទាំងនេះ អាចនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានផ្សេងៗខាងគោលនយោបាយ ដែលនឹងកែលំអដល់ជីវភាពរស់នៅជនបទនៅកម្ពុជា ។

ក្រុមអ្នកនិពន្ធក៏សូមអរគុណផងដែរ ដល់បុគ្គលិកអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដែលបានផ្តល់ការណែនាំ និងជំនួយដល់ការស្រាវជ្រាវនៅខេត្តមណ្ឌលគីរី និងព្រះវិហារ ព្រមទាំងសូមថ្លែងអំណរគុណជាពិសេសដល់លោកស្រី ហង់ មារី ដែលបានជួយក្នុងការចុះសិក្សាដល់ខេត្តមណ្ឌលគីរី ។ លោក យឹម ជា ជាសហសេវិក និងអ្នកស្រាវជ្រាវក្នុងកម្មវិធីធនធានធម្មជាតិ និងបរិស្ថាននៃ វបសអ គួរទទួលបាននូវការលើកបញ្ជាក់ជាពិសេសចំពោះការដឹកនាំចុះស្រាវជ្រាវដល់កន្លែង និងការចូលរួមវិភាគទានដ៏សំខាន់ក្នុងការវិភាគ និងការប្រមូលទិន្នន័យ ។

ក្រុមអ្នកនិពន្ធក៏សូមថ្លែងអំណរគុណដល់អង្គការ Danida ចំពោះជំនួយមូលនិធិដ៏សប្បុរសសំរាប់កម្មវិធីកម្មវិធីធនធានធម្មជាតិ និងបរិស្ថាននៃ វបសអ ។ ការសិក្សានឹងមិនអាចលេចចេញជាលទ្ធផលទេ ប្រសិនបើគ្មានជំនួយបែបនេះ ។

នៅទីបញ្ចប់ ការសិក្សានេះបានទទួលផលពីយោបល់ និងយល់កាន់តែស៊ីជម្រៅទៀតពីបុគ្គលិកអង្គការមួយចំនួនរួមទាំង WCS, NGO Forum និងកម្មវិធីអភិវឌ្ឍន៍អាស៊ីអគ្នេយ៍ (SADP) និងនាយកដ្ឋានរុក្ខាប្រមាញ់ ។ ក្រុមអ្នកនិពន្ធសូមអរគុណផងដែរដល់លោកបណ្ឌិត K.A.S. Murshid នាយកស្រាវជ្រាវរបស់ វបសអ និងលោកស្រី អេវ៉ា មីស្លីវិក នាយិកា វបសអ ចំពោះការជួយមតិ ការណែនាំ និងការគាំទ្រដ៏មានតំលៃ ។

ភ្នំពេញ ខែតុលា ឆ្នាំ២០០៣

ព្រុំ តុលា និង *Bruce McKenney*

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ជំពូកទី ១

# សេចក្តីផ្តើម

នៅកម្ពុជា ព្រៃឈើជួយទ្រទ្រង់ដល់ជីវភាពរស់នៅជនបទបានច្រើនមុខសំខាន់ៗ ។ ប្រជាជននៅតាមជនបទស្ទើរតែគ្រប់គ្នា បានប្រើប្រាស់ធនធានព្រៃឈើ ដើម្បីធ្វើសំភារៈសំណង់ និងធ្វើអុសដុត ។ ប្រជាជនជាច្រើនបានប្រមូលផលិតផលផ្សេងទៀតសំរាប់ប្រើប្រាស់ក្នុងគ្រួសារ និងបង្កើនប្រាក់ចំនូលតាមរយៈការធ្វើពាណិជ្ជកម្ម ដូចជា ឬស្សី ផ្តៅ ជ័រទឹក បន្លែនិងផ្លែឈើព្រៃផ្សេងៗ និងរុក្ខជាតិឱសថបុរាណ ។ ក្រៅពីផលិតផលសំរាប់ការប្រើប្រាស់ផ្ទាល់នានា ព្រៃឈើក៏ផ្តល់ជំរកដល់ពពួកសត្វ និងរុក្ខជាតិដ៏សំបូរបែប និងសេវាកម្មខាងអេកូឡូស៊ីក្នុងមូលដ្ឋាន និងជាសាកល ដូចជា ការទប់ស្កាត់ការហូរច្រោះដី និងការរក្សាទុកសារធាតុកាបូន ហើយសំរាប់តំបន់មួយចំនួន ព្រៃឈើមានសារៈសំខាន់ច្រើនណាស់ខាងផ្លូវជំនឿ និងវប្បធម៌ សំរាប់សហគមន៍ដែលនៅជុំវិញ ។

មានប្រជាជនកម្ពុជាយ៉ាងច្រើនរស់នៅក្នុង ឬនៅជិតតំបន់ព្រៃឈើ ។ កម្មវិធីស្បៀងអាហារពិភពលោក (២០០១) បានប៉ាន់ស្មានថា មានប្រជាជនកម្ពុជាប្រមាណ ៦០០.០០០នាក់រស់នៅក្នុងតំបន់ព្រៃសម្បទាន (ដែលច្រើនតែសំបូរធនធានព្រៃឈើ) ហើយប្រជាជនប្រហែល ៣លាននាក់ (ឬប្រហែល ២៥%នៃប្រជាជនសរុប) ឬមួយរស់នៅក្នុងតំបន់ព្រៃសម្បទាន ឬមួយរស់នៅក្នុងរង្វង់ ៣០គ.ម ពីព្រំដែនព្រៃសម្បទាន ។ ភាគច្រើននៃប្រជាជនជនបទទាំងនេះ ពឹងផ្អែកលើធនធានព្រៃឈើយ៉ាងហោចណាស់ក៏មួយផ្នែកណាមួយដែរ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ ។ ក្នុងចំណោម ៥៤០ឃុំ ដែលមានទិន្នន័យបញ្ជាក់ដោយកម្មវិធីស្បៀងអាហារពិភពលោក (២០០១) បានរកឃើញថា មាន ៣១០ឃុំ (២,៣លាននាក់) ដែលមានគ្រួសារច្រើនជាង ២០% បានចូលទៅក្នុងព្រៃដើម្បីរកប្រាក់ចំណូលពីព្រៃឈើ ។ នៅក្នុងចំណោមឃុំទាំងនេះ មាន ៥៥ឃុំ (៤០០.០០០នាក់) ដែលមានគ្រួសារច្រើនជាង ៥០% បានចូលទៅក្នុងព្រៃដើម្បីរកប្រាក់ចំណូលទាក់ទិននឹងព្រៃឈើ ។ ដើម្បីជាការបញ្ជាក់គាំទ្រដល់ការប៉ាន់ស្មានទាំងនេះ មានករណីសិក្សាជាច្រើនបានធ្វើឡើងនៅទូទាំងកម្ពុជា ដើម្បីបង្ហាញពីតួនាទីដ៏សំខាន់ជាអាយុជីវិតនៃព្រៃឈើចំពោះជីវភាពរស់នៅតាមជនបទ[២] ។

ទោះជាផលិតផលព្រៃឈើដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ចនៃជនបទកម្ពុជាក្តី ក៏ជារឿយៗវាត្រូវបានគេមើលរំលង ។ សព្វថ្ងៃនៅមានការមិនច្បាស់លាស់ច្រើនពី លក្ខខណ្ឌធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើនៅកម្ពុជា និងពីផលប៉ះពាល់របស់វាចំពោះជីវភាពនៅជនបទ ។ បញ្ហាសំខាន់ៗមួយចំនួនសំរាប់ការវិភាគ រួមមាន រចនាសម្ព័ន្ធទីផ្សារ, កំរៃនិងបន្ទុកចំណាយលើការរកទីផ្សារ, ការតំរូវផ្សេងៗក្នុងបទប្បញ្ញត្តិ និងការអនុវត្តន៍ជាក់ស្តែង, និងចីរភាពពាណិជ្ជកម្មយោងតាមរបៀបរបបគ្រប់គ្រងបច្ចុប្បន្ន ។ ដើម្បីស្រាវជ្រាវពីបញ្ហាទាំងនេះ ការសិក្សានេះផ្តោតលើផលិតផលព្រៃឈើមួយមុខដែលស្ថិតក្នុងចំណោមផលិតផល

---

[២] ករណីសិក្សាថ្មីៗរួមមាន: Chan and Charya (2003), Evans *et al.* (2003), McAndrew *et al.* (2003), Mlup Baitong (2003), Sy *et al.* (2002), So *et al.* (2001), Yoshida *et al.* (2001), មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគីរី *et al.* (2000), Phat *et al.* (1999), Chea *et al.* (1998) and Seilava *et al.* (2002) ។

ព្រៃឈើដ៏សំខាន់ៗបំផុត គឺផលិតផលជ័រទឹក[៣] ។ ជ័រទឹកដងពីឈើទាល (dipterocarpus alatus) នៃតំបន់ព្រៃស្រោង ប៉ុន្តែក៏អាចយកពីប្រភេទឈើផ្សេងទៀតមួយចំនួនដែរ ហើយអាចប្រមូលផលក្នុងទំរង់ជាជ័ររាវ និងជ័ររឹង ។ ជ័រទឹកគេប្រើនៅក្នុងស្រុកសំរាប់លាប ក្តារទូក និងបិទស្នាមប្រេះក្តារទូកកុំឱ្យជ្រាបទឹក និងនាំចេញទៅប្រទេសក្រៅសំរាប់ធ្វើថ្នាំពណ៌ និងវ៉ែរនី ។ សកម្មភាពដងជ័រទឹក ឃើញមាននៅតាមតំបន់ព្រៃឈើភាគច្រើននៃកម្ពុជា (ក្នុង ១០ខេត្តយ៉ាងតិច) ហើយមានច្រើនបំផុតគឺនៅតំបន់ខាងជើង និងឦសាននៃកម្ពុជា ។

ជ័រទឹក ជាឧទាហរណ៍មួយ ត្រូវបានជ្រើសរើសធ្វើជាករណីសិក្សាអំពីពាណិជ្ជកម្មផលិតផលព្រៃឈើ ដោយសារមូលហេតុច្រើនយ៉ាង ។ ទីមួយ ការសិក្សាកន្លងមក និងកំពុងធ្វើមួយចំនួន បានបញ្ជាក់ពីសារៈសំខាន់នៃជ័រទឹកក្នុងការបង្កើនប្រាក់ចំណូលសំរាប់សហគមន៍ព្រៃឈើ (Chan and Acharya 2003, Evans *et al.* 2003, McAndrew *et al.* 2003, Cock *et al.* forthcoming) ។ ការកែលំអលក្ខខ័ណ្ឌពាណិជ្ជកម្មតាមលក្ខណៈមួយដែលអំណោយផលដល់ការបង្កើនផលចំណេញដល់ផលិតករ/អ្នកដងជ័រ អាចផ្តល់ផលប្រយោជន៍គួរកត់សំគាល់ចំពោះជីវភាពជនបទនៅក្នុងសហគមន៍ព្រៃឈើកម្ពុជាជាច្រើន ។ ទីពីរ ជ័រទឹកមានធ្វើពាណិជ្ជកម្មយ៉ាងទូលំទូលាយនៅក្នុងស្រុក (ពីតំបន់ខ្ពង់រាបមានព្រៃឈើ ដល់តំបន់វាលទំនាបធ្វើនេសាទ) និងមាននាំចេញយ៉ាងច្រើន ដែលធ្វើឱ្យវាក្លាយជាករណីចាំបាច់មួយសំរាប់ធ្វើការសិក្សាពីពាណិជ្ជកម្ម និងរកទីផ្សារផលិតផលព្រៃឈើ ។ ទីបី ការដងជ័រទឹកមិនធ្វើឱ្យខូចខាតដើមឈើទេ ហើយដើមឈើដែលគេបានចោះយកជ័រ អាចបន្តផ្តល់ជ័រទឹកបានជាច្រើនទសវត្សរ៍ ។ ដូច្នេះគេស្វែងរកវិធីកែលំអពាណិជ្ជកម្ម និងការរកទីផ្សារជ័រទឹក ដោយគ្មានការគំរាមគំហែង ការកែលំអទាំងនេះអាចចោទបញ្ហាដល់ការគ្រប់គ្រងផលិតផលព្រៃឈើឱ្យមានចីរភាព ។ ទីបួន ដោយសារជ័រទឹកផលិតបាននៅតំបន់ជនបទ ហើយបច្ចុប្បន្នភាគច្រើនបាននាំចេញក្នុងទំរង់ដើមមិនទាន់កែច្នៃ ដូច្នេះវាអាចជាផលិតផលមួយសំខាន់គួរយកមកគិតគូរក្នុងការងារជំរុញ "ពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ" ។ តាមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម យុទ្ធសាស្ត្រពាណិជ្ជកម្មអំណោយផលដល់អ្នកក្រមានគោលដៅធ្វើឱ្យឱកាសល្អខាងពាណិជ្ជកម្ម និងការនាំចេញ ផ្តល់ផលទៅដល់អ្នកក្រ តាមការលើកទឹកចិត្តដល់សហគ្រិន និងការវិនិយោគទុននៅតាមតំបន់ជនបទ ការធ្វើវិមជ្ឈការមូលដ្ឋាននាំចេញឱ្យទៅកាន់តំបន់ថ្មីៗ ការបង្កើនតំលៃបន្ថែម និងការកែលំអយុទ្ធសាស្ត្ររកទីផ្សារ ។

នៅទីបញ្ចប់ ដើមឈើផ្តល់ជ័រទឹកនៅតែជាបញ្ហាសំខាន់សំរាប់ការពិភាក្សានានាស្តីពីការគ្រប់គ្រងព្រៃឈើនៅកម្ពុជា ។ ថ្វីបើអ្នកដងជ័រយល់ថា គេជា "ម្ចាស់" លើដើមឈើផ្តល់ជ័រទឹករបស់ខ្លួន យោងតាមរបៀបអនុវត្តន៏កម្មសិទ្ធជាទំលាប់របស់គេ ហើយច្បាប់ស្តីពីព្រៃឈើ (២០០២) បានហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹក និងបញ្ជាក់ពីសិទ្ធិប្រមូលជ័រទឹករបស់អ្នកប្រើប្រាស់, ប៉ុន្តែការកាប់ដើមឈើផ្តល់ជ័រទឹកនៅតែបន្ត ពីព្រោះឈើនេះមានលក្ខណៈទាក់ទាញខាងពាណិជ្ជកម្មចំពោះអ្នកកាប់ឈើ ។ ទិន្នន័យក្នុងបញ្ជីរបស់នាយកដ្ឋានរុក្ខាប្រមាញ់ អំពីការកាប់ឈើដោយសម្បទានិក ៦ក្រុមហ៊ុនបង្ហាញថា ក្នុងចំណោមឈើបានកាប់យកនៅឆ្នាំ២០០១ ប្រភេទឈើសំរាប់ដងជ័រទឹកមានសមាមាត្រធំគួរឱ្យកត់សំគាល់ (សូមអានជំពូកទី៣) ។ ដោយសារសារៈសំខាន់នៃដើមឈើផ្តល់ជ័រទឹកចំពោះការកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម ព្រៃសម្បទានមួយចំនួនប្រហែលមិនអាចដំណើរការបានយូរទេ (ឬលែងមានចំណេញដូចពីមុន) បើសិនបំរាមលើការកាប់ដើមឈើផ្តល់ជ័រទឹកត្រូវបានដាក់អនុវត្ត ។ ដូច្នេះគេអាចរំពឹងថា បើសិនផែនការគ្រប់គ្រងព្រៃសម្បទានថ្មីបានទទួលការអនុម័ត ការកាប់ដើមឈើផ្តល់ជ័រទឹកនឹងនៅតែមានជាបន្តក្នុងតំបន់មួយចំនួន ។ ទង្វើនេះអាចបង្កើនទំនាស់ និងធ្វើឱ្យបាត់បង់ប្រភពចំណូលដ៏សំខាន់សំរាប់ប្រជាជនជនបទរាប់ពាន់នាក់ដែលរស់នៅដោយពឹងផ្អែកលើការដងជ័រទឹក ។ គេសង្ឃឹមថា ការសិក្សានេះអាចជួយបង្កើនការយល់ដឹងពីតួនាទីនៃផលិតកម្ម និងពាណិជ្ជកម្មជ័រទឹកនៅក្នុងជីវភាពរស់នៅរបស់ប្រជាជនជនបទ ដែលអាចជួយរួមចំណែកដល់ការរកដំណោះស្រាយមួយច្បាស់លាស់ចំពោះបញ្ហានេះ ។

---

[៣] ថ្វីបើពាក្យជ័រទឹកមានគេស្គាល់ជាទូទៅនៅកម្ពុជាក្តី ប៉ុន្តែជាលក្ខណៈបច្ចេកទេសផលិតផលនេះគឺជាជ័រប្រេង (oleoresin) ពីព្រោះវាមានសារជាតិប្រេងក្រអូប (ងាយហួតហើរ) ម្យ៉ាង ។

ពាណិជ្ជកម្មផលិតផលព្រៃឈើមានជាប់ទាក់ទងដល់គោលដៅថ្នាក់ជាតិមួយចំនួន រួមទាំង ការកាត់បន្ថយភាពក្រីក្រ, ការធានាសន្តិសុខស្បៀង, ការបង្កើនពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ ការអភិវឌ្ឍន៍ជនបទ និងការកែលំអការគ្រប់គ្រងព្រៃឈើ ។ ដើម្បីបំរើទិសដៅគោលនយោបាយទាំងនេះ ការស្រាវជ្រាវបានធ្វើលើពាណិជ្ជកម្ម និងរកទីផ្សារជ័រទឹកនៅ ៤តំបន់គឺ មណ្ឌលគិរី ព្រះវិហារ កំពង់ធំ និងឧត្តរមានជ័យ/សៀមរាប ក្នុងចន្លោះខែសីហា និងវិច្ឆិកា ២០០២ ។ ទិន្នន័យ និងពត៌មាន បានប្រមូលតាមរយៈបទសំភាសន៍ពាក់កណ្តាលរៀបរយជាមួយមនុស្សជិត ៦០នាក់ ដែលជាពាណិជ្ជករជ័រទឹក អ្នកលក់ដុំ អ្នកដឹកជញ្ជូន អ្នកនាំចេញ អ្នកលក់រាយ/អ្នកបែងចែក មន្ត្រីមានសមត្ថកិច្ច, ការធ្វើដំណើរជាមួយការដឹកជញ្ជូនជ័រទឹក, និងការធ្វើអង្កេតយ៉ាងខ្លីលើតំណាងសហគមន៍មួយចំនួនមកពីតំបន់ផលិតជ័រទឹកក្នុងខេត្តទាំង ៩ ។

## ១.១. កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុនៃការសិក្សានេះរួមមាន ធ្វើការកំណត់ពីឧបសគ្គលើពាណិជ្ជកម្មជ័រទឹក, ការគណនាពីបន្ទុកចំណាយលើឧបសគ្គទាំងនេះ ការប៉ាន់ស្មានពីផលប៉ះពាល់របស់វា និងការផ្តល់អនុសាសន៍ខាងគោលនយោបាយដែលគាំទ្រដល់គោលដៅរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រ ធានាសន្តិសុខស្បៀង បង្កើនពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ និងកែលំអការគ្រប់គ្រងព្រៃឈើ ។ ជាពិសេសទៅទៀត ការសិក្សានេះមានគោលបំណង:

- ពិពណ៌នាពីវិធីផ្សេងៗសំរាប់ដងយកជ័រ ទំលាប់នៃការកាន់កាប់ដើមឈើផ្តល់ជ័រទឹកនិងបទប្បញ្ញត្តិច្បាប់នានា និងការគូសបញ្ជាក់ពីសារៈសំខាន់នៃការប្រើប្រាស់ជ័រទឹក និងផលិតផលរបស់វា (ជំពូកទី២) ។
- ធ្វើការវាយតំលៃពីការគំរាមគំហែងនៃការកាប់ឈើដែលប៉ះពាល់ដល់សកម្មភាពដងជ័រទឹក រួមទាំង ពិភាក្សាពីការអនុវត្តន៍ការកាប់ឈើ ច្បាប់ហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹក និងផលប៉ះពាល់ដល់កំណែទំរង់ព្រៃឈើ (ជំពូកទី ៣) ។
- ធ្វើវិភាគពីផលិតកម្ម និងរកទីផ្សារជ័រទឹក ។ ធ្វើការប៉ាន់ស្មានពីផលិតកម្មជ័រទឹកនៅទូទាំងប្រទេស, ចំនួនជ័រទឹកប្រើប្រាស់ក្នុងស្រុក និងនាំចេញ, ពិពណ៌នាពីរចនាសម្ព័ន្ធទីផ្សារគួយ៉ាងសំរាប់ពាណិជ្ជកម្មជ័រទឹក និងការនាំចេញ, និងវាយតំលៃពីតួនាទីឥណទាន និងកត្តាផ្សេងៗទៀតក្នុងពាណិជ្ជកម្មជ័រទឹក (ជំពូកទី៤) ។
- ពណ៌នាថាតើប្រព័ន្ធបទប្បញ្ញត្តិជាផ្លូវការនៃការគ្រប់គ្រងពាណិជ្ជកម្មជ័រទឹក ប្រព្រឹត្តទៅក្នុងទំរង់យ៉ាងដូចម្តេច និងតើប្រព័ន្ធនៃការអនុវត្តជាក់ស្តែងប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ (ជំពូកទី៥) ។
- រកមើលពីបញ្ហាប្រឈមចំបងៗចំពោះពាណិជ្ជកម្មនិងការនាំចេញជ័រទឹក និងគណនាពីបន្ទុកចំណាយជាប់ទាក់ទិន ។ ប៉ាន់ស្មាននិងវិភាគពីថ្លៃ, បន្ទុកចំណាយលើប្រតិបត្តិការ, ប្រាក់កំរៃ, និងផលចំណេញជាប់ទាក់ទិននឹងការរកទីផ្សារតាំងពីជ័រទឹកនៅឯព្រៃ ទៅដល់ទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ (ជំពូកទី៦) ។
- គូសបញ្ជាក់ពីការជាប់ទាក់ទងនៃការសិក្សានេះ ទៅនឹងទិសដៅគោលនយោបាយជាគន្លឹះរបស់រដ្ឋាភិបាល និងធ្វើការកំណត់អនុសាសន៍ទាក់ទងនឹងជំរើសគោលនយោបាយនានា (ជំពូកទី៧) ។

## ១.២. វិធីសាស្ត្រ

ក្នុងការជ្រើសរើសផ្លូវពាណិជ្ជកម្មសំរាប់ធ្វើសិក្សា វបសអ បានពិនិត្យលើឯកសារដែលមានស្រាប់ និងបានប្រឹក្សាជាមួយអង្គការនានាដែលធ្វើការលើបញ្ហាគ្រប់គ្រងព្រៃឈើ និងអភិវឌ្ឍន៍ជនបទ, ដើម្បីស្វែងរកតំបន់ដែលមានផលិតកម្មជ័រទឹកច្រើនគួរកត់សំគាល់ និងមានភាពក្រីក្រនិងអសន្តិសុខស្បៀងកំរិតខ្ពស់ ។ ដោយឡែក វបសអ បានពិចារណាលើការវិភាគរបស់កម្មវិធីស្បៀងអាហារពិភពលោក (២០០១) ដែលបានរកឃើញថា មានប្រជាជន ៣០០.០០០នាក់ រស់នៅក្នុង ៦៧ "ឃុំគួរបារម្ភ"

ដែលជាតំបន់ងាយរងគ្រោះ ដោយសារតែមានការពឹងផ្អែកខ្លាំងលើព្រៃឈើ, អត្រាបាត់បង់ព្រៃឈើខ្ពស់, អសន្តិសុខស្បៀង និងភាពក្រីក្រ ។ តាមការសិក្សារបស់កម្មវិធីស្បៀងអាហារពិភពលោក (WFP) "សន្តិសុខស្បៀងនៅឃុំទាំងនេះ អាចទទួលរងគ្រោះពីផលប៉ះពាល់អវិជ្ជមាននៃការបាត់បង់ព្រៃឈើ" ។ ផ្អែកលើតំហើញនៃការសិក្សារបស់ WFP និងពត៌មានមានស្រាប់ស្តីពីតំបន់ដងជ័រទឹក, វិបសអ បានជ្រើសយក ៤តំបន់ (៧ស្រុក) ដែលគេដឹងថាមានផលិតកម្មនិងពាណិជ្ជកម្មជ័រទឹកច្រើន ដែលក្នុងនេះមាន ១៣ឃុំគួរបារម្ភ ។ នៅឆ្នាំ២០០២ ស្រុកដែលផលិតជ័រទឹកទាំង៧ដែលបានជ្រើសរើសសំរាប់ការសិក្សានេះ មានឱនភាពស្រូវ (MAFF 2003) ។ ផែនទីផ្លូវពាណិជ្ជកម្មទីមួយៗ បានបង្ហាញក្នុងឧបសម្ព័ន្ធ ក ។

មណ្ឌលគិរី

<u>តំបន់ជ្រើសរើស</u>: ស្រុកកែវសីមា និងស្រុកអូររាំង (មាន ២ឃុំគួរបារម្ភ)

<u>ផ្លូវពាណិជ្ជកម្មបានសិក្សា</u>: ពីកែវសីមា ទៅស្រុកមេមត់ (កំពង់ចាម) និងបន្តទៅព្រំដែនវៀតណាម

ព្រះវិហារ

<u>តំបន់ជ្រើសរើស</u>: ស្រុករវៀង និងស្រុកត្បែងមានជ័យ (មាន ៧ឃុំគួរបារម្ភ)

<u>ផ្លូវពាណិជ្ជកម្មបានសិក្សា</u>: ពីត្បែងមានជ័យ ទៅស្រុកត្បូងឃ្មុំ (កំពង់ចាម) និងបន្តទៅព្រំដែនវៀតណាម

កំពង់ធំ

<u>តំបន់ជ្រើសរើស</u>: ស្រុកសណ្តាន់ ក្នុងខេត្តកំពង់ធំ (មាន ១ឃុំគួរបារម្ភ)

<u>ផ្លូវពាណិជ្ជកម្មបានសិក្សា</u>: ពីក្រុងកំពង់ធំ និងស្រុកកំពង់ថ្ម មកភ្នំពេញ

ឧត្តរមានជ័យ/សៀមរាប

<u>តំបន់ជ្រើសរើស</u>: ស្រុកអន្លង់វែងក្នុងខេត្តឧត្តរមានជ័យ និងស្រុកបន្ទាយស្រី ក្នុងខេត្តសៀមរាប (មាន ៣ឃុំ)

<u>ផ្លូវពាណិជ្ជកម្មបានសិក្សា</u>: ពីស្រុកអន្លង់វែង (ឧត្តរមានជ័យ) ទៅចុងឃ្នាស (សៀមរាប)[៤]

វិបសអ បានចុះធ្វើការស្រាវជ្រាវដល់កន្លែងអំពីពាណិជ្ជកម្មជ័រទឹក ដោយបានធ្វើដំណើរ ៤ជើងទៅកាន់តំបន់សិក្សានានា នៅចន្លោះខែសីហា និងវិច្ឆិកា ២០០២ ។ ដោយប្រើបញ្ជីសំណួររៀបចំស្រេច, ការស្រាវជ្រាវបានធ្វើសំភាសន៍ពាក់កណ្តាលរៀបរយចំនួន ៥៧រូប ដែលមានពាណិជ្ជករ (១៧នាក់), អ្នកលក់ដុំ (១៤នាក់), អ្នកដឹកជញ្ជូន (១២នាក់), អ្នកនាំចេញ (២នាក់), និងអ្នកលក់រាយ/អ្នកចែក ចាយ (១២នាក់) ។ គេមិនបានប្រើវិធីសាស្រ្តយកសំណាកជាផ្លូវការដើម្បីជ្រើសរើសអ្នកឆ្លើយសំភាសន៍ទេ ដោយសារខ្វះពត៌មានជាមុនស្តីពីចំនួន អត្តសញ្ញាណ និងទីតាំងរបស់អ្នកដែលធ្វើសកម្មភាពនៅក្នុងពាណិជ្ជកម្ម និងការនាំចេញជ័រទឹក ។ ប៉ុន្តែដោយផ្អែកទៅលើទំហំនៃសកម្មភាពធ្វើសំភាសន៍ដ៏ទូលំទូលាយ (៤ផ្លូវពាណិជ្ជកម្មជ័រទឹកចេញពីតំបន់ផលិតកម្មជ័រទឹកសំខាន់ៗ) និងការពិនិត្យផ្ទៀងផ្ទាត់យ៉ាងច្រើនលើពត៌មាននានា, ទិន្នន័យដែលទទួលបានសំរាប់ការសិក្សានេះសង្ឃឹមថាអាចតំណាងបាននូវ លក្ខខណ្ឌផលិតកម្ម ទីផ្សារ និងជំនួញជ័រទឹក នៅក្នុងទូទាំងប្រទេស ។

វិបសអ បានអនុវត្តវិធានការមួយចំនួនថែមទៀត ដើម្បីប្រមូលពត៌មានសំរាប់គាំទ្រដល់ការសិក្សានេះ ។ ទី១ បានធ្វើដំណើរមួយលើកជាមួយអ្នកដឹកជញ្ជូនជ័រទឹកពីស្រុកកែវសីមា ទៅស្រុកមេមត់ ដើម្បីសង្កេតដោយផ្ទាល់ពីលក្ខខណ្ឌពាណិជ្ជកម្ម, ប្រមូលទិន្នន័យពីថ្លៃ បន្ទុកចំណាយ ប្រាក់កំរៃ និងផ្ទៀងផ្ទាត់ទិន្នន័យនេះជាមួយនឹងពត៌មានប្រមូលបានពីបទសំភាសន៍ ។ ទី២

[៤] ក្នុងពេលស្រាវជ្រាវ គេរកឃើញថា អ្នកលក់ដុំគ្មានប្រភពជ័រទឹកពីបន្ទាយស្រីទៀតទេ ។ ឥលូវនេះ គេពឹងលើការផ្គត់ផ្គង់ពីអន្លង់វែង ។ វិបសអ មិនអាចបញ្ជាក់ចំពោះហេតុផលនៃការប្តូរទិសដៅក្នុងការផ្គត់ផ្គង់ជ័រទឹកនេះបានឡើយ ។

ដោយមានជំនួយពី NGO Forum វបសអ បានធ្វើអង្កេតខ្លីមួយជាមួយនឹងតំណាងសហគមន៍មកពីតំបន់ផលិតជ័រទឹកក្នុង ៩ខេត្ត ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យបានពីការចុះសិក្សាដល់កន្លែង និងកែលំអពតិមានស្តីពីផលិតកម្មជ័រទឹក និងចំនួនប្រជាជនអ្នកទាញយកចំណូលពីការដងជ័រទឹក ។ ទី៣ វបសអ បានសំភាសមន្ត្រីមកពីក្រសួងពាណិជ្ជកម្ម និងនាយកដ្ឋានរុក្ខាប្រមាញ់ ដើម្បីកំណត់ និងបញ្ជាក់ពីក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងពាណិជ្ជកម្មផលិតផលព្រៃឈើ ។

ការសិក្សានេះក៏មានកំហិតមួយចំនួនគួរកត់សំគាល់ឡើងដែរ ។ ទី១ ការសិក្សានេះពិនិត្យលើ ៤ផ្លូវពាណិជ្ជកម្មជ័រទឹកចំបង៧ទៅកាន់ទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ប៉ុន្តែកម្ពុជាមានតំបន់ផលិតជ័រទឹក និងផ្លូវពាណិជ្ជកម្មជ័រទឹកជាច្រើនទៀតដែលមិនបានពិនិត្យសិក្សា ។ ទី២ ទិន្នន័យប្រមូលបានសំរាប់ការសិក្សានេះ ឆ្លុះបញ្ចាំងពីសកម្មភាពពាណិជ្ជកម្មក្នុងកំឡុងពេលចាប់ពីពាក់កណ្តាល ដល់ចុងរដូវវស្សា ។ អ្នកឆ្លើយសំភាសន៍បានប្រាប់ថា ផលិតកម្ម និងពាណិជ្ជកម្មជ័រទឹកប្រែប្រួលតាមរដូវកាល ដូចជា ទិន្នផលជ័រទឹកធ្លាក់ចុះបន្តិចនៅរដូវប្រាំង ឬក៏ពាណិជ្ជករជួបបញ្ហាក្នុងការចូលទៅដល់តំបន់ផលិតជ័រទឹកនៅរដូវវស្សា។ ប៉ុន្តែយោងតាមពាណិជ្ជករ និងអ្នកលក់ដុំនៅតាមតំបន់ដែលបានសិក្សា, ការប្រែប្រួលតាមរដូវកាលនេះមិនប៉ះពាល់ដល់ថ្លៃជ័រទឹកខ្លាំងទេ ។ ពួកគេកត់សំគាល់ថា ជ័រទឹកអាចស្តុកទុកបានយ៉ាងស្រួល ដូច្នេះវាមិនសូវឡើងចុះថ្លៃខ្លាំងទេ ។ ដោយមូលហេតុទាំងនេះគេរំពឹងថា ការប្រែប្រួលតាមរដូវកាល មិនប៉ះពាល់ច្រើនដល់លទ្ធផលជាទូទៅនៃការស្រាវជ្រាវនេះទេ ។ ជាទីបញ្ចប់ ចំណុចស្រាវជ្រាវមួយចំនួនគួរយកចិត្តទុកដាក់ឱ្យបានច្រើនថែមទៀត ប៉ុន្តែការនេះមិនអាចធ្វើទៅបាន ដោយសារធនធានមានកំរិត និងកង្វះចំណេះដឹងខាងបច្ចេកទេស ។ ឧទាហរណ៍ គេមិនអាចកំណត់ដឹងថា ហេតុអ្វីបានជាជ័រទឹកនៅខេត្តកំពង់ធំមានគុណភាពអន់ជាងនៅតំបន់ផ្សេងទៀត (រួមទាំងខេត្តព្រះវិហារដែលនៅជាប់នោះផង) ។

# ជំពូកទី ២

# ការជងជ័រ ការកាន់កាប់ដើមឈើ និងផលិតផល

នៅកម្ពុជា គេប្រមូលបានទាំងជ័ររាវ និងជ័ររឹង ។ ពពួកពូជដើមឈើទាល (dipterocarpus alatus) គឺជាប្រភពជ័ររាវដ៏សំខាន់ ប៉ុន្តែនៅមាន ៥ពូជឈើផ្សេងទៀតយ៉ាងតិចដែលគេអាចប្រមូលយកជ័របាន (Evans *et al.* 2003, Smitinand 1980) ។ ពូជ dipterocarpus ភាគច្រើនមានឈ្មោះជាភាសាខ្មែរថា ឈើទាល រួមទាំងឈើប្រភេទផ្សេងមួយចំនួនទៀត (ដូចជា ឈើទាលទឹក ឈើទាលម្សៅ) ។ ជ័ររាវប្រមូលបានពីពូជឈើទាំងនេះ ហៅថា ជ័រទឹក ។ ក្នុងកន្លែងផ្សេងទៀតនៅអាស៊ីអគ្នេយ៍ ជ័ររាវអាចមានឈ្មោះថា ប្រេង *yang, gurjun, gurjun balsam, nam man nyang* (ឡាវ) ឬ ប្រេង *keruing* (ម៉ាឡេស៊ី) ។ ដើម្បីចៀសវាងការភ័ន្តច្រឡំ ការសិក្សានេះនឹងប្រើពាក្យ "ជ័រទឹក" ដើម្បីសំគាល់ជ័ររាវ ចាប់ពីពេលនេះតទៅ [៥] ។

ជ័ររឹង (ពាក្យខ្មែរហៅថា ជ័រចុង) ប្រមូលបានពីពូជឈើ Shorea នៅតាមកន្លែងដើមឈើមានរបួស (ដូចជា បាក់មែក) ដែលបណ្តាលឱ្យចេញជ័រមកកកជាដុំមួយ ។ គេប្រមូលជ័រដុំទាំងនេះដោយឡើងទៅបេះពីដើម ប្រើចំពាមកៅស៊ូ ឬ រើសពីដីតែម្តងបើសិនវាបានជ្រុះមកហើយ ។ ដោយសារប្រភពផ្គត់ផ្គង់មានកំណត់ ការប្រមូលនិងជំនួញជ័រចុង បានដើរតួនាទីតូចជាងជ័រទឹកនៅក្នុងជីវភាពរស់នៅរបស់សហគមន៍ព្រៃឈើ ។ ដូច្នេះ ជ័រចុងមិនមែនចំណុចផ្តោតនៅក្នុងការសិក្សានេះទេ [៦] ។

## ២.១. វិធីជងជ័រទឹក និងទិន្នផល[៧]

ដើម្បីជងជ័រទឹក គេត្រូវចោះរន្ធទេរចុះទៅខាងក្រោយ (រន្ធច្បោះ) នៅលើដើមឈើធំៗ ដែលតាមធម្មតាមានអង្កត់ផ្ចិតធំជាង ៦០ស.ម. [៨] ។ គេដុតរន្ធច្បោះមួយរយៈខ្លីដើម្បីឱ្យជ័រទឹកហូរចេញច្រើន ហើយគេជងវាដាក់ធុងប្លាស្ទិក (ឬក្នុងករណីខ្លះ ច្រកថង់ប្លាស្ទិក) នៅពេល ២-៣ថ្ងៃបន្ទាប់ ។ ក្រោយមក អ្នករកជ័រធ្វើដដែលៗ គឺដុតរន្ធច្បោះ ហើយត្រលប់មកប្រមូលយកជ័រ ជារៀងរាល់ ៥-១៥ថ្ងៃម្តង ។ ការសិក្សាបានបង្ហាញថា វិធីសាស្ត្រនេះបានអនុវត្តប្រហាក់ប្រហែលគ្នា ក្នុងទូទាំងប្រទេស កម្ពុជា ឡាវ និង ថៃ (Evans *et al.* 2003, Juiprik and Kijtewachakul 2001, Ankarfjard and Kegl 1998) ។ មានរបាយការណ៍មួយចំនួនបញ្ជាក់ថា បើសិនប្រើវិធីប្រមូលជ័រទឹកបែបនេះ ដើមឈើអាចផ្តល់ទិន្នផលបានច្រើនទសវត្សរ៍ គឺប្រហែលជាង ៧០ឆ្នាំបើតាមឯកសារ Enfield *et al.* 1998 ឬ ៥០-៨០ឆ្នាំបើតាមឯកសារ Ankarfjard and Kegl 1998 ។

---

[៥] តាមបច្ចេកទេស ជ័ររាវគឺជា "oleoresin" ដោយសារវាមានជាតិប្រេងសំខាន់ម៉្យាង (ហួតហើរលឿន) ។

[៦] ប៉ុន្តែគួរកត់សំគាល់ថា អ្នកជំនួញ និងអ្នកលក់ដុំជាច្រើននាក់ដែលផ្តល់សំភាសន៍ដល់ការសិក្សានេះ បានបង្ហាញថា ជំនួញជ័រចុងអាចមានទំហំធំជាង ប៉ុន្តែដោយសារវាមានដង់ស៊ីតេទាប និងមានទំងន់ស្រាលជាងជ័រទឹករាវ, ការដឹកជញ្ជូនមានតំលៃខ្ពស់ជាង (គិតតាមឯកតាទម្ងន់) ។

[៧] ផ្នែកនេះ បានដកស្រង់ពត៌មានយ៉ាងច្រើនពីការសិក្សាដ៏ទូលំទូលាយមួយ ឧបត្ថម្ភដោយសហគមន៍អភិរក្សសត្វព្រៃ (WCS) និងធ្វើដោយ Evans *et al.* (2003) ស្តីពីការប្រមូលជ័រទឹក និងជីវភាពរស់នៅក្នុងខេត្តមណ្ឌលគិរី កម្ពុជា ។ ការសិក្សានេះក៏បានផ្តល់ ការពិនិត្យមើលឡើងវិញយ៉ាងម៉ត់ចត់និងយ៉ាងសំខាន់នូវ ពត៌មានស្តីពីការប្រមូលជ័រទឹកដែលបានបោះពុម្ពផ្សាយហើយ ។

[៨] ការវាយតំលៃលើដើមឈើចោះយកជ័រជាង២.៥០០ដើមនៅមណ្ឌលគិរី Evans *et al.(2003)* បានរកឃើញថា អង្កត់ផ្ចិតដើមឈើជាមធ្យមនៅកំពស់ត្រឹមដើមទ្រូង គឺ ៨២ស.ម , ដោយឡែក ដើមឈើ ៩៦,៥%មានអង្កត់ផ្ចិតធំជាង ៤៥ស.ម ហើយ ៧៨% គឺធំជាង ៦០ស.ម ។

ជាទូទៅ ដើមឈើកាន់តែធំ គឺអាចផ្ដល់ជ័រទឹកបានកាន់តែច្រើន។ ផ្អែកតាមបទសំភាសន៍សំរាប់ការសិក្សានេះ ដើមឈើផ្ដល់ជ័រទឹក "ជាតួយ៉ាង" ផ្ដល់ជ័រទឹកប្រចាំឆ្នាំបានប្រហែល ៣០-៣៥លីត្រ ។ តួលេខនេះ ស៊ីគ្នាជាមួយនឹងការសិក្សាផ្សេងៗទៀត ដែលរកឃើញ ទិន្នផលមធ្យម ក្នុងកំរិត ៣០-៤០លីត្រ/ឆ្នាំ (Evans *et al.* 2003), ២២,៥-៣១លីត្រ/ឆ្នាំនៅឡាវ (Ankarfjard and Kegl 1998), និង ៣០-៣៥លីត្រ/ឆ្នាំ (Smitinand *et al.* 1990 in Ankarfjard and Kegl 1998) ។ ទោះបីមានការរាយការណ៍ថា ដើមឈើផ្ដល់ទិន្នផលនៅរដូវវស្សាបានច្រើនជាងនៅរដូវប្រាំងក្ដី ប៉ុន្ដែការប្រមូល/ផលិតកម្មជ័រទឹកសរុប ហាក់ដូចនៅថេរគួរសមក្នុងពេញមួយឆ្នាំ ។ មូលហេតុគឺអ្នកដងជ័រតែងចូលទៅព្រៃនៅរដូវវស្សា តិចដងជាងនៅរដូវប្រាំង ដោយសារមានទឹកជន់លិច ឬក៏ពួកគេជាប់រវល់ខ្លាំងក្នុងការងារធ្វើស្រែ/ចំការ (ជាពិសេសក្នុងរយៈពេលដកស្ទូង និងប្រមូលផល) ។ ផ្ទុយទៅវិញ អ្នកដងជ័រអាចប្រកបការងារដងជ័រទឹកយ៉ាងសកម្មនៅរដូវប្រាំង ដែលជាពេលមិនសូវមានការងារអ្វីផ្សេងធ្វើ ។ គេមិនទាន់ដឹងច្បាស់ទេថា ទិន្នផលនៃដើមឈើជាក់លាក់ណាមួយវាប្រែប្រួលយ៉ាងណាក្នុងរយៈច្រើនឆ្នាំ/ទសវត្សរ៍ ។ គេរាយការណ៍ថា រន្ធច្បោះថ្មីផ្ដល់ទិន្នផលខ្ពស់ពីដំបូង ហើយអាចធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំក្រោយមក (Evans *et al.* 2003) ។ ពេលនោះអ្នកដងជ័រអាចចោះរន្ធថ្មី ប៉ុន្ដែ គេមិនច្បាស់ទេថា តើវិធីនេះអាចបង្កើនទិន្នផលជ័រទឹកដល់កំរិតពីដំបូងវិញឬយ៉ាងណា ។

ការដុតរន្ធច្បោះ និងការប្រមូលជ័រ មិនធ្វើឱ្យខូចដល់ដើមឈើផ្ដល់ជ័រទឹកទេ ហើយហានិភ័យនៃការរាលភ្លើងឆេះព្រៃ ហាក់ដូច មានតិចតួចបំផុត ដោយសារការដុតនេះមានរយៈពេលខ្លី និងមានការគ្រប់គ្រងល្អ (Evans *et al.* 2003, Enfield *et al.* 1998, Foppes and Ketphanh 1997) ។ ក្នុងការសិក្សាដ៏គ្រប់ជ្រុងជ្រោយជាងគេមួយ Evans *et al.* (2003) បានវិភាគលើការខូចខាតជាសក្ដានុពលចំពោះដើមឈើជាង ២.៥០០ដើមដែលគេកំពុងដងជ័រទឹកយ៉ាងសកម្មនៅខេត្តមណ្ឌលគិរី ។ ការសិក្សារកឃើញថា ករណីនៃការដងជ័រដែលធ្វើឱ្យខូចខាតគួរកត់សំគាល់ដល់ដើមឈើ គឺកំរមានណាស់ ហើយគេឃើញមានដើមឈើតែ ២ដើមប៉ុណ្ណោះ ដែលបានងាប់ដោយមូលហេតុជាប់ទាក់ទិននឹងការដងជ័រទឹក (រន្ធច្បោះដុតឆេះជ្រុល) ។ គេមិនឃើញមានភស្ដុតាងអ្វីដែលបង្ហាញថា ដើមឈើដែលបានដងជ័រទឹកយូរមកហើយ វាមានការខូចខាតច្រើនជាងដើមឈើទើបចោះថ្មីៗ ។ លើសពីនេះទៀត ក្នុងការសិក្សាមួយស្ដីពីនៃផលប៉ះពាល់ពីការដងជ័រទឹក ចំពោះតំលៃឈើហ៊ុបក្នុងខេត្តសុវណ្ណកេត នៅប្រទេសឡាវ Ankarfrjard (2000) បានរកឃើញថា ពុំមានម្ចាស់រោងអារឈើណាមួយយល់ថា ការដងជ័រ បានចោទបញ្ហាដល់គុណភាពឈើហ៊ុបឬក៏ធ្វើឱ្យប៉ះពាល់ដល់ថ្លៃឈើហ៊ុបនោះទេ ។



ដើមឈើទាលដែលគេដងយកជ័រទឹកនៅខេត្តមណ្ឌលគិរី (រូបភាពថតដោយ *WCS*)

## ២.២. ការកាន់កាប់ដើមឈើផ្ដល់ជ័រទឹកតាមទំលាប់ និងបទប្បញ្ញត្តិច្បាប់ជាប់ទាក់ទិន

ការកាន់កាប់ដើមឈើផ្ដល់ជ័រទឹកតាមទំលាប់ ឃើញមានប្រហាក់ប្រហែលគ្នាក្នុងតំបន់សិក្សាទាំង ៤ ហើយវាមានដំណើរការស្របគ្នាជាមួយនឹងគំហើញលំអិតរបស់ Evans *et al.* (2003) ។ តាមទំលាប់ មនុស្សទីមួយដែលបានរកឃើញ និងដៅលើដើមឈើផ្ដល់ជ័រទឹក ត្រូវបានគេចាត់ទុកថាជាម្ចាស់នៃដើមឈើនោះ ។ នៅតាមតំបន់ខ្លះ ដើមឈើផ្ដល់ជ័រទឹកដុះទៅតាមក្រុមរបស់វាយ៉ាងល្អ (៣០-៥០ដើម) ដូច្នេះតាមធម្មតាមនុស្សដដែលនោះតែងរកឃើញ, ដៅសំគាល់ និងកាន់កាប់ដើមឈើផ្ដល់ជ័រទឹកទាំងអស់ក្នុងដើមឈើមួយក្រុមនោះ ។ ក្នុងតំបន់ផ្សេងទៀត ដើមឈើផ្ដល់ជ័រទឹកមានដុះនៅតាមដងអូរ ឬដុះរាយប៉ាយនៅក្នុងព្រៃ ។

តាមធម្មតាគ្រួសារយកជ័រនិមួយៗមានកាន់កាប់ដើមឈើផ្តល់ជ័រទឹក ៣០-១០០ដើម ប៉ុន្តែគ្រួសារខ្លះកាន់កាប់តិចជាង ហើយគ្រួសារខ្លះទៀតអះអាងថាមានដល់ច្រើនរយដើម ។

សមាជិកក្នុងភូមិជាមួយគ្នា និងភូមិជិតខាង បានទទួលស្គាល់កម្មសិទ្ធិដើមឈើផ្តល់ជ័រទឹកជាទ្រព្យឯកជន ដែលគេអាចផ្ទេរកម្មសិទ្ធិ បានតាមរយៈការលក់ដូរ ការបន្តមរតក ការបរិច្ចាក ឬលក់សិទ្ធិប្រមូលយកជ័រក្នុងរយៈពេលជាកំណត់មួយ ។ ប្រព័ន្ធកាន់កាប់នេះ មានតែចំពោះដើមឈើផ្តល់ជ័រទឹកមួយមុខ រីឯដើមឈើ និងអនុផលព្រៃឈើផ្សេងៗទៀត គ្មាន "ម្ចាស់" ទេ ហើយលទ្ធភាពប្រើប្រាស់ធន ធានទាំងនេះគឺបើកទូលាយសំរាប់ទាំងអស់គ្នា (Evans *et al.* 2003) ។ ដោយសារគេចាត់ទុកដើមឈើផ្តល់ជ័រទឹកជាទ្រព្យឯកជន អ្នកជងជ័រមានទឹកចិត្តមោះមុតក្នុងការការពារដើមឈើផ្តល់ជ័រទឹកឱ្យជៀសផុតពីការកាប់ធ្វើជាឈើហ៊ុប ។ សន្ទុះចិត្តក្នុងការគ្រប់គ្រង និងការពារព្រៃឈើបែបនេះ អាចផ្តល់មូលដ្ឋានរឹងមាំមួយសំរាប់ការពង្រីកកិច្ចប្រឹងប្រែងគ្រប់គ្រងព្រៃឈើក្នុងស្រុកនៅពេលអនាគត ។

ទោះជារបៀបរបបតាមទំលាប់ដូចខាងលើ គឺជាការធ្វើម្ចាស់លើដើមឈើក្តី ប៉ុន្តែកម្មសិទ្ធិនេះគ្មានមូលដ្ឋានជាច្បាប់ទេ ។ តាម ច្បាប់ស្តីពីព្រៃឈើ (២០០២) ព្រៃឈើគឺជាសម្បត្តិរដ្ឋ ( មាត្រា ២.ខ) ។ រដ្ឋអាចផ្តល់ សិទ្ធិដល់អ្នកប្រើប្រាស់តាមទំលាប់ចំពោះផលិតផលឈើ និងអនុផលព្រៃឈើ (NTFPs) ស្របតាមមាត្រា ២.គ. ប៉ុន្តែសិទ្ធិនេះផ្តល់សុវត្ថិភាពដល់ការកាន់កាប់ ក្នុងកំរិតតិចជាង ការកាន់កាប់ជាទ្រព្យឯកជន ពីព្រោះរដ្ឋអាចដកហូតសិទ្ធិពីអ្នកប្រើប្រាស់វិញបាន នៅពេលអនាគត ។

ច្បាប់ស្តីពីព្រៃឈើ ធានាសិទ្ធិអ្នកប្រើប្រាស់ចំពោះជ័រទឹកនិង NTFPs ផ្សេងៗតាមមាត្រាមួយចំនួន ក្នុងនេះ មាត្រា ៤០ បានដោះស្រាយបញ្ហាចំចំណុចជាងគេៈ

> មាត្រា ៤០
>
> ក. ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬក្បែរដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះ សំរាប់គោលបំណងទំនៀមទំលាប់ សាសនា និងការរស់នៅដូចមានចែងក្នុងច្បាប់នេះ ។
>
> ខ. សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល-អនុផលព្រៃឈើ ដោយសហគមន៍មូលដ្ឋាន មិនតំរូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះ រួមមានៈ
>
> ១. ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់ ....
>
> ៥. សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើ ដោយពុំចាំបាច់មានលិខិតអនុញ្ញាត ប្រសិនបើការលក់ដូរនេះ មិនគំរាមកំហែងដល់ចីរភាពនៃព្រៃឈើ ។ អតិថិជន ឬភាគីទីបីណាមួយ ដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍ក្នុងគោលដៅពាណិជ្ជកម្ម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ អាចធ្វើការដឹកជញ្ជូនទៅកាន់ទិសដៅបាន ដោយតំរូវឱ្យមានលិខិតដឹកជញ្ជូន ក្រោយពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច ។
>
> គ. សហគមន៍មូលដ្ឋាន មិនអាចផ្ទេរសិទ្ធិប្រើប្រាស់ជាប្រពៃណី ឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញទៅមកក្តី ឬស្ថិតក្រោមកិច្ចសន្យាក្តី ...

ភាពខុសប្លែកគ្នាមួយចំនួនរវាងប្រព័ន្ធកាប់កាប់តាមទំលាប់ និងបទប្បញ្ញត្តិច្បាប់ គួរតែធ្វើការកត់សំគាល់ឡើង ។ ទី១ ផ្ទុយពីការកាប់កាប់តាមទំលាប់ដែលអនុញ្ញាតឱ្យមានកម្មសិទ្ធិ និងការផ្ទេរកម្មសិទ្ធិ លើដើមឈើផ្តល់ជ័រទឹក, មាត្រា៤០ គ្រាន់តែធានាសិទ្ធិ ប្រើប្រាស់ និងហាមឃាត់ការផ្ទេរសិទ្ធិប្រើប្រាស់ទាំងនេះប៉ុណ្ណោះ ។ ទី២ ទោះជាមាត្រាទី ៤០ បានបញ្ជាក់ច្បាស់ថា មិនតំរូវឱ្យមានលិខិតអនុញ្ញាតទេ (ប្រមូលផល) ចំពោះការជងជ័រទឹក, ប៉ុន្តែពាណិជ្ជកម្មជ័រទឹកតំរូវឱ្យមានលិខិតដឹកជញ្ជូន និងការបង់ប្រាក់កំរៃ ។ វាជា "ទំនៀមទំលាប់" យូរយារណាស់មកហើយ ក្នុងការធ្វើពាណិជ្ជកម្មជ័រទឹកពីតំបន់ព្រៃឈើដែលមានការប្រើប្រាស់តិច ទៅកាន់តំបន់មានតំរូវការខ្ពស់ (សូមអានផ្នែក ២.៣) ។ ដោយសារជ័រទឹកសឹងតែទាំងអស់ត្រូវបានលក់ដូរ ដូច្នេះ មាត្រា៤០ បានផ្តល់ជាមូលដ្ឋានសំរាប់ការយកប្រាក់កំរៃលើជ័រទឹកដែលផលិតបានសឹងតែទាំងអស់ ។

## ២.៣. ផលិតផលជ័រទឹកចំបងៗ

នៅកម្ពុជា ជ័រទឹកបានលក់ដូរសំរាប់យកទៅ ប្រើឆៅ, ច្រោះសំអាតបង្កើនគុណភាព (តាមធម្មតាសំរាប់នាំចេញ) ឬលាយជាមួយសារធាតុផ្សេងៗ (ដូចជា ជ័រចុង ប្រេងកាត និងស្លឹកព្រាល) ដើម្បីបិទបាតទូក, ធ្វើវត្ថុខាប់រាវច្រើនយ៉ាងសំរាប់ការពារជ្រាបទឹក, និងធ្វើចន្លុះ ។ អ្នកលក់ដុំជើរតួនាទីសកម្មជាងគេក្នុងការកែច្នៃជ័រទឹក ប៉ុន្តែអ្នកលក់រាយ និងអ្នកនាំចេញ កែច្នៃជ័រទឹកម្តងម្កាលដែរ ដើម្បីឆ្លើយតបនឹងតំរូវការរបស់អ្នកប្រើប្រាស់ ។ ការកែច្នៃភាគច្រើនមានគោលដៅ យកកំទេចកំទីផ្សេងៗចេញពីជ័រទឹក ដែលអាចធ្វើឡើងតាមរយៈការច្រោះសំអាត និង/ឬទុកឱ្យរង ។ ផលិតផលចុងក្រោយគឺជាជ័រទឹកដែលរាវ និងស្មើសាច់ជាងមុន ។ ផលិតផលជ័រទឹកមួយចំនួនដែលឃើញមានជាទូទៅ មានពិពណ៌នានៅខាងក្រោម ។

### ២.៣.១. ជ័រទឹកគុណភាពនាំចេញ

តាមការសំភាសន៍ និងអង្កេតផ្ទាល់ ជ័រទឹកដែលលក់ចេញពីខេត្តព្រះវិហារ មណ្ឌលគីរី និងឧត្តរមានជ័យ មានគុណភាពខ្ពស់ជាង (រាវជាង, ស្មើសាច់ជាង) ជ័រទឹកលក់ចេញពីតំបន់បានសិក្សានៅខេត្តកំពង់ធំ ។ ជ័រទឹកពីកំពង់ធំ ហាក់ដូចសំរាប់បំរើទីផ្សារក្នុងស្រុកភាគច្រើន ចំណែកជ័រទឹកប្រមូលបានក្នុងតំបន់សិក្សា ៣ផ្សេងទៀត ភាគច្រើនសំរាប់នាំចេញទៅវៀតណាម ។ ការចុះសំភាសន៍ដល់កន្លែង មិនបានផ្តល់ចម្លើយច្បាស់ទេថា ហេតុអ្វីបានជាជ័រទឹកកំពង់ធំ មានគុណភាពខុសគ្នាពី ជ័រទឹកនៃតំបន់ផ្សេងៗទៀត ។ ប៉ុន្តែមានការផ្តល់គំនិតថា គុណភាពខុសគ្នាគឺមកពីអ្នកជងជ័រនៅកំពង់ធំ បានយកជ័រពីពូជឈើមួយចំនួន ដែលខុសគ្នាពីតំបន់ផ្សេងទៀត (P. Swift pers. comm. 2003) ។ គេមិនអាចធ្វើបានទេទូវ ការវិភាគផ្នែកគីមីនៃជ័រទឹកខុសៗគ្នាដែលប្រមូលបាន ឬ ការស្រាវជ្រាវដើម្បីបញ្ជាក់ពីពូជឈើដែលបានយកជ័រ ឬ ការស៊ើបអង្កេតពីប្រែប្រួលខុសប្លែកគ្នាក្នុងវិធីជងយកជ័រ ឬ កត្តាផ្សេងៗទៀតដែលអាចធ្វើឱ្យគុណភាពប្រែប្រួលខុសគ្នា ។

អ្នកលក់ដុំ និងអ្នកនាំចេញបញ្ជាក់ថា ជ័រទឹកសំរាប់នាំចេញទាំងអស់ បានកែច្នៃក្នុងករិតណាមួយដើម្បីយកសំរាមចេញ និងធ្វើឱ្យស្មើសាច់ល្អ ។ វិធីសាស្ត្រទូទៅជាងគេគឺការច្រោះសំអាតដោយប្រើ បាវក្រចៅ/ប្លាស្ទិក ខ្នាត ១០០គ.ក ។ គេច្រកជ័រទឹកឱ្យពេញបាវ រួចទុកឱ្យវាជ្រាបយឺតៗចេញតាមសរសៃបាវស្រក់ចូលទៅក្នុងធុងធំមួយ ។ នៅចុងបញ្ចប់ ក្នុងបាវនៅសល់តែកំទេចកំទីកាកសំណល់ស្មើនឹង ១០-៤០% នៃទំងន់ជ័រទឹកមិនទាន់ច្រោះ ។

តាមការសំភាសន៍ ជ័រទឹកនាំចេញត្រូវបានប្រើប្រាស់ជាធាតុចូលសំរាប់ផលិតកម្មធ្វើថ្នាំលាប និងវ៉េរនី នៅវៀតណាម ។ អ្នកជំនួញខ្លះរាយការណ៍ថា វៀតណាមនាំចេញជ័រទឹកបន្តទៅប្រទេសចិន។ ប៉ុន្តែគួរឱ្យស្តាយដែល រ៉បសអ មិនអាចទទួល/បញ្ជាក់ពតិមានពីការប្រើប្រាស់ចុងក្រោយនូវជ័រទឹកដែលនាំចេញពីកម្ពុជា ។ ការសិក្សាពីការប្រើជ័រទឹកផ្សេងៗនៅអាស៊ីអគ្នេយ៍បង្ហាញថា ជ័រទឹកអាចជាធាតុចូលដ៏សំខាន់សំរាប់ធ្វើថ្នាំលាបនិងវ៉េរនីគុណភាពខ្ពស់ (ប៉ុន្តែថ្នាំលាបនិងវ៉េរនីគុណភាពទាប មិនប្រើជ័រទឹកទៀតទេ ពីព្រោះមានសារធាតុសិប្បនិម្មិតជំនួសដែលថោកជាង) (Ankarfjard and Kegl 1998, Foppes and Ketphanh 1997) ។ ការសិក្សាមួយចំនួនបានបញ្ជាក់ថា ដោយមានការកែច្នៃត្រឹមត្រូវ សារធាតុប្រេងសំខាន់នៅក្នុងជ័រទឹក ជួនកាលគេយកមកប្រើធ្វើ

ទឹកអប់ ប៉ុន្តែរឿងនេះមានការបញ្ជាក់ច្បាស់តែចំពោះជ័រទឹកនៃពូជឈើ dipterocarpus kerrii (Ankarfjard and Kegl 1998, Jantan *et al.* 1990, Gianno 1986) ។ គេនៅមិនទាន់ច្បាស់ទេថា បើសិនវាជាប្រេងពិសេសក្នុងជ័រទឹកបានពីឈើទាល (dipterocarpus alatus) (ដើមឈើដែលគេប្រមូលជ័រទឹកជាទូទៅបំផុតនៅកម្ពុជា) តើគេអាចប្រើការបានដូចគ្នាដែរឬទេ ។



ដំណាក់កាលចុងបញ្ចប់នៃការប្រមូលជ័រទឹកដែលច្រោះជ្រាបចេញពីបាវៈ គុណភាពសមស្របសំរាប់នាំចេញ



ជ័រទឹកដាក់ក្នុងបាវរួចរាល់សំរាប់ធ្វើការនាំចេញពីខេត្តព្រះវិហារ

## ២.៣.២. ជ័របិទទូក/ការពារជ្រាបទឹក

នៅកម្ពុជា អ្នកមានទូកមានប្រហែល ២៥០.០០០-៣០០.០០០នាក់ ហើយជ័រទឹកត្រូវបានប្រើប្រាស់នៅទូទាំងប្រទេសជាជ័របិទទូក និងជាផលិតផលការពារកុំឱ្យជ្រាបទឹក[៩] ។ តាមការឆ្លើយសំភាសន៍ម្ចាស់ទូកលាបទូករបស់ខ្លួនដោយប្រើជ័រទឹក ដើម្បីកុំឱ្យជ្រាបទឹក និងការពារឈើទូកជារៀងរាល់ ៦-១២ខែម្តង អស់ជ័រប្រហែល ១០-២០គ.ក ទៅតាមទំហំទូក ។ អ្នកលក់រាយការណ៍ថា ជ័រទឹកសំរាប់បិទទូកភាគច្រើនលក់បាននៅដើមរដូវវស្សាពីខែមិថុនា ដល់ កញ្ញា ។ ម្ចាស់ទូកច្រើនចូលចិត្តប្រើជ័រទឹកគ្មានការកែច្នៃដើម្បីបិទទូក ពីព្រោះវាថ្លៃតែ ៨០០-១០០០រៀល/គ.ក (ឬ ០,២០-០,២៥ដុល្លារ/គ.ក) គឺថោកជាងជ័រច្រោះសំអាតរួច ។

[៩] ផ្អែកតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកីរិតជាតិមួយ វិជ្ជាស្ថានជាតិស្ថិតិ (២០០០) ប៉ាន់ស្មានថា មាន ២៣២.០០០គ្រួសារ (១១.១% នៃប្រជាជនសរុប) ដែលមានទូកនៅឆ្នាំ១៩៩៩ ។ អង្កេតស្រដៀងគ្នាមួយទៀតធ្វើនៅឆ្នាំ១៩៩៧ រកឃើញថាមាន ១៦០.០០០គ្រួសារ (ឬ ៨,៥% នៃប្រជាជនសរុប) ដែលមានទូក ។ គ្រួសារទាំងនោះអាចមានទូកច្រើនជាងមួយ ។ ការគន់គូរផ្អែកតាមស្ថិតិម្ចាស់ទូកឆ្នាំ១៩៩៧-១៩៩៩ និងទិន្នន័យកំណើនប្រជាជន គឺមានប្រហែល ២៥០.០០០-៣០០.០០០គ្រួសារដែលមានទូកនៅឆ្នាំ២០០២ ។

ដូចបានកត់សំគាល់ខាងលើ ការស្រាវជ្រាវរបស់ វបសអ បង្ហាញថា ជ័រទឹកដែលប្រមូលបាននៅខេត្តកំពង់ធំ ភាគច្រើនមានគុណភាពអន់ជាង ជ័រទឹកនៅតាមខេត្តផ្សេងទៀតដែលបានសិក្សា ។ ជ័រទឹកកំពង់ធំនេះហើយដែលផ្គត់ផ្គង់ទីផ្សារក្នុងស្រុកជាច្រើននៅជុំវិញបឹងទន្លេសាប និងក្នុងទូទាំងប្រទេស (តាមរយៈអ្នកបែងចែកនៅភ្នំពេញ) ។ អ្នកលក់ដុំ និងអ្នកបែងចែកបានឱ្យដឹងថា បើសិនជ័រទឹកវាខាប់ពេកមិនអាចលក់ចេញសំរាប់ធ្វើជ័របិទទូកបាន គេអាចលាយប្រេងកាតថែមដើម្បីឱ្យរាវ (ប្រេងកាតមួយភាគ លាយជាមួយជ័រទឹកពីរភាគ) ។ គេប្រើប្រេងកាតយ៉ាងសំចៃពីព្រោះវាមានតំលៃ ១៥០០រៀល/គ.ក (ឬ ប្រហែល ០,៤០ដុល្លារ/គ.ក) គឺប្រហែលជាពីរដងនៃតំលៃជ័រទឹកគុណភាពអន់ ។



ការបិទទូកកុំឱ្យជ្រាបទឹកនៅកន្លែងឡើងត្រីចុងឃ្នាសក្នុងខេត្តសៀមរាប

## ២.៣.៣. ការបិទរន្ធទូក

ដើម្បីបំពេញចន្លោះរវាងក្តារទូក ព្រមទាំងស្នាមប្រេះ ឬរន្ធតូចៗ ម្ចាស់ទូកប្រើប្រាស់ជ័រទឹកខាប់ រួមជាមួយនឹង សារធាតុកាកសំណល់ជ័រទឹក និងជ័រចុង ។ របស់ផ្សេងៗទៀត ដូចជា សសៃក្រចៅ ម្សៅ និង ជ័រទឹកគុណភាពខ្ពស់ ត្រូវបានលាយបញ្ចូល ប៉ុន្តែមិនច្រើនទេ ។ តាមធម្មតាគេយករបស់ផ្សំបាននេះទៅកំដៅលើភ្លើងប្រហែល ៣ម៉ោង ដើម្បីធ្វើឱ្យវាឡើងខ្មៅ ស្អិត ។ ជ័របិទទូកប្រភេទនេះថ្លៃប្រហែល ៧០០-៩០០រៀល/គ.ក (ឬ ០,១៨-០,២៣ដុល្លារ/គ.ក) ។



ប្រើសំភារៈដែលធ្វើពីជ័រទឹកបិទស្នាម/កន្លែងប្រេះក្នុងក្តារទូកខេត្តកំពង់ឆ្នាំង

## ២.៣.៤. ការធ្វើចន្លុះ



ចន្លុះធ្វើអំពីវត្ថុកាកសំណល់ជ័រទឹក និងស្លឹកព្រាល
គេប្រើនៅជនបទសំរាប់ដុតបំភ្លឺ និងបង្កាត់ភ្លើង

ចន្លុះ គឺជាមធ្យោបាយជាប្រពៃណីសំរាប់ដុតបំភ្លឺនៅពេលយប់របស់ប្រជាជននៅជនបទកម្ពុជាដែលគ្មានអគ្គីសនីប្រើ ជាពិសេសអ្នករស់នៅតាមតំបន់ដាច់ស្រយាល ។ នៅតាមតំបន់ទីក្រុង ជួនកាលគេប្រើចន្លុះដើម្បីបង្កាត់ភ្លើងចំអិនអាហារ ។ វបសអ បានសំភាសម្ចាស់អាជីវកម្មធ្វើចន្លុះមួយនៅស្រុករវៀង ខេត្តព្រះវិហារ ។ ចន្លុះធ្វើពីការបន្សំនៃផលិតផលកាកសំណល់ជ័រទឹក (៤0%) ទិញពីអ្នកលក់ដុំជ័រទឹកក្នុងតំលៃប្រហែល ៥0-១00រៀល/គ.ក និងស្លឹកព្រាល (៦0%) ដែលប្រមូលបានពីព្រៃ ។ ដើម្បីធ្វើចន្លុះ គេលាយស្លឹកព្រាលជាមួយនឹងផលិតផលកាកសំណល់ជ័រទឹកដែលគេដុតកំដៅ បន្ទាប់មកគេពូតចងវាជារាង ចន្លុះ ហើយព្យួរសំដិលវាឱ្យស្ងួត ។ ដោយមានជួលកម្មករ ២-៣ នាក់ផង អ្នកផលិតចន្លុះនៅស្រុករវៀង អាចផលិតបានពី ២00-៣00ចន្លុះ/ថ្ងៃ ។ ចន្លុះមួយលក់បាន ៥00រៀល (0,១៣ដុល្លារ) ហើយបានចំណេញ ២៥0-៣00រៀល/ចន្លុះ (0,0៧ដុល្លារ) ក្រោយបានកាត់ចំណាយលើកម្មករ អុស និងស្លឹកព្រាលរួចហើយ ។

# ជំពូកទី ៣

# ការកាប់ឈើគំរាមកំហែងដល់ដើមឈើផ្តល់ជ័រទឹក

មុននឹងពិភាក្សាពីរបកគំហើញនៃការស្រាវជ្រាវស្តីពីពាណិជ្ជកម្ម និងផលិតកម្មជ័រទឹកនៅកម្ពុជា (ជំពូក ៤), វាជាការសំខាន់ដែលគួរពិនិត្យទៅលើផលប៉ះពាល់ និងការគំរាមកំហែងទៅអនាគត នៃកាប់ឈើទៅលើរបរដងជ័រទឹក ។ ពិតហើយ កិច្ចប្រឹងប្រែងដើម្បីកែលំអពាណិជ្ជកម្ម និងរកទីផ្សារផលិតផលជ័រទឹក នឹងគ្មានខ្លឹមសារអ្វីទេ បើសិនបាត់បង់ប្រភពផ្គត់ផ្គង់ ។ នៅប្រទេសផ្សេងទៀតក្នុងតំបន់ ដូចជាម៉ាឡេស៊ីជាដើម ការកាប់ឈើបានប៉ះពាល់គួរកត់សំគាល់ដល់ដើមឈើផ្តល់ជ័រទឹក និងផលិតផលជ័រទឹកជាទូទៅ (Jantan *et al.* 1990, Gianno 1986, Gianno and Kochummen 1981) ។ ការកាប់ឈើយ៉ាងច្រើននៅកម្ពុជា ក៏អាចធ្វើឱ្យមានសេនារីយ៉ូស្រដៀងគ្នាមួយដែរ ។

ដើមឈើផ្តល់ជ័រទឹក មានទាំងពូជឈើទាល (dipterocarpus) ដ៏សំបូរនេះផង គឺជាប្រភពឈើដែលមានលក្ខណៈទាក់ទាញខាងពាណិជ្ជកម្មចំពោះសម្បទានិកព្រៃឈើ និងអ្នកកាប់ឈើផ្សេងទៀត ។ មកទល់ពេលនេះ ដើមឈើពីរប្រភេទដែលល្បីជាងគេសំរាប់ផលិតកម្មជ័ររាវ និងជ័ររឹង (ឈើទាល និងដើមជ័រចុង) គឺហាក់ដូចបានក្លាយជា "ប្រភេទឈើសំខាន់សំរាប់ផលិតកម្មឈើហ៊ុប" ពីរមុខរបស់នាយកដ្ឋានរុក្ខាប្រមាញ់ (នាយកដ្ឋានរុក្ខាប្រមាញ់ ២០០៣) ។ ឈើបានមកពីប្រភេទដើមឈើផ្តល់ជ័រទឹក ត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់គុណភាពលេខ២ មិនមែនក្នុងឈើប្រណិត ឬគុណភាពលេខ១ទេ ដោយសារសាច់ឈើមានជាតិប្រេង និងមានជ័រច្រើន ។ ប៉ុន្តែ ឈើដែលកាប់ច្រើនជាងគេនៅកម្ពុជា គឺជាឈើនៅក្នុងចំណាត់ថ្នាក់លេខ២នេះឯង (នាយកដ្ឋានរុក្ខាប្រមាញ់ ២០០៣) ។

ការកាប់ដើមឈើផ្តល់ជ័រទឹក ត្រូវបានហាមឃាត់ដោយច្បាប់កម្ពុជា ។ ការកាប់យកដើមឈើផ្តល់ជ័រទឹក ដំបូងត្រូវបានហាមឃាត់ដោយ វិធានអនុវត្តន៍ព្រៃឈើ (ក្រឹត្យលេខ៣៥ ចុះថ្ងៃ ២៥ មិថុនា ១៩៩៨) ជាច្បាប់ចំបងគ្រប់គ្រងវិស័យព្រៃឈើនៅមុនការអនុម័ត ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ នាពេលថ្មីៗនេះ ។ មាត្រា ១៧ឆ នៃច្បាប់ឆ្នាំ១៩៩៨ ចែងថា "ត្រូវបានហាមឃាត់ ....ការកាប់ដើមឈើដែលប្រជាជនប្រមូលយកជ័រទឹក..." ។ ប៉ុន្តែ មាត្រាទី១៨ នៃច្បាប់ បានទុកសេចក្តីសំរេចជាក់ស្តែងអំពីការ កាប់ដើមឈើផ្តល់ជ័រទឹក ឱ្យក្រសួងកសិកម្ម ដោយបានចែងថា "...ការកាប់ដើមឈើផ្តល់ជ័រទឹក ត្រូវបានអនុញ្ញាតតែក្នុងករណីមានការយល់ព្រម ពីក្រសួងកសិកម្ម" ។

ដើម្បីពង្រឹងកិច្ចប្រឹងប្រែងបញ្ឈប់ការកាប់ដើមឈើផ្តល់ជ័រទឹក, "សារាចរណែនាំ" មួយចេញដោយនាយករដ្ឋមន្ត្រី បានអំពាវនាវឱ្យផ្អាកការកាប់ដើមឈើផ្តល់ជ័រទឹកនៅខែមេសា ២០០១ (លិខិតលេខ ៣៣ Tor/2001, ចុះថ្ងៃ៨ មេសា ២០០១) ។ បទបញ្ជាបានយោងដល់បណ្តឹងរបស់ប្រជាជនក្នុងមូលដ្ឋាន ស្តីពីការកាប់ដើមឈើផ្តល់ជ័រទឹក ដោយក្រុមហ៊ុនសម្បទាន ។ ប៉ុន្តែ បទបញ្ជានេះមានខ្លឹមសារមិនច្បាស់លាស់វិញ ដោយសារលិខិតមួយចេញដោយនាយកនៃនាយកដ្ឋានរុក្ខាប្រមាញ់នៅ ២-៣ថ្ងៃបន្ទាប់ពីនោះ ។ លិខិតនោះបានបញ្ជាក់ថា ការផ្អាកកាប់ដើមឈើផ្តល់ជ័រទឹកមានលក្ខណៈបណ្តោះអាសន្ន ហើយតំរូវឱ្យសម្បទានិកធ្វើការសិក្សាពីលទ្ធភាពមានការងារផ្សេងទៀតសំរាប់អ្នកដងជ័រ ហើយបានបញ្ចប់ដោយបញ្ជាក់ថា "ការអនុញ្ញាតឱ្យ

កាប់ដើមឈើផ្តល់ជ័រទឹកជាបន្តទៀត នឹងអាចលើកយកមកពិភាក្សាបាន ក្រោយពេលដែលអ្នកបានបង្ហើយ និងបានបង្ហាញលទ្ធផលនៃការសិក្សាខាងលើ” លិខិតលេខ ៧៤០ Rbro. KKB, ២៦ មេសា ២០០១) (សេចក្តីបញ្ជាក់មានបន្ថែម) ។

តាមការអនុម័ត ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ការកាប់ដើមឈើផ្តល់ជ័រទឹកត្រូវបានហាមឃាត់ម្តងទៀតតាមមាត្រា២៩ ។

**មាត្រាទី២៩:**

ក. លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមូលហេតុជាអាទិ៍ លក្ខខណ្ឌអាកាសធាតុមិនអំណោយផល ឈើចំណីផ្លូវដែលត្រូវសាងសង់ ដោយមានការអនុញ្ញាត ឬលក្ខខណ្ឌឧបទ្ទវហេតុផ្សេងៗទៀត ដែលស្នើឡើង ដោយរដ្ឋបាលព្រៃឈើ ការប្រមូលផល អនុផលព្រៃឈើដូចខាងក្រោមក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានហាមឃាត់:

១. ប្រភពឈើជាប់ក្នុងលំដាប់ថ្នាក់ ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ

២. ប្រភេទឈើដែលមានដោយកម្រ ។

៣. ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី ។

៤. ដើមឈើផ្តល់ជ័រមានតម្លៃ ។

ខ. ផល អនុផលព្រៃឈើដែលហាមឃាត់ដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា២៩ មានសេចក្តីចែង ហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹក ដែលច្បាស់លាស់ជាងបទប្បញ្ញត្តិមុនៗទាំងអស់ ។ បើសិន ដើមឈើស្ថិតក្នុងប្រភេទណាមួយដែលផ្តល់ជ័រទឹក គេមិនត្រូវកាប់វាទេ ។ សព្វថ្ងៃមានការឯកភាពគ្នាច្រើនហើយពីប្រភេទដើមឈើដែលគេចោះយកជ័រជាទូទៅបំផុត (ឈើទាលៈ *dipterocarpus*) ប៉ុន្តែនៅមានដើមឈើច្រើនប្រភេទទៀតដែលគេប្រមូលយកជ័រដែរ ។ ដូច្នេះគួរលើកទឹកចិត្តឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បញ្ជាក់ឱ្យបានច្បាស់ និងយ៉ាងឆាប់តាមអាចធ្វើបាននូវគ្រប់ ប្រភេទឈើដែលមិនអាចកាប់បាន (តាមរយៈ ប្រកាស ដូចមានចែងក្នុងចំណុច ខ នៃមាត្រានេះ) ដើម្បីចៀសវាងការភ័ន្តច្រឡំជាយថាហេតុ ។ ការអនុវត្តន៍ដូច្នេះដើម្បីទប់ស្កាត់ការកាប់ដើមឈើផ្តល់ជ័រទឹក នឹងបានស្របគ្នាជាមួយនឹងខ្លឹមសារសុន្ទរកថាគន្លឹះរបស់សម្តេចនាយករដ្ឋមន្ត្រី ទៅកាន់ថ្នាក់ដឹកនាំខេត្ត-ក្រុង ស្តីពីការលើកកំពស់ជីវភាពប្រជាជននៅជនបទ (សូមអានប្រអប់) ។

ទោះបីជាខុសច្បាប់ក្តី ក៏មានសេចក្តីរាយការណ៍ពីការកាប់ដើមឈើផ្តល់ជ័រទឹកជាច្រើនករណីក្នុងរយៈពេល ២-៣ឆ្នាំកន្លងមកនេះ ។ ឧទាហរណ៍ នៅខេត្តមណ្ឌលគិរី Evans *et al.* 2003 បានរកឃើញថា មាន ៣ភូមិបានបាត់បង់ដើមឈើចោះយកជ័រទឹកជាង ៣.០០០ដើម ឬប្រហែល ២០-៣០% នៃដើមឈើផ្តល់ជ័រទឹកដែលគេកំពុងយកជ័រ ដោយសារការកាប់ឈើនៅក្នុងព្រៃសម្បទានរបស់ក្រុមហ៊ុនអន្តរជាតិ Samling ។ ការកាប់ឈើនេះបានកើតមានភាគច្រើននៅចន្លោះឆ្នាំ១៩៩៨-៩៩ ។ នៅខេត្តសៀមរាប និងឧត្តរមានជ័យ អ្នកចាត់ចែងការក្រុមហ៊ុនព្រៃសម្បទាន Samrong ប៉ាន់ស្មានថា ដើមឈើផ្តល់ជ័រទឹកតំណាងឱ្យ ៨០%នៃការប្រមូលផលឈើរបស់ក្រុមហ៊ុននៅឆ្នាំ២០០១ ក្នុងនេះប្រហែល ២០% ជាដើមឈើកំពុងជងជ័រទឹកយ៉ាងសកម្ម (Globle Witness 2002) ។ ថ្មីៗជាងនេះទៀត មានការរាយការណ៍ជាច្រើនពីការកាប់ដើមឈើផ្តល់ជ័រទឹកនៅខាងក្នុង និងខាងក្រៅក្រុមហ៊ុនចំការកៅស៊ូ Tumring នៅខេត្តកំពង់ធំ (NGO forum *et al.* 2002, BBC News 2002, The Economist 2003, The Cambidia Daily 2003) ។

**ដកស្រង់ពីសុន្ទរកថាគន្លឹះរបស់**
**សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា**
**"រដ្ឋាភិបាលសេដ្ឋកិច្ច និងយុទ្ធសាស្ត្រលើកកំពស់ជីវភាពនៅជនបទ"**

យើងប្តូរផ្តាច់តាំងពីមុនបង្កើតរដ្ឋាភិបាលអាណត្តិទី២ ។ យើងប្រកាស់អំពីកំណែទំរង់ព្រៃឈើ យើងត្រូវបន្តរហូតមកដល់ពេលនេះ ។ ក៏ប៉ុន្តែមិនត្រូវភ្លេចទេថា ព្រៃឈើមានសត្រូវច្រើនណាស់ អ្នកឈ្មួញកាប់ឈើ ឬអ្នករកស៊ីឈើខុសច្បាប់ ក៏កាប់ឈើ អ្នកត្រូវការដីដើម្បីធ្វើចំការធ្វើស្រែក៏កាប់ឈើ ភ្លើងឆេះព្រៃក៏ឆេះឈើ ។ ដូច្នេះ វាមានសត្រូវច្រើនណាស់ ។ ជាមួយគ្នានេះ សហគមន៍ជនបទ តាមអនុសាសន៍ដែលលើកឡើងតាមការកត់សំគាល់របស់អ្នកស្រី អេវ៉ា បានលើកឡើងថា គឺពាក់ព័ន្ធជាមួយនឹងបញ្ហាជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទជាក់លាក់ណាស់លើចំណុចនេះ ។ ដូច្នេះ ហើយបានជានៅក្នុងការប្រជុំពិគ្រោះយោបល់ រវាងរាជរដ្ឋាភិបាលជាមួយសហគមន៍អ្នកផ្តល់ជំនួយកាលពីខែមករា ខ្ញុំបានផ្តល់អនុសាសន៍ជូនក្រសួងកសិកម្ម ហើយឱ្យផ្តល់អាទិភាពជាពិសេស ត្រូវចុះទៅពិនិត្យដើម្បីនឹងរៀបរយនូវផែនទីឡើងវិញសំរាប់ព្រៃសម្បទាន ។ ដីធ្លីមួយចំនួនត្រូវផ្តល់អាទិភាពឱ្យប្រជាពលរដ្ឋជាមុន ។ មួយផ្នែកទៀត ព្រៃឈើ ដើមឈើ មានចែងក្នុងច្បាប់ ហើយទាក់ទងនឹងព្រៃអ្នកតាក៏ប៉ុន្តែខ្ញុំបានផ្តល់អនុសាសន៍យ៉ាងជាក់លាក់នៅពេលនោះថា ព្រៃដែលប្រជាជនចោះយកជ័រទឹក គឺមិនអនុញ្ញាតឱ្យកាប់តែម្តងទៅជាការល្អជាង ។ ឥលូវ ឧទាហរណ៍ មួយភូមិនេះ គាត់មាន ៥.០០០ដើម យើងទុក ៥០០០ដើមនោះទៅ ។ បើក្រុមហ៊ុនព្រៃសម្បទាន គេធ្វើសកម្មភាពឡើងវិញ កុំប៉ះពាល់ ៥.០០០ ដើមនោះ ទុកវា ២០០ឆ្នាំទៀត ៥០០ឆ្នាំទៀត ១.០០០ឆ្នាំទៀត ក៏វាមិនផ្អូមដែរ គឺវាមិនផ្អូមទេ កុំទៅព្រួយ ។ ប៉ុន្តែអ្វីដែលជាកង្វល់នៅពេលដែលយើងដោះស្រាយផ្ទេរការងារ និងបង្កើតការងារឱ្យគាត់មិនបានទេ តែយើងកាប់ដើមឈើទាំងនេះ គាត់នឹងទៅច្បោះ ទៅកាប់ដើមដទៃទៀត ។ ដូច្នេះ យកល្អទុកឱ្យគាត់តែម្តងទៅគឺដែនព្រៃសម្បទាននេះ ព្រោះធម្មតាខាងផ្នែករុក្ខាប្រមាញ់ គឺទាល់តែគេបោះផ្លាកឱ្យកាប់ ទើបអាចកាប់បាន ។ ដូច្នេះខាងរុក្ខាប្រមាញ់កុំទៅបោះត្រានោះឱ្យក្រុមហ៊ុនកាប់តែម្តងទៅ ទុកទៅ ១០០ ២០០ឆ្នាំ ១.០០០ ២.០០០ឆ្នាំ ក៏មិនផ្អូមដែរ ។ វានៅតែជាធនធានធម្មជាតិរបស់យើង។ ។ ព្រោះថាភូមិនៅតាមជនបទ គាត់ពឹងផ្អែកទៅលើឈើនោះ ។

ប្រភព: វបសអ (២០០៣) ។

ប្រភេទដើមឈើដែលបានកាប់យក មានចុះកត់ត្រានៅក្នុង "បញ្ជី" របស់នាយកដ្ឋានរុក្ខាប្រមាញ់ និងរបស់ក្រុមហ៊ុនសម្បទាន ។ កំណត់ត្រាក្នុងបញ្ជីបញ្ជាក់ថា ប្រភេទដើមឈើផ្តល់ជ័រទឹក គឺជាប្រភពឈើហ៊ុបដ៏សំខាន់សំរាប់ក្រុមហ៊ុនព្រៃសម្បទាន ។ យោងតាមស្ថិតិរកបានលើ ៦ក្រុមហ៊ុន ដើមឈើសឹងតែទាំងអស់ដែលបានកាប់យកនៅឆ្នាំ២០០១ ស្ថិតក្នុងប្រភេទ Dipterocorpaceae ក្នុងនេះដើមឈើទាលមានប្រហែល ៣០-៩០% ទៅតាមក្រុមហ៊ុនខុស។គ្នា (តារាង ៣.១) ។ លើសពីនេះទៀត ដើមជ័រចុងដែលជាប្រភេទឈើចំបងផ្តល់ជ័ររឹង ព្រមទាំងប្រភេទឈើផ្សេង។ទៀតដែលគេអាចយកជ័រ (ដូចជា ត្រាច) ក៏ត្រូវបានកាប់យកដែរ ។ ស្ថិតិកាប់ឈើចំពោះក្រុមហ៊ុនព្រៃសម្បទានផ្សេងទៀត មិនអាចរកបានទេ ។

ពិនិត្យតាមសារៈសំខាន់នៃដើមឈើផ្តល់ជ័រទឹកចំពោះការកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម បើសិនដាក់ពង្រឹងការហាមឃាត់ស្តីពីការកាប់ដើមឈើផ្តល់ជ័រទឹក ក្រុមហ៊ុនសម្បទានមួយចំនួនប្រហែលមិនអាចរស់រានបានទេ (ឬច្បាស់ជាមិនចំណេញច្រើនដូចមុនទេ) ។ ជាក់ស្តែង សម្បទានិកបានត្អូញត្អែររួចហើយពីការមិនអាចរកចំណេញបាន និងបន្ទុកចំណាយបន្ថែមផ្សេង។ ទាក់ទិននឹងការចាប់អនុវត្តន៍ ការគ្រប់គ្រងសម្បទានព្រៃឈើប្រកបដោយចីរភាព (KPMG 2001) ។ ជាអកុសល នៅតាមតំបន់ព្រៃ

ឈើមួយចំនួន ហាក់ដូចមានច្រកតិចតួចណាស់ដើម្បីរកបានដំណោះស្រាយ "ឈ្នះ-ឈ្នះ" ពោលគឺ ការថែរក្សាចំណូលបានមកពីការជងជ័រ និង ការកាប់ឈើធ្វើពាណិជ្ជកម្ម ។

**តារាង ៣.១. ប្រភេទឈើបានកាប់យកដោយ ៦ ក្រុមហ៊ុនព្រៃសម្បទាន នៅឆ្នាំ២០០១**

| ឈ្មោះប្រភេទឈើបានកាប់យក | | ក្រុមហ៊ុនសម្បទាន ទីតាំងសម្បទាន ប្រភេទឈើបានកាប់យក គិតជាភាគរយនៃប្រភេទឈើកាប់យកសរុបនៅឆ្នាំ២០០១ | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះប្រភេទឈើជាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រនៃអំបូរ និង ប្រភេទឈើ | ភាពីម៉ិច Fuchan (រតនគិរី ស្ទឹងត្រែង) | ភាពីម៉ិច Fuchan ថា ឡាបរិវ៉ាត់ (ស្ទឹងត្រែង) | មៀង លីហេង (កំពង់ធំ ព្រះវិហារ កំពង់ចាម) | Samrong Wood (សៀមរាប) | ធនធាន Timas (កំពង់ចាម ព្រះវិហារ ក្រចេះ) | ក្រុមហ៊ុនក្ការបន្ទះ Cherndar |
| ឈើទាល | *Dipterocorpaceae – Dipterocarpus Alatus, Costatus, Dyori, Jourdani* | 80.0% | 89.3% | 78.2% | 30.7% | 45.1% | 27.7% |
| ផ្ចៀក | *Dipterocorpaceae – Anisoptera Glabra* | 5.4% | 8.0% | 18.5 | 58.1% | 51.3% | 59.8% |
| ជ័រចុង | *Dipterocorpaceae – Shorea Vulgaris* | 8.0% | - | 1.3% | - | 0.9% | 0.3% |
| ត្រាច | *Dipterocorpaceae – Dip- terocarpus Intricatus* | 3.1% | - | - | 0.8% | - | - |
| គគី | *Dipterocorpaceae – Hopea Helferi, Odorata, Ferrea* | - | - | - | 4.3% | 0.1% | 9.5% |
| ឈើផ្សេងទៀត | ពូជឈើ៤ប្រភេទផ្សេងទៀត | 3.2% | 2.5% | 1.8% | 5.9% | 2.1% | 2.7% |

ប្រភព: ប្រភេទឈើកាប់យកដោយសម្បទានិកនៅឆ្នាំ២០០១, នាយកដ្ឋានរុក្ខាប្រមាញ់- បញ្ជីកាប់ឈើរបស់ ក្រុមហ៊ុន តាមរបាយការណ៍របស់អង្គការសាក្សីអន្តរជាតិ *(Global Witness, 2003)* ។

ដោយមានការលើកទឹកចិត្តខាងហិរញ្ញវត្ថុ (និងយោងតាមភស្តុតាងនៃការអនុវត្តន៍កន្លងមក) បើសិនមានការកាប់ឈើជាលក្ខណៈពាណិជ្ជកម្មនៅតាមតំបន់ព្រៃឈើដែលមានដើមឈើផ្តល់ជ័រទឹក គេរំពឹងថានឹងមានការកាប់ដើមឈើផ្តល់ជ័រទឹក។ បច្ចុប្បន្ននេះ ផែនការគ្រប់គ្រងព្រៃសម្បទានដែលកំពុងពិនិត្យមើលឡើងវិញ មានផ្តល់ពត៌មានតិចតួចណាស់ពីដើមឈើផ្តល់ជ័រទឹកនៅក្នុងតំបន់ព្រៃសម្បទាន ។ ដើម្បីជួយទ្រទ្រង់ឱ្យមានការគ្រប់គ្រងព្រៃឈើយ៉ាងល្អ ផែនការទាំងនេះគួរមានការកែលំអដោយមានចុះពត៌មានជាប់ទាក់ទិន នឹងដើមឈើផ្តល់ជ័រទឹកដូចជា ទិន្នន័យសារពើភ័ណ្ឌ ការវាយតំលៃពីផលប៉ះពាល់ខាងបរិស្ថាននិងសង្គមកិច្ច និងយុទ្ធសាស្ត្រគ្រប់គ្រងនានា ។ ដើម្បីឱ្យបានទូលំទូលាយថែមទៀត ត្រូវមានសេចក្តីសំរេចគ្រប់គ្រងព្រៃឈើច្បាស់លាស់មួយថា តើការកាប់ឈើធ្វើពាណិជ្ជកម្ម នឹងត្រូវអនុញ្ញាតក្នុងរូបភាពណាមួយ នៅក្នុងតំបន់មានដើមឈើផ្តល់ជ័រទឹកឬយ៉ាងណា ។ បើគ្មានអន្តរាគមន៍យ៉ាងដូច្នេះទេ ដើមឈើផ្តល់ជ័រទឹក ប្រហែលមានកាប់បន្តទៀត ទំនាស់លើដើមឈើផ្តល់ជ័រទឹកនឹងកើនឡើង ប្រជាជននៅជនបទកម្ពុជារាប់ពាន់នាក់ដែលពឹងផ្អែកលើការជងជ័រទឹក អាចបាត់បង់ប្រភពចំណូលដ៏សំខាន់បំផុតមួយ ហើយរឿងនេះវាផ្ទុយគ្នាយ៉ាងច្បាស់នឹងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ជាតិ ។

# ជំពូកទី ៤

# ផលិតកម្មជ័រទឹក និងរកទីផ្សារ

ការដងជ័រទឹកមានធ្វើក្នុងតំបន់ព្រៃឈើភាគច្រើននៅកម្ពុជា ហើយមានច្រើនបំផុតនៅភាគឧត្តរ និងឦសាន គឺមានខេត្តកំពង់ធំ ព្រះវិហារ សៀមរាប ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និង រតនគិរី ។ សកម្មភាពយកជ័រក៏មានធ្វើដែរក្នុងខេត្តកោះកុងនៅភាគខាងលិច និងខេត្តឧត្តរមានជ័យនៅភាគពាយព្យ ព្រមទាំងក្នុងតំបន់ព្រៃដាច់ស្រយាលនៃខេត្តមួយចំនួនផ្សេងទៀត (Cock *et al.* forthcoming)។ ចេញពីតំបន់ព្រៃ គេតែងដឹកជញ្ជូនជ័រទឹកឆ្ងាយៗ ទៅទីផ្សារក្នុងស្រុកនៅជុំវិញបឹងទន្លេសាប ទៅវាលទំនាបទន្លេមេគង្គខាងត្បូង និងនាំចេញទៅ វៀតណាម ថៃ និងឡាវ (ដែលគេរាយការណ៍ថានាំចេញបន្តទៅថៃ) (Enfield *et al.* 1998, Nicholson 1997) ។ ទោះជាទំហំសរុបនៃផលិតកម្មជ័រទឹកកម្ពុជា ពិបាកប៉ាន់ស្មានជាក់លាក់ក្តី ក៏ផ្អែកលើការស្រាវជ្រាវរបស់ វបសអ និង លទ្ធផលបានពីការសិក្សាផ្សេងៗទៀត គេឃើញថា ជ័រទឹកប្រមូលប្រចាំឆ្នាំបានប្រហែល ២០.០០០តោន ហើយសកម្មភាពនេះគឺជាប្រភពចំណូលសំរាប់ប្រជាជនកម្ពុជានៅតាមជនបទប្រហែល ១០០.០០០នាក់[១០] ។

ក្នុងជ័រទឹកប្រមូលបាននៅកម្ពុជា ២០.០០០ តោន/ឆ្នាំ នេះមានជ័រទឹក ៣.០០០-៤.០០០តោន បានលក់ដូរនៅក្នុងស្រុក ហើយជ័រទឹកនៅសល់ (ប្រហែល១៦.០០០-១៧.០០០តោន) បាននាំចេញភាគច្រើនទៅវៀតណាម[១១] ។ តំរូវការជ័រទឹកក្នុងស្រុកកើតចេញជាសំខាន់ពីតំរូវការរបស់ប្រជាជនកម្ពុជាជាង ២៥០.០០០នាក់ ដើម្បីបិទទូកកុំឱ្យជ្រាបទឹកជារៀងរាល់ឆ្នាំ ។ តំរូវការជ័រទឹកនៅវៀតណាម ហាក់កើតចេញពីតំរូវការនៃកម្មន្តសាលផលិតថ្នាំលាបនិងវ៉ែរនី តែ វបសអ មិនអាចបញ្ជាក់ពីការប្រើប្រាស់ចំបងនៃជ័រទឹកនាំចេញនេះទេ ។ តំលៃទីផ្សារ/ការនាំចេញប្រចាំឆ្នាំនៃផលិតកម្មជ័រទឹកនៅកម្ពុជា គឺប្រហែល៦លានដុល្លារ[១២] ។

ក្នុងពាណិជ្ជកម្មជ័រទឹក គឺមានការលក់ជ័រទឹកពីអ្នកដងជ័រ ទៅឱ្យខ្សែរយៈទីផ្សារដែលមានឈ្មួញ អ្នកលក់ដុំ អ្នកដឹកជញ្ជូន

---

[១០] ទោះជាកន្លងមកមិនទាន់មានធ្វើអង្កេតជាផ្លូវការពីតំបន់ដងជ័រទឹកក្នុងទូទាំងកម្ពុជា ដើម្បីជួយឱ្យមានការប៉ាន់ស្មានកាន់តែត្រឹមត្រូវពីផលិតកម្មជ័រទឹកក្តី ក៏មានប្រភពពត៌មានផ្សេងៗមួយចំនួនបានអនុញ្ញាតឱ្យធ្វើការប៉ាន់ស្មានដោយចៀលៗអំពីទំហំផលិតកម្ម ។ ប្រភពទាំងនេះរួមមាន: ក) ទិន្នន័យផលិតកម្មដែល វបសអ ប្រមូលបានសំរាប់ ៤ផ្លូវពាណិជ្ជកម្ម (ប្រហែល ៥.០០០តោន/ឆ្នាំ), ខ) ពត៌មានពីរឿងនេះ និងពីតំបន់ផលិតកម្មជ័រទឹកចំបងៗផ្សេងទៀតនៅកម្ពុជា (Cock *et al.* forthcoming), គ) ទិន្នន័យស្តីពីតំបន់ និងគ្រួសារដងជ័រទឹកដែល វបសអ ប្រមូលបានពីតំណាងខេត្តទាំង៩ នៃបណ្តាញព្រៃឈើ(ដែលជួយឧបត្ថម្ភដោយ NGO Forum) និង ឃ) ពត៌មានស្តីពីទិន្នផលជ័រទឹកជាមធ្យមក្នុងឈើមួយដើម និងចំនួនជាតួយ៉ាងនៃដើមឈើដែលគ្រួសារនិមួយៗដងយកជ័រ និងដែលការសិក្សានេះ និងការសិក្សាផ្សេងៗទៀត ប្រមូលបាន (Evans *et al.* 2003, Cock *et al.* forthcoming) ។

[១១] ការប៉ាន់ស្មានពីតំរូវការក្នុងស្រុក ផ្អែកលើតំរូវការជ័រទឹកប្រចាំឆ្នាំនៅកម្ពុជាសំរាប់យកទៅបិទទូកកុំឱ្យជ្រាបទឹក ។ តួលេខនេះកសាងឡើងដោយប្រើទិន្នន័យស្តីពីចំនួនគ្រួសារដែលមានទូក(២៥០.០០០-៣០០.០០០គ្រួសារ), ចំនួនជ័រទឹកជាមធ្យមដែលត្រូវការសំរាប់បិទ ទូកតូចមួយ(១០-១៥គ.ក) និង ទូកមធ្យមមួយ(២០គ.ក) រយៈពេលជាមធ្យមដែលម្ចាស់ទូកត្រូវបិទទូកឡើងវិញ (៦-១២ខែ) ។ តួលេខប៉ាន់ស្មាននៃជ័រទឹកនាំចេញ ផ្អែកលើគំលាតរវាង ទំហំប៉ាន់ស្មាននៃការប្រើប្រាស់ក្នុងស្រុកប្រចាំឆ្នាំ និងផលិតកម្មសរុប ព្រមទាំងពត៌មានខ្លីៗបានពីអ្នកនាំចេញ និងអ្នកដឹកជញ្ជូនជ័រទឹក ។

[១២] ប៉ាន់ស្មានឡើងដោយផ្អែកលើ ថ្លៃនាំចេញជាមធ្យមគុណនឹងចំនួនជ័រទឹកនាំចេញ រួចបូកនឹង ថ្លៃក្នុងស្រុកជាមធ្យមគុណនឹងចំនួនជ័រទឹកប្រើប្រាស់ក្នុងស្រុក ។

អ្នកលក់រាយក្នុងស្រុក និងអ្នកនាំចេញ ។ ការធ្វើផែនទីរចនាសម្ព័ន្ធទីផ្សារដោយបង្ហាញពីរូបភាពដ៏ស្មុគស្មាញទាំងអស់ គឺជាបញ្ហាប្រឈមមួយយ៉ាងធំ ពីព្រោះនៅកម្ពុជាមានតំបន់ព្រៃជាច្រើនដែលផ្តល់ប្រភពជ័រទឹក អ្នកដងជ័ររាប់ពាន់នាក់ ពាណិជ្ជករ អ្នកធ្វើសកម្មភាពផ្សេងទៀតក្នុងពាណិជ្ជកម្មជ័រទឹក, និងផ្លូវផ្សេងៗជាច្រើនសំរាប់ពាណិជ្ជកម្ម និងការនាំចេញជ័រទឹក ។ ប៉ុន្តែផ្អែកលើផ្លូវពាណិជ្ជកម្មជ័រទឹកទាំងបួនដែលបានសិក្សា គេអាចរកឃើញនូវរចនាសម្ព័ន្ធទីផ្សារជាទូទៅមួយ (ក្រាហ្វិក ៤.១)។ ការពិពណ៌នាលំអិតពីតួអង្គនិមួយៗក្នុងរចនាសម្ព័ន្ធទីផ្សារនេះមានបង្ហាញនៅខាងក្រោម ដោយមានពត៌មានជាក់លាក់ស្តីពីវិធីរកទីផ្សារជ័រទឹក សំរាប់ផ្លូវពាណិជ្ជកម្មនិមួយៗ ។

ក្រាហ្វិក ៤.១. រចនាសម្ព័ន្ធទីផ្សារជាទូទៅសំរាប់ពាណិជ្ជកម្មជ័រទឹកនៅកម្ពុជា




អ្នកដងជ័រ ធ្វើដំណើរទៅតំបន់ព្រៃដើម្បីប្រមូលជ័រទឹកពីដើមឈើរបស់ខ្លួនជារៀងរាល់ ៥-១៥ថ្ងៃ ។ ក្នុងដំណើរមួយជើង គេអាចប្រមូលបានពី ១-៣ធុង (៣០-៩០លីត្រ) ដែលគេលក់ទៅឱ្យឈ្មួញ នៅឯព្រៃតែម្តង ឬនៅឯភូមិរបស់អ្នកដងជ័រ ឬនៅតាមផ្លូវ ។ ដើម្បីធានាឱ្យអ្នកដងជ័រលក់ជ័រទាំងអស់មកឱ្យខ្លួន អ្នកលក់ដុំតែងផ្តល់ឥណទានទៅឱ្យអ្នកដងជ័រ ជាស្រូវ ជាគ្រឿងហូបផ្សេងទៀត និងជាសាច់ប្រាក់តែម្តង ។ គេផ្តល់ឥណទានដោយផ្ទាល់ទៅឱ្យអ្នកដងជ័រ ឬតាមរយៈពាណិជ្ជករដែលគេទុកចិត្ត ។ គេក៏អាចផ្តល់ជាឧបករណ៍សំរាប់ដងជ័រ និងប្រមូលជ័រទុក ដាយឥតគិតថ្លៃដែរ ។ ជាទូទៅអ្នកដងជ័រច្រើនខ្ចីឥណទាននៅរដូវវស្សា នៅពេលស្ងួង និងមុនពេលច្រូតកាត់បន្តិច ។ គេសងកំចីនោះវិញក្នុងរយៈពេលខ្លីត្រឹម៧-១០ថ្ងៃ ឬក្នុងរយៈពេលវែងដល់ទៅ ៦ខែ ដោយគ្មានបង់ការប្រាក់ ។ ប៉ុន្តែនៅខេត្តព្រះវិហារ គេបានបញ្ចុះថ្លៃទិញជ័រអស់ ១០០-១៥០រៀល/គ.ក ចំពោះអ្នកដងជ័រដែលនៅមានជំពាក់បំណុលមិនទាន់សង ។ នៅខេត្តមណ្ឌលគិរី ក៏វិតថ្លៃគឺដូចគ្នា ទាំងសំរាប់អ្នកដងជ័រមានខ្ចីឥណទាន ឬទាំងសំរាប់អ្នកគ្មានខ្ចីសោះ ។ រឿងនេះផ្តល់គំនិតថា ការផ្តល់ឥណទានគឺគ្រាន់តែជាឧបករណ៍មួយសំរាប់ធានា ឱ្យការផ្គត់ផ្គង់ជ័រទឹកមានស្ថិរភាពប៉ុណ្ណោះ ។

ពាណិជ្ជករ ទិញជ័រទឹកពីអ្នកដងជ័រនៅឯព្រៃ ឬនៅតាមភូមិរបស់អ្នកដងជ័រ ដែលភូមិខ្លះអាចនៅឆ្ងាយដាច់ស្រយាល ។ ដោយធ្វើដំណើរតាមម៉ូតូ ពាណិជ្ជករអាចដឹកជ័រទឹកបានប្រហែល ២០០គ.ក (៦-៧ធុង)[១៣] ។ ពាណិជ្ជករខ្លះប្រើរទេះគោដែលអាចដឹកជ័រទឹកបានប្រហែល ៣០០-៤០០គ.ក ។ បន្ទាប់មកពាណិជ្ជករដឹកជ័រទឹក ទៅទីប្រជុំជន ឬតំបន់ពាក់កណ្តាលទីក្រុងដើម្បីលក់ទៅឱ្យអ្នកលក់ដុំ ។ ពាណិជ្ជករអាចធ្វើប្រតិបត្តិការដោយឯករាជ្យពីអ្នកលក់ដុំ (ដូចនៅមណ្ឌលគិរី) ឬដោយមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកលក់ដុំណាម្នាក់ (ដូចនៅព្រះវិហារ) ។

អ្នកលក់ដុំ ទិញជ័រពីពាណិជ្ជករ និងអ្នកដងជ័រ, ធ្វើការច្រោះសំអាតក្នុងករណីខ្លះ, និងស្តុកទុកឱ្យបានគ្រប់ចំនួនសំរាប់ធ្វើការដឹកជញ្ជូន (ជាទូទៅប្រហែល ១-២តោន) ។ ដូចបានកត់សំគាល់ខាងលើ អ្នកលក់ដុំអាចផ្តល់ឥណទានទៅឱ្យពាណិជ្ជករ និងអ្នកដងជ័រ ដើម្បីធានាឱ្យមានការផ្គត់ផ្គង់ជ័រទឹក ។ អ្នកលក់ដុំបានប្រាប់ថា គេមិនពឹងផ្អែក

[១៣] សំរាប់ផលិតផលជ័រទឹកនៅកម្ពុជា ជាទូទៅអ្នកដងជ័រវាស់ចំនួនជ័រទឹកតាម "កាន" គឺធុងប្លាស្ទិកដែលអាចដាក់បាន ៣០លីត្រ ។ ប៉ុន្តែពាណិជករ អ្នកលក់ដុំ និងអ្នកនាំចេញទាំងអស់គ្នា បានវាស់ចំនួនជ័រទឹកដោយថ្លឹង (គ.ក និងតោន) ជាជាងគិតជាចំណុះ ។

លើប្រភពឥណទានពីខាងក្រៅទេ មុខជំនួញរបស់គេពឹងលើហិរញ្ញវត្ថុផ្ទាល់ខ្លួន ។ ចំពោះជ័រទឹកសំរាប់នាំចេញជាទូទៅអ្នកលក់ដុំច្រោះសំអាតវាតាមបច្ចេកទេសសាមញ្ញដើម្បីកែលំអគុណភាពជ័រទឹក ។ ជ័រទឹកសំរាប់ទីផ្សារក្នុងស្រុក អាចមានការច្រោះសំអាត ឬលក់ជាផលិតផលជ័រនៅទៅឱ្យអ្នកបែងចែក និងអ្នកលក់រាយដែលអាចយកវាទៅកែច្នៃ ទៅតាមគុណភាពជ័រទឹក និងតំរូវការរបស់អតិថិជន ។

អ្នកដឹកជញ្ជូន ដឹកជ័រទឹកពីអ្នកលក់ដុំទៅឱ្យ អ្នកនាំចេញ ឬអ្នកលក់ដុំ/អ្នកលក់រាយក្នុងស្រុក ដោយប្រើរថយន្តធុនធ្ងន់ ឬរថយន្តតាក់ស៊ី ។ ដើម្បីនាំចេញ អ្នកដឹកជញ្ជូនទិញជ័រទឹកពីអ្នកលក់ដុំ ហើយដឹកវាតាមឡានធំទៅលក់ឱ្យអ្នកនាំចេញ ។ ផ្ទុយទៅវិញ ជ័រទឹកសំរាប់ទីផ្សារក្នុងស្រុក តាមធម្មតាគេដឹក (ដោយលាក់លៀម) ក្នុងឃ្លុបឡានតាក់ស៊ីដឹកអ្នកដំណើរ ។ អ្នកបើកបរតាក់ស៊ី មិនទិញជ័រទឹកទេ គឺគ្រាន់តែដឹកវាទៅឱ្យអ្នកបែងចែក ឬអ្នកលក់រាយ ដោយយកថ្លៃឈ្នួលពីអ្នកលក់ដុំ ។

អ្នកនាំចេញ ប្រមូលទិញជ័រទឹកពីអ្នកដឹកជញ្ជូនដើម្បីនាំចេញ ។ ក្នុងករណីមួយចំនួន អ្នកនាំចេញច្រោះសំអាតជ័រ ទឹក បើសិនអ្នកលក់ដុំមិនបានច្រោះវាទេ ។ ចំពោះផ្លូវពាណិជ្ជកម្មដែលបានសិក្សា ជ័រទឹកនាំចេញទាំងអស់ គេដឹកតាមច្រកមេមត់ ខេត្តកំពង់ចាម ចេញទៅវៀតណាម ។ ការដឹកជញ្ជូន មានទំហំពី ១-២០ត. ។

អ្នកបែងចែក/អ្នកលក់រាយក្នុងស្រុក ទិញជ័រទឹកពីអ្នកលក់ដុំ (ដឹកតាមតាក់ស៊ី) ។ អ្នកលក់រាយច្រើនមានទីតាំងនៅទីផ្សារក្នុងទីរួមខេត្ត ឬនៅជិតតំបន់នេសាទ ដែលមានទូកច្រើនជាប្រភពនៃតំរូវការជ័រទឹក ។ ការសិក្សាបានរកឃើញមានអ្នកបែងចែកជ័រទឹក ៤នាក់ នៅភ្នំពេញ ។ ពួកគេទិញជ័រទឹកពីខេត្តកំពង់ធំជាសំខាន់ ហើយចែកចាយទៅខេត្តតាកែវ កណ្តាល កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង និងកោះកុង ។

នៅតាមតំបន់បានសិក្សាទាំងបួន ជំរើសវិធីរកទីផ្សារ និងផ្លូវពាណិជ្ជកម្មដែលត្រូវប្រើ វាជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងកំរិតនៃការបង់ប្រាក់កំរៃ (និងការចៀសវាងបង់កំរៃ) គុណភាពជ័រទឹក ស្ថានភាពផ្លូវ និងតំរូវការផលិតផលជ័រទឹកខុសៗគ្នារបស់អតិថិជន ។ ឧទាហរណ៍ពីផលប៉ះពាល់នៃកត្តាទាំងនេះ ទៅលើរចនាសម្ព័ន្ធទីផ្សារ និងពាណិជ្ជកម្មនៅតាមតំបន់នីមួយៗ មានអធិប្បាយនៅខាងក្រោម[១៤] ។

មណ្ឌលគីរីៈ នៅអតីតកាល ពាណិជ្ជករខ្នាតតូចនៅស្រុកកែវសីមា និងអូរាំង បានធ្វើការលក់ដូរដោយឯករាជ្យដោយទិញជ័រទឹកពីអ្នកជងជ័រ ហើយដឹកវាផ្លូវជិតទៅព្រំដែនវៀតណាមនៅ ឡាបាកេ (Labake) ។ ក្រោយមកអាជ្ញាធរមូលដ្ឋានបានបង្កើនប្រាក់កំរៃខ្លាំងពេកនៅតាមផ្លូវទៅ ឡាបាកេ ធ្វើឱ្យពាណិជករមិនអាចនាំចេញតាមចំណុចព្រំដែននេះដោយមានចំណេញទេ ។ ជាក់ស្តែង ប្រាក់កំរៃបង់លើការនាំចេញជ័រទឹកតាម ឡាបាកេ វាខ្ពស់១០ដងជាងប្រាក់កំរៃបង់លើការនាំចេញតាមច្រកមេមត់ ខេត្តកំពង់ចាម ។ គ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដើម្បីចៀសវាងការបង់ប្រាក់កំរៃ ជ័រទឹកមួយភាគធំដែលប្រមូលបាននៅមណ្ឌលគីរី ឥលូវបាននាំចេញតាមច្រកមេមត់ ជាជាងតាម ឡាបាកេ ទោះបីត្រូវចំណាយខ្ពស់ជាងលើការដឹកជញ្ជូនផ្លូវឆ្ងាយទៅមេមត់ក្តី (សូមអានផ្នែក ៦.៥) ។ ម្យ៉ាងទៀត ដោយគ្មានមធ្យោបាយខាងហិរញ្ញវត្ថុ ដើម្បីដឹក ជញ្ជូនបរិមាណជ័រទឹកច្រើនៗ ពាណិជ្ជករខ្នាតតូចឥលូវនេះត្រូវ តែលក់ជ័រទឹកទៅឱ្យអ្នកលក់ដុំក្នុងស្រុក ជាជាងយកវាទៅលក់ នៅឯព្រំដែនដោយខ្លួនឯង ។

---

[១៤] សកម្មភាពធ្វើពាណិជ្ជកម្មជ័រទឹក មានវិសាលភាពធំជាងអ្វីដែលបានបង្ហាញក្នុងឯកសារនេះ ពីព្រោះការស្រាវជ្រាវបានធ្វើតែលើជំរើសផ្លូវពាណិជ្ជកម្ម និងតំបន់ផលិតជ័រទឹក ខ្លះប៉ុណ្ណោះ ។ ឧទាហរណ៍ ការសិក្សានេះពិនិត្យលើពាណិជ្ជកម្មពី ស្រុករវៀង និងត្បែងមានជ័យទៅវៀតណាម កាត់តាមខេត្តកំពង់ចាម, ប៉ុន្តែគេដឹងថា ជ័រទឹកផលិតក្នុងស្រុកដទៃទៀតនៃខេត្តព្រះវិហារ ត្រូវបានលក់ទៅវៀតណាម កាត់តាមខេត្តស្ទឹងត្រែង និង ទៅថៃ កាត់តាមប្រទេសឡាវដែរ ។


ពាណិជ្ជករចាក់ជ័រទឹកពីកានចំណុះ ៣០លិត្រ ចូលទៅបាវប្លាស្ទិក ដើម្បីដឹកជញ្ជូនតាមរទេះគោ

កំពង់ធំ: ការសិក្សារកឃើញថា ជ័រទឹកគុណភាពអន់ (ខាប់) មានចំនួនយ៉ាងច្រើន ប្រមូលបាននៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដែលនៅទីនោះជ័រទឹកថោកជាងនៅកន្លែងឯទៀតៗ ។ ដោយសារគុណភាពជ័រទឹកនេះ មិនត្រូវស្តង់ដាសំរាប់នាំចេញ ដូច្នេះភាគច្រើនបានលក់ក្នុងស្រុកតាមរយៈអ្នកបែងចែកនៅភ្នំពេញ ទៅដល់ខេត្តមួយចំនួន ។ ដើម្បីជៀសវាងប្រាក់កំរៃតាមកុងត្រូល ដែលអាចធ្វើឱ្យពាណិជ្ជកម្មគ្មានផលចំណេញ អ្នកលក់ដុំមិនអាចដឹកជញ្ជូនច្រើនៗតាមឡានធំបានទេ ។ ដូច្នេះគេជួលតាក់ស៊ីដឹកអ្នកដំណើរពីកំពង់ធំ មកភ្នំពេញ ឱ្យដឹកជ័រទឹកត្រឹមប្រហែល ២០០គ.ក ក្នុងឃ្លុបឡានវិញ ។

ព្រះវិហារ: នៅស្រុកត្បែងមានជ័យ និងរវៀង អ្នកលក់ដុំជួលពាណិជ្ជករតាមភូមិប្រហែល ៥-១០នាក់ ឱ្យទិញជ័រទឹកពីអ្នកដងជ័រ ។ ពាណិជ្ជករទាំងនេះ បានចំណេញប្រហែល ៥០០-១.០០០ រៀល/ជ័រទឹកមួយធុង (២៨-៣០គ.ក) ។ ពាណិជ្ជករដឹកជ័រទឹកទៅឱ្យអ្នកលក់ដុំ/និយោជករបស់ខ្លួន ដែលច្រោះសំអាត និងប្រមូលទុកវាឱ្យបានច្រើន សំរាប់ដឹក (២០តោន) ។ ជ័រទឹកដឹកចេញទាំងនេះ គេលក់ទៅឱ្យអ្នកដឹកជញ្ជូន ដែលក្រោយមកបានលក់ទៅឱ្យអ្នកនាំចេញនៅខេត្តកំពង់ចាម ។ អ្នកលក់ដុំរាយការណ៍ថា កាលពីមុនគេលក់ជ័រទឹកទៅឱ្យអ្នកបែងចែកនៅភ្នំពេញ ។ ប៉ុន្តែ ដោយដឹងថា ជ័រទឹកខេត្តព្រះវិហារ សមស្របសំរាប់នាំចេញ ហើយជ័រទឹកនាំចេញ ផ្តល់ផលកំរៃខ្ពស់ជាងការលក់ទៅភ្នំពេញ ដូច្នេះក៏មានការប្រែប្រួលនៅក្នុងពាណិជ្ជកម្ម ។

ឧត្តរមានជ័យ: ជ័រទឹកប្រមូលបាននៅស្រុកអន្លង់វែង ឬមួយលក់នៅសៀមរាបសំរាប់ប្រើក្នុងស្រុក ឬមួយដឹកកាត់ប្រទេសដើម្បីនាំចេញទៅវៀតណាមតាមច្រកកំពង់ចាម[១៥] ។ ស្រដៀងគ្នានឹងយុទ្ធសាស្ត្រដឹកជញ្ជូនដែលអនុវត្តនៅកំពង់ធំដែរ ជ័រទឹកដឹកពីអន្លង់វែងទៅសៀមរាប គេដាក់ក្នុងឃ្លុបឡានតាក់ស៊ីដឹកអ្នកដំណើរ ។ អ្នកលក់ដុំនៅសៀមរាបរាយការណ៍ថា ឥលូវនេះគេដងជ័រទឹកមកពីអន្លង់វែងវិញ ពីព្រោះមិនអាចទិញជ័រទឹកពីស្រុកបន្ទាយស្រី ខេត្តសៀមរាបបានទៀតទេ ។ អ្នកលក់ដុំមួយចំនួនផ្តល់គំនិតថា រឿងនេះកើតឡើងដោយសារតែការកាប់ដើមឈើផ្តល់ជ័រទឹកនៅបន្ទាយស្រី រីឯអ្នកលក់ដុំខ្លះទៀតបានគិតថា វាជាលទ្ធផលនៃការហាមឃាត់ការដឹកជញ្ជូនជ័រទឹក ពីសំណាក់អាជ្ញាធរមូលដ្ឋាននៅក្នុងតំបន់នោះ ។ ការសិក្សានេះមិនអាចបញ្ជាក់ទៅលើការអះអាងទាំងនេះបានទេ ។


ពាណិជ្ជករដឹកជ័រទឹកតាមរទេះគោ ទៅឱ្យអ្នកលក់ដុំនៅត្បែងមានជ័យ ខេត្តព្រះវិហារ

[១៥] ការសិក្សានេះមិនអាចកំណត់បានទេថា ហេតុអ្វីបានជាគេដឹកជ័រទឹកយ៉ាងឆ្ងាយបែបនេះដើម្បីនាំចេញទៅវៀតណាម ជាជាងលក់វាដើម្បីនាំចេញទៅថៃ ។

# ជំពូកទី ៥

# បទប្បញ្ញត្តិពាណិជ្ជកម្មជ័រទឹក និងការអនុវត្តន៍ជាក់ស្តែង

ក្នុងគោលដៅគ្រប់គ្រងព្រៃឈើ និងរកចំណូល រដ្ឋាភិបាលបានបង្កើតលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងប្រាក់កំរៃលើការដឹកជញ្ជូន និងការនាំចេញអនុផលព្រៃឈើ (NTFPs) ។ ប៉ុន្តែនៅក្នុងពាណិជ្ជកម្ម និងការនាំចេញជ័រទឹកជាក់ស្តែង សឹងតែគ្មានអ្នកណាម្នាក់មានលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណត្រឹមត្រូវទេ ។ ផ្ទុយទៅវិញ ពួកគេរកស៊ីតាមដំណើរការមិនផ្លូវការ ដែលមានការបង់ប្រាក់កំរៃជាច្រើនទៅឱ្យស្ថាប័នផ្សេងៗ ។ ជំពូកនេះធ្វើការពិនិត្យត្រួសៗពីបទប្បញ្ញត្តិ និងការតំរូវសំខាន់ៗនៃច្បាប់ សំរាប់ពាណិជ្ជកម្មជ័រទឹក និងគូសបញ្ជាក់ពីការអនុវត្តន៍ជាក់ស្តែងដោយមន្ត្រី និងអ្នកធ្វើសកម្មភាពផ្សេងៗក្នុងការរកទីផ្សារ និងពាណិជ្ជកម្មជ័រទឹក ។

## ៥.១. ការតំរូវផ្សេងៗក្នុងបទបញ្ញត្តិជាផ្លូវការ

ការប្រមូលផល ការស្តុក ពាណិជ្ជកម្ម និងការនាំចេញអនុផលព្រៃឈើ អាចត្រូវមានអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតជាច្រើន (សូមអានឧបសម្ព័ន្ធ ខ: មាត្រា ២៥ និង ២៦ នៃច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២) ។ ដូចបានបញ្ជាក់ហើយ តាមមាត្រា ៤០ នៃច្បាប់ស្តីពីព្រៃឈើ សហគមន៍មូលដ្ឋានមាន "សិទ្ធិប្រើប្រាស់ជាប្រពៃណី" ដើម្បីប្រមូលអនុផលព្រៃឈើ (រួមទាំងជ័រទឹក) ដោយមិនចាំបាច់មានលិខិតអនុញ្ញាត ។ ប៉ុន្តែបើសិនសហគមន៍ទាំងនេះ ចង់លក់អនុផលព្រៃឈើទៅឱ្យភាគីទីបី (ឧ. ពាណិជ្ជករ និងអ្នកលក់ដុំ) អាចមានការតំរូវឱ្យសុំលិខិតអនុញ្ញាត និងបង់ប្រាក់កំរៃ (មាត្រា ២៥.ក.៤ និង ៤០.ខ.៥) ។ ដោយសារជ័រទឹកសឹងតែទាំងអស់ បានលក់ដូរទៅឱ្យភាគីទីបី (លើកលែងតែមួយភាគតូចដែលប្រើនៅក្នុងភូមិតាមទំលាប់ ដូចជាធ្វើចន្លុះជាដើម) ដូច្នេះជ័រទឹកដែលសហគមន៍មូលដ្ឋានប្រមូលបានសឹងតែទាំងអស់សុទ្ធតែត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូន និងការបង់ប្រាក់កំរៃជាប់ទាក់ទិននានា ។ ក្រៅពីលិខិតដឹកជញ្ជូន អ្នកលក់ដុំជ័រទឹកត្រូវមានលិខិតអនុញ្ញាតសំរាប់ការស្តុក និងបែងចែកជ័រទឹក (មាត្រា២៥.ក.៨) ឯអ្នកនាំចេញត្រូវមានអាជ្ញាប័ណ្ណនាំចេញ (មាត្រា ២៥.ក.១១) ។

គេមិនអាចកំណត់ដឹងច្បាស់ទេថា តើការិយាល័យណានៅក្នុងក្រសួងកសិកម្ម និងនាយកដ្ឋានរុក្ខាប្រមាញ់ ទទួលខុសត្រូវក្នុងការសំរេច យល់ព្រម និងចេញលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ ។ ច្បាប់ស្តីពីព្រៃឈើ បានចែងពីការបង្កើត "រដ្ឋបាលព្រៃឈើ" ដែលនឹងក្លាយជា "ស្ថាប័នរដ្ឋសំរាប់អនុវត្តការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើ" ។ រដ្ឋបាលព្រៃឈើ នឹងត្រូវបានចាត់តាំងរចនាសម្ព័ន្ធដោយផ្ទាល់ និងតាមរយៈការគ្រប់គ្រងខ្សែបណ្តោយ ដែលចែកចេញជាកំរិតឋានានុក្រមដូចតទៅៈ ថ្នាក់កណ្តាល អធិការដ្ឋាន ខ័ណ្ឌ ផ្នែក និងសង្កាត់ (មាត្រា ៦.ក និង ៦.ខ) ។ ច្បាប់ក៏បានកំណត់ផ្តល់សិទ្ធិអំណាចក្នុងការសំរេចយល់ព្រម និងចេញលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ ទៅឱ្យរដ្ឋមន្ត្រីក្រសួងកសិកម្ម ប្រធានរដ្ឋបាលព្រៃឈើ នាយខ័ណ្ឌ នាយផ្នែក ដោយគ្មានចែងអ្វីពី "អធិការដ្ឋាន" និង "សង្កាត់" ទេ (សូមអានប្រអប់មាត្រា ២៦) ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ដោយសារ "ការរៀបចំ និងការប្រព្រឹត្តិទៅ" នៃរដ្ឋបាលព្រៃឈើ ទើបតែមានកំណត់ថ្មីៗដោយប្រកាស នៅខែកញ្ញា ឆ្នាំ២០០៣ នោះការទទួលខុសត្រូវគ្រប់គ្រងព្រៃឈើក្នុងពេលសព្វថ្ងៃ គឺក្តោបក្តាប់ដោយក្រសួងកសិកម្ម នាយកដ្ឋានរុក្ខាប្រមាញ់ និងការិយាល័យកសិកម្ម

រុក្ខាប្រមាញ់ និងកសិកម្មខេត្ត (PFOs)[១៦] ។

នៅក្នុងគោលការណ៍ស្តីពីអត្រាកំរៃផ្លូវការចំពោះផលិតផលព្រៃឈើ (២000) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងកសិកម្ម បានបង្កើតប្រាក់កំរៃលើការដឹកជញ្ជូនផលិតផលព្រៃឈើ ៧១មុខ មានទាំងជ័រទឹកផង (បញ្ជីផលិតផលព្រៃឈើទាំងអស់មានចុះក្នុងឧបសម្ព័ន្ធ គ) ។ តាមគោលការណ៍នេះ មន្ត្រីរុក្ខាប្រមាញ់មានតួនាទីគណនាយកប្រាក់កំរៃ ៣១៥រៀល/គ.ក ជ័រទឹកដែលក្នុងនេះមាន ៣00រៀល សំរាប់ "ប្រាក់កំរៃដឹកជញ្ជូន" និង ៥% (១៥រៀល) ទៀត សំរាប់ "ការគ្រប់គ្រងព្រៃឈើ" ។ អត្រាប្រាក់កំរៃសំរាប់ជ័រទឹក និងផលិតផលព្រៃឈើមួយចំនួនទៀតដែលមានធ្វើពាណិជ្ជកម្មច្រើន មានបង្ហាញនៅក្នុងតារាង ៥.១. ។

**តារាង ៥.១. អត្រាប្រាក់កំរៃផ្លូវការសំរាប់ផលិតផលព្រៃឈើជ្រើសរើសមួយចំនួន**

| ប្រភេទផលិតផលព្រៃឈើ | ឯកតា | ប្រាក់កំរៃសរុប[១] (រៀល/ឯកតា) | ប្រាក់កំរៃសរុប (ដុល្លារ/ឯកតា) | ប្រាក់កំរៃសរុប (ដុល្លារ/តោន) |
|---|---|---|---|---|
| ជ័រទឹក | ១ហាប = ៦0គ.ក | 18,900 | $4.8 | $80.4 |
| ធ្យូង | ១ហាប = ៦0គ.ក | 6,300 | $1.6 | $26.8 |
| ឫស្សីបន្ទាត់ផ្ចិតទំហំគល់ពី ៥ស.ម | ១តោន | 15,750 | $4.0 | $4.0 |
| ឫស្សីបន្ទាត់ផ្ចិតទំហំគល់តូចជាង ៥ស.ម | ១តោន | 10,500 | $2.7 | $2.7 |
| វល្លិ៍ | ១ហាប = ៦0គ.ក | 63,000 | $16.1 | $267.9 |
| ផ្តៅ | ១តោន | 262,500 | $67.0 | $67.0 |
| អុសចំរុះ | 1 ស្ទែរ = 1m3 | 10,500 | $2.7 | - |
| កូនឈើក្នុងលំដាប់ថ្នាក់ទំហំគល់ពី 0,១៥ម-0,១៩ម | ១ដើម | 6,300 | $1.6 | - |
| កូនឈើក្នុងលំដាប់ថ្នាក់ទំហំគល់ពី 0,១0-0,១៥ម | ១ដើម | 3,150 | $0.8 | - |
| កូនឈើក្នុងលំដាប់ថ្នាក់ទំហំគល់តូចជាង 0,១0ម | ១ដើម | 1,050 | $0.3 | - |

[១] ប្រាក់កំរៃសរុប គឺស្មើនឹង ប្រាក់កំរៃដឹកជញ្ជូន បូកនឹង ប្រាក់កំរៃគ្រប់គ្រងព្រៃឈើ ៥% ។ ប្រភព: *MAFF (2000)* ។

យោងតាម ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្លូវការបច្ចុប្បន្ន ការវិភាគលើមាត្រាជាប់ទាក់ទិននានានៃច្បាប់ស្តីពីព្រៃឈើ និងពតិមានពី គោលការណ៍ស្តីពីអត្រាកំរៃផ្លូវការចំពោះផលិតផលព្រៃឈើ ការតំរូវជាផ្លូវការផ្សេងៗចំពោះការស្តុកដឹកជញ្ជូន និងនាំចេញជ័រទឹក អាចសង្ខេបបានដូចខាងក្រោម:

**លិខិតអនុញ្ញាតស្តុក:** នៅក្នុងពាក្យសុំលិខិតអនុញ្ញាតស្តុក អ្នកលក់ដុំជ័រទឹកត្រូវផ្តល់ចំនួនជ័រទឹកប៉ាន់ស្មានដែលគេគ្រោងស្តុកក្នុងរយៈពេលមួយឆ្នាំ ។ បច្ចុប្បន្ននេះ ពាក្យសុំលិខិតអនុញ្ញាតត្រូវដាក់ជូនទៅ MAFF ក្រោយពីបានទទួលការយល់ព្រមពី PFO ជាប់ទាក់ទិនហើយ ។ MAFF អាចស្នើសុំការគាំទ្រផ្នែកបច្ចេកទេសពី DFW ។ នៅក្រោមរដ្ឋបាលព្រៃឈើនាពេលខាងមុខ នាយខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតអនុញ្ញាតនេះ (មាត្រា២៦.គ.២) ។

**លិខិតអនុញ្ញាតដឹកជញ្ជូន:** បច្ចុប្បន្ននេះ ដើម្បីដឹកជញ្ជូនជ័រទឹកនៅក្នុងខេត្តណាមួយ ត្រូវមានការយល់ព្រមពី PFO ប៉ុន្តែគ្មានការតំរូវឱ្យបង់ប្រាក់កំរៃផ្លូវការទេ ។ ដើម្បីដឹកជញ្ជូនជ័រទឹកឆ្លងកាត់ខេត្តនានានៅកម្ពុជា ត្រូវមានការយល់ព្រមពី PFO មានលិខិតដឹកជញ្ជូនសុំបានពី DFW នៅភ្នំពេញ និងត្រូវបង់ប្រាក់កំរៃ ៣១៥រៀល/គ.ក ជ័រទឹកទៅឱ្យ DFW ឬ PFO ។ នៅក្រោមរដ្ឋបាលព្រៃឈើនៅពេលខាងមុខ អាជ្ញាធរផ្សេងៗមួយចំនួនអាចមានតួនាទីក្នុងការចេញលិខិតដឹកជញ្ជូន ។ នៅកំរិតមូលដ្ឋាន នាយផ្នែករដ្ឋបាលព្រៃឈើ មានសិទ្ធិចេញលិខិតអនុញ្ញាតដឹកជញ្ជូន

[១៦] ចំពោះពតិមានលំអិតស្តីពីរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើថ្មី សូមអាន "ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលព្រៃឈើ" លេខ ៥0៩ PK/MAFF/B (១៧ កញ្ញា ២00៣) ។

សំរាប់ជ័រទឹកដែលធ្វើពាណិជ្ជកម្មចេញពីតំបន់នៅក្រោមការគ្រប់គ្រងផ្ទៃករបស់ខ្លួន (មាត្រា ២៦.ឃ.២) ។ បើសិនតំបន់នោះជាសហគមន៍ព្រៃឈើ ត្រូវមាន លិខិតកូតាដឹកជញ្ជូន ចេញដោយនាយខ័ណ្ឌរដ្ឋបាល ព្រៃឈើ (មាត្រា ២៦.គ.៤) ។ បើសិនតំបន់នោះជា ព្រៃសម្បទាន ឬ ព្រៃផលិតកម្មមិនស្ថិតក្រោមរបបសម្បទាន ត្រូវមានលិខិតកូតាដឹកជញ្ជូនចេញដោយប្រធានរដ្ឋបាលព្រៃឈើ (មាត្រា ២៦.ខ.២) ។ ហើយបើសិនជាជ័រទឹកសំរាប់នាំចេញ ត្រូវមានផងដែរនូវ លិខិតអនុញ្ញាតដឹកជញ្ជូន ចេញដោយប្រធានរដ្ឋបាលព្រៃឈើដែរ (មាត្រា ២៦.ខ.៣) ។

អាជ្ញាប័ណ្ណនាំចេញ: បច្ចុប្បន្ននេះ ដើម្បីនាំចេញជ័រទឹក ត្រូវមានការយល់ព្រមពី PFO, លិខិតដឹកអនុញ្ញាតជញ្ជូនពី DFW និងមានអាជ្ញាប័ណ្ណនាំចេញ យល់ព្រមដោយក្រសួងពាណិជ្ជកម្ម និង ទីស្តីការគណៈរដ្ឋមន្ត្រី ។ ជាបន្ថែមពីលើប្រាក់កំរៃ ៣១៥រៀល/គ.ក. អ្នកនាំចេញត្រូវបង់ "កំរៃសេវាកម្ម" ស្មើនឹង ១%នៃតំលៃជ័រទឹកនាំចេញសរុប បូកនឹងកំរៃសួយសារផង (ការសិក្សានេះ មិនអាចរកឃើញពីទឹកប្រាក់សួយសារជាផ្លូវការនេះទេ) ។ នៅក្រោមរដ្ឋបាលព្រៃឈើនាពេលខាងមុខ ការនាំចេញជ័រទឹកត្រូវមានអាជ្ញាប័ណ្ណនាំចេញ ផ្តល់ដោយរដ្ឋមន្ត្រី MAFF ក្រោយមានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា (គ្មានបញ្ជាក់ការិយាល័យ) ដែលត្រូវធ្វើទំនាក់ទំនង (មាត្រា ២៦.ក.២) ។ ការតំរូវផ្សេងទៀត រួមមាន លិខិតអនុញ្ញាតដឹកជញ្ជូន និង "ការអនុញ្ញាត ឬទិដ្ឋាការនៅលើអាជ្ញាប័ណ្ណនាំចេញ-នាំចូល" ស្នើសុំពីប្រធានរដ្ឋបាលព្រៃឈើ (មាត្រា ២៦.ខ.៥) និងលិខិតអនុញ្ញាតដឹកជញ្ជូនត្រូវស្នើសុំពីនាយផ្នែកដែលជាប់ទាក់ទិន និង/ឬ ពីនាយខ័ណ្ឌ ។

## ៥.២. ដំណើរការជាក់ស្តែងនៃប្រព័ន្ធ

ក្នុងការអនុវត្តន៍ជាក់ស្តែង ការដាក់ពាក្យសុំលិខិតអនុញ្ញាតដើម្បីដឹកជញ្ជូន និងស្តុកជ័រទឹក កំរមានណាស់, គ្មាននរណាម្នាក់មានអាជ្ញាប័ណ្ណនាំចេញ, និងគ្មានអ្នកណាបង់ប្រាក់កំរៃតាមអត្រាផ្លូវការទេ ។ ក្នុងករណីតិចតួចដែលអ្នកនាំចេញទទួលបានលិខិតដឹកជញ្ជូនជ័រទឹកផ្លូវការពីនាយកដ្ឋានរុក្ខាប្រមាញ់ លិខិតអនុញ្ញាតនេះកត់ត្រាដោយគ្មានតំលាភាព ហើយចុះតួលេខបន្ថយច្រើនណាស់នូវបរិមាណជ័រទឹកដឹកជញ្ជូនជាក់ស្តែង ។ អ្នកដឹកជញ្ជូនបានឱ្យដឹងថា តាមធម្មតាមានកត់ត្រាជាផ្លូវការនៅលើលិខិតដឹកជញ្ជូន ប្រហែលតែ ១ភាគ៤ នៃបរិមាណដឹកជញ្ជូនជាក់ស្តែងប៉ុណ្ណោះ ។ ការរាយការណ៍បញ្ចុះតួលេខ បានផ្តល់ឱកាសដល់មន្ត្រីរុក្ខាប្រមាញ់ ដើម្បីទារយកប្រាក់កំរៃក្រៅផ្លូវការ ថែមពីលើការបង់ជាផ្លូវការ ហើយទង្វើនេះវាស្រដៀងគ្នានេះនឹងទង្វើរបស់មន្ត្រីជលផលនៅក្នុងការនាំចេញត្រី (Yim and McKenney 2003) ។ ទាក់ទងនឹងអាជ្ញាប័ណ្ណនាំចេញ ការសិក្សានេះមិនបានរកឃើញនរណាម្នាក់នៅក្នុងរបរជំនួញជ័រទឹកមានអាជ្ញាប័ណ្ណឡើយ ហើយតំណាងនាយកដ្ឋានរុក្ខាប្រមាញ់ម្នាក់បញ្ជាក់ថា តាំងពីឆ្នាំ ២០០០មក គ្មានអ្នកណាម្នាក់មកសុំអាជ្ញាប័ណ្ណនាំចេញជ័រទឹកនេះទេ ។

ការប្រតិបត្តិតាមប្រព័ន្ធផ្លូវការនៃលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងប្រាក់កំរៃផ្សេងៗដែលគ្រប់គ្រងលើការរកទីផ្សារជ័រទឹកគឺពិបាកខ្លាំងណាស់ ជាពិសេសចំពោះអាជីវករតូចៗដែលខ្វះមធ្យោបាយបង់ប្រាក់កំរៃផ្លូវការ ឬធ្វើដំណើរទៅភ្នំពេញដើម្បីសុំលិខិតដឹកជញ្ជូន និង/ឬ អាជ្ញាប័ណ្ណនាំចេញ។ ដូច្នេះ ពាណិជ្ជកម្ម និងការនាំចេញជ័រទឹក សឹងតែទាំងអស់ ត្រូវតែធ្វើឡើងដោយខុសច្បាប់ ហើយប្រព័ន្ធនេះសឹងតែគ្មានផ្តល់ចំនូលផ្លូវការអ្វីដល់រដ្ឋទេ ។ ប៉ុន្តែប្រព័ន្ធផ្លូវការនេះបានផ្តល់នូវមូលដ្ឋានមួយសំរាប់ឱ្យអាជ្ញាធរមូលដ្ឋាន និងមន្ត្រីនានាជាច្រើន លើកមកសំអាងដើម្បីទារយកប្រាក់កំរៃក្រៅផ្លូវការ ។

ការសិក្សានេះបានរកឃើញថា អ្នកប្រមូលកំរៃ រួមមាន មន្ត្រីមកពីនាយកដ្ឋានរុក្ខាប្រមាញ់ ការិយាល័យរុក្ខាប្រមាញ់ខេត្ត ក្រសួងបរិស្ថាន ព្រមទាំងមន្ត្រីស្រុក ប៉ូលីស ប៉ូលីសសេដ្ឋកិច្ច យោធា និងកងរាជអាវុធហត្ថ ។ របៀបអនុវត្តជាទូទៅមួយដើម្បីទារយកប្រាក់កំរៃ គឺការ "ត្រួតពិនិត្យ" លិខិតដឹកជញ្ជូន ។ ពួកមន្ត្រីបានដឹងថា អ្នកនាំចេញ ឬមួយគ្មានលិខិតដឹកជញ្ជូន ឬមួយ

មានលិខិតដឹកជញ្ជូនដែលរាយការណ៍បន្ទាប់បន្ទូរចំនួនជ័រទឹកជាក់ស្តែង ។ ពួកគេអាចយក "ការត្រួតពិនិត្យ" លិខិតអនុញ្ញាតនេះ ធ្វើជាមូលដ្ឋានបានរាល់លើកដើម្បីទារយកប្រាក់កំរៃ ។ ពួកមន្ត្រីដែលប្រមូលប្រាក់កំរៃលើការនាំចេញត្រី ក៏បានប្រើវិធីសាស្ត្រដូចគ្នានេះដែរ (Yim and McKenney 2003) ។

គួរបង្ហាញចំណុចសំខាន់មួយទៀតថា ប្រព័ន្ធប្រមូលប្រាក់កំរៃក្រៅផ្លូវការប្រែប្រួលខុសប្លែកគ្នាច្រើនណាស់ ដែលធ្វើឱ្យអ្នកប្រកបរបរជំនួញជ័រទឹក មិនអាចដឹងច្បាស់ពីបន្ទុកចំណាយរបស់ខ្លួន ។ ទី១ ស្ថាប័នដដែលអាចប្រមូលយកប្រាក់កំរៃលើការដឹកជញ្ជូនជ័រទឹក នៅតាមចំណុចត្រួតពិនិត្យច្រើនកន្លែង ហើយក៏គ្មានបង្កាន់ដៃអ្វីសំរាប់ឱ្យអ្នកនាំចេញបញ្ជាក់ថា ខ្លួនបានបង់ប្រាក់រួចហើយទៅឱ្យស្ថាប័នណាមួយ ។ ទី២ ប្រាក់កំរៃអាចខុសគ្នាច្រើនពីស្រុកមួយទៅស្រុក ។ ឧទាហរណ៍ ប្រាក់កំរៃដែលមន្ត្រីស្រុកនៅកែវសីមា ខេត្តមណ្ឌលគិរី ទារយក វាមានកំរិត ៥ដង ខ្ពស់ជាងប្រាក់កំរៃនៅស្រុកអូរាំង ដែលនៅជិតនោះ ។ ទី៣ ពាណិជ្ជករ និងអ្នកលក់ដុំបានរាយការណ៍ពីករណីជាច្រើនដែលអាជ្ញាធរមូលដ្ឋានបានតំលើងកំរិតប្រាក់កំរៃ ដោយមិនឱ្យដឹងជាមុន ជួនកាលខ្ពស់ជាងអត្រាមុនដល់ទៅជាងពីរដង ។ ទី៤ ទោះបីកំរិតប្រាក់កំរៃអាចកំណត់ឡើងក្តី ក៏ប្រាក់កំរៃទាំងអស់សុទ្ធតែអាចចរចាបាន ដែលធ្វើឱ្យវាប្រែប្រួលខុសគ្នាទៅតាមកត្តាផ្សេងៗ មានទាំង "អារម្មណ៍" របស់អ្នកប្រមូលប្រាក់កំរៃនៅថ្ងៃនោះផង ។

## ជំពូកទី ៦

# ការវិភាគពីបន្ទុកចំណាយ និងប្រាក់កំរៃលើពាណិជ្ជកម្មជ័រទឹក

ឧបសគ្គចំបងចំពោះពាណិជ្ជកម្មជ័រទឹក គឺ ចំណាយដឹកជញ្ជូន និងប្រាក់កំរៃក្រៅផ្លូវការច្រើនបែបយ៉ាង ។ ទោះបីចំនាយទាំងនេះ កើតមានចំពោះការរកទីផ្សារជ័រទឹក មិនមែនការដងជ័រទឹកក្តី ក៏វាអាចមានផលប៉ះពាល់គួរកត់សំគាល់ទៅលើចំណូលរបស់អ្នកដងជ័រ ។ នៅពេលអ្នករកទីផ្សារជ័រទឹកមានបន្ទុកចំណាយច្រើនលើការលក់ដូរ ពួកគេប្រហែលមិនអាចរ៉ាប់រងវាទាំងអស់ហើយនៅតែមានចំណេញនោះទេ ។ ក្នុងករណីបែបនេះ ពួកគេត្រូវផ្ទេរបន្ទុកចំនាយទៅលើអ្នកដងជ័រ ដោយបញ្ចុះថ្លៃទិញជ័រ គឺដូចសំដីរបស់ពាណិជ្ជករម្នាក់ថា "នៅពេលអាជ្ញាធរបង្កើនប្រាក់កំរៃ ខ្ញុំមិនអាចបង់វាទាំងអស់ហើយរកចំណេញបានទេ ដូច្នេះខ្ញុំត្រូវបញ្ចុះថ្លៃទិញជ័រពីអ្នកភូមិ" ។

ការប្រមូល និងពាណិជ្ជកម្មអនុផលព្រៃឈើត្រូវបានទទួលស្គាល់ថា ជាប្រភពចំណូលដ៏សំខាន់មួយនៅជនបទកម្ពុជា ។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ មិនទាន់មានការវាយតំលៃជាតួលេខនូវបន្ទុកចំណាយដែលជាប់ទាក់ទិននឹងការរកទីផ្សារអនុផលព្រៃឈើនៅក្នុងប្រទេសកម្ពុជា និងក្នុងការនាំចេញនោះទេ ។ ជំពូកនេះធ្វើការគណនាពីបន្ទុកចំណាយ និងប្រាក់កំរៃជាប់ទាក់ទិននឹងការរកទីផ្សារជ័រទឹក ។ ពិនិត្យតាមបទប្បញ្ញត្តិ និងការអនុវត្តន៏ជាក់ស្តែងសព្វថ្ងៃក្នុងវិស័យអនុផលព្រៃឈើ, ករណីវិភាគពីជ័រទឹកនេះ ប្រហែលអាចតំណាងបាននូវលក្ខខណ្ឌពាណិជ្ជកម្មសំរាប់អនុផលព្រៃឈើផ្សេងៗទៀត ។ គោលដៅនៃការវិភាគនេះគឺស្វែងយល់ឱ្យបានកាន់តែប្រសើរពីទំហំចំណាយ និងប្រាក់កំរៃក្នុងជំនួញជ័រទឹក ព្រមទាំងផលប៉ះពាល់អវិជ្ជមានរបស់វាទៅលើចំណូលនៅជនបទ ។

សំរាប់ផ្លូវពាណិជ្ជកម្មនីមួយៗនៃ ៤ផ្លូវដែលបានសិក្សា វបសអ បានប្រមូលពត៌មានស្តីពី ដំណើរការ ក៏រិតថ្លៃ ផលចំនេញ បន្ទុកចំនាយ (មូលធន ប្រតិបត្តិការ និងបន្ទុកចំណាយលើទុនបង្វិល) និងប្រាក់កំរៃ ក្នុងពាណិជ្ជកម្មជាក់ស្តែង ។ ដូចមានបង្ហាញក្នុងតារាង ៦.១ មានប្រែប្រួលខុសគ្នាយ៉ាងច្រើនក្នុង ក៏រិតថ្លៃ បន្ទុកចំនាយ និងប្រាក់កំរៃ រវាងផ្លូវពាណិជ្ជកម្មនានា ។ ឧទាហរណ៏ ចំពោះអ្នកដងជ័រម្នាក់ដែលចូលទៅព្រៃប្រមូលជ័រទឹកបាន ១តោន/ឆ្នាំ គាត់អាចទទួលបានតែ ៦៧ដុល្លារទេសំរាប់ជ័រទឹកនៅខេត្តកំពង់ធំ ពីព្រោះវាមានគុណភាពអន់ ប៉ុន្តែគាត់អាចរកប្រាក់បានច្រើនជាងនេះបីដង បើសិនវាជាជ័រទឹកនៅខេត្តមណ្ឌលគិរី (១៩៤ ដុល្លារ) ។ បើនៅខេត្តព្រះវិហារ ឬឧត្តរមានជ័យ អ្នកដងនេះអាចទទួលបានតែជាង ១០០ដុល្លារទេ ទោះបីជ័រទឹកមានគុណភាពដូចគ្នានឹងខេត្តមណ្ឌលគិរីក្តី ។ ថ្លៃដែលអ្នកផលិតជ័រទឹកទទួលបានខុសគ្នាៗ សំរាប់ផ្លូវពាណិជ្ជកម្មទាំងបួននេះ កើតចេញពីកត្តាមួយចំនួនដូចជា គុណភាពជ័រទឹក, ចំងាយផ្លូវពីភូមិរបស់អ្នកដងជ័រទៅទីផ្សារចុងក្រោយ, ក៏រិតប្រាក់កំរៃនៅតាមផ្លូវពាណិជ្ជកម្ម, និងទីផ្សារចុងក្រោយ (ថ្លៃនាំចេញ ខ្ពស់ជាងថ្លៃក្នុងស្រុក) ។

តារាង ៦.១. ការវិភាគពីបន្ទុកចំណាយ និងផលចំណេញ ក្នុងជំនួញជ័រទឹកនៅកម្ពុជា សំរាប់ ៤ ផ្លូវពាណិជ្ជកម្ម

| ការវិភាគពីចំណូល និងចំណាយ | ផ្លូវពាណិជ្ជកម្មទី១: មណ្ឌលគិរី-កំពង់ចាម -វៀតណាម | | ផ្លូវពាណិជ្ជកម្មទី២: ព្រះវិហារ-កំពង់ចាម -វៀតណាម | | ផ្លូវពាណិជ្ជកម្មទី៣: កំពង់ធំ -ភ្នំពេញ | | ផ្លូវពាណិជ្ជកម្មទី៤: ឧត្តរមានជ័យ -សៀមរាប | |
|---|---|---|---|---|---|---|---|---|
| | ៛/គ.ក | $/តោន | ៛/គ.ក | $/តោន | ៛/គ.ក | $/តោន | ៛/គ.ក | $/តោន |
| ថ្លៃបង់ឱ្យអ្នកដងជ័រ | 759 | 194 | 414 | 105 | 261 | 67 | 437 | 111 |
| ថ្លៃ នាំចេញ/ទីផ្សារ | 1275 | 325 | 1250 | 319 | 675 | 172 | 861 | 220 |
| ថ្លៃបានចំណេញ (ពីអ្នកដងជ័រ ដល់ នាំចេញ/ទីផ្សារ) | 515 | 131 | 836 | 213 | 414 | 106 | 423 | 108 |
| ចំនាយពាណិជ្ជកម្មសរុប (ពីអ្នកដងជ័រ ដល់ ទីផ្សារ/នាំចេញ មិនបូកប្រាក់កំរៃ) | 226 | 58 | 354 | 90 | 175 | 45 | 127 | 32 |
| ប្រាក់កំរៃ | 120 | 31 | 240 | 61 | 82 | 21 | 109 | 28 |
| កំរិតចំណេញ[១] | 168 | 43 | 241 | 61 | 155 | 40 | 187 | 48 |
| ប្រាក់កំរៃជា %នៃចំណាយសរុប | 35% | | 40% | | 32% | | 46% | |
| ប្រាក់កំរៃជា %នៃចំណេញ"ជាសក្តានុពល"[២] | 42% | | 50% | | 35% | | 37% | |

[១] កំរិតចំណេញនេះ គឺជាប្រាក់ចំណេញ ក្នុងករណីដែលម្ចាស់ជំនួញ បានបញ្ចូលប្រាក់ឈ្នួលរបស់ខ្លួនឯងទៅក្នុងចំណាយប្រតិបត្តិការ ។ បើសិន ម្ចាស់ជំនួញមិនគិតប្រាក់ឈ្នួលប្រចាំថ្ងៃរបស់ខ្លួនឯងជាចំណែកមួយនៃចំណាយប្រតិបត្តិការទេ, កំរិតចំណេញនេះគឺជាចំណូលសុទ្ធ ។
[២] ចំនេញជាសក្តានុពល គឺស្មើនឹងថ្លៃបានចំនេញ (ពីអ្នកដងជ័រ ដល់ នាំចេញ/ទីផ្សារ) ដកនឹងចំនាយពាណិជ្ជកម្មសរុប(គ្មានបូកប្រាក់កំរៃទេ) ។

## ៦.១. ចំណែករបស់អ្នកដងជ័រ នៅក្នុងតំលៃទីផ្សារនៃជ័រទឹក

ការប្រៀបធៀបថ្លៃរបស់ផលិតករ ទៅនឹងថ្លៃទីផ្សារនាំចេញ/ក្នុងស្រុក បង្ហាញថា អ្នកដងជ័រនៅមណ្ឌលគិរីទទួលបាន ភាគរយតំលៃទីផ្សារជ័រទឹកខ្ពស់ជាងគេ គឺប្រហែល ៦០% (១៩៤ដុល្លារ ក្នុងកំរិតថ្លៃទីផ្សារ ៣២៥ដុល្លារ/តោន) ។ រឿងនេះ ហាក់ដូចកើតឡើងដោយសារជំនួញជ័រទឹកនៅខេត្តមណ្ឌលគិរីមានសកម្មភាពច្រើន ដែលជំរុញឱ្យមានការប្រកួតប្រជែងទីផ្សារ ដោយសេរីជាង, ការប្រជែងគ្នាឱ្យថ្លៃខ្ពស់ដល់ផលិតករ, និង កំរិតចំណេញទាបជាងសំរាប់អ្នករកទីផ្សារជ័រទឹក ។ ការនៅជាប់នឹង ប្រទេសវៀតណាម ធ្វើឱ្យ ការដឹកជញ្ជូន អស់សោហ៊ុយតិចជាង ជ័រទឹកនាំចេញពីព្រះវិហារ ។ ប៉ុន្តែ បន្ទុកចំណាយទាំងនេះ អាច ទាបថែមទៀត បើសិនគ្មានការយកប្រាក់កំរៃខ្ពស់នៅចំណុចព្រំដែន ឡាបាកេ នៅជិតនោះ ដែលបានបង្ខំឱ្យអ្នកដឹកជញ្ជូន ធ្វើ ដំណើរផ្លូវវាងឆ្ងាយ ដើម្បីនាំចេញតាមច្រកមេមត់ ខេត្តកំពង់ចាមវិញ (សូមអានផ្នែកទី ៦.៥) ។

ខុសពីខេត្តមណ្ឌលគិរី អ្នកដងជ័រនៅខេត្តព្រះវិហារ និងកំពង់ធំ ទទួលបានតែប្រហែល ១ភាគ៣ នៃតំលៃទីផ្សារនៃជ័រទឹក របស់ខ្លួន (១០៥ដុល្លារ ក្នុងតំលៃទីផ្សារ ៣១៩ដុល្លារ និង ៦៧ដុល្លារ ក្នុងតំលៃទីផ្សារ ១៧២ដុល្លារ/តោន រៀង១គ្នា) ។ នៅខេត្ត ព្រះវិហារ ចំណូលទាបសំរាប់អ្នកដងជ័រ ប្រហែលដោយសារកំលាំងត្រួតត្រាទីផ្សារកំរិតខ្ពស់របស់អ្នកលក់ដុំចំបង១ពីរនាក់នៅ តំបន់នោះ ។ អ្នកលក់ដុំម្នាក់១ ប្រមូលទិញជ័រទឹក (តាមរយៈពាណិជ្ជករដែលគេជួល) ដោយផ្តោតលើស្រុកផ្សេងពីគ្នា (ចែក ស្រុកគ្នា) ។ ជាលទ្ធផល គឺកង្វះការប្រកួតប្រជែងប្រមូលទិញជ័រទឹកផ្គត់ផ្គង់ ដែលធ្វើឱ្យអ្នកដងជ័រទទួលបានថ្លៃទាប ។ ម្យ៉ាងទៀត បន្ទុកចំណាយទាក់ទិននឹងផ្លូវឆ្ងាយទៅកាន់ទីផ្សារ និងប្រាក់កំរៃកំរិតខ្ពស់តាមផ្លូវពីព្រះវិហារទៅកំពង់ចាម/វៀត ណាម បានកាត់បន្ថយថ្លៃដែលអ្នកដងជ័រទទួលបាន ។ នៅខេត្តកំពង់ធំ ចំណូលរបស់អ្នកដងជ័រ ត្រូវបានប៉ះពាល់ដោយហានិភ័យ កំរិតខ្ពស់នៅក្នុងការដឹកជញ្ជូនជ័រទឹក ។ ការដឹកជ័រទឹកតាមរថយន្តតាក់ស៊ីដឹកអ្នកដំណើរ តាមធម្មតាអាចចៀសវាងការបង់ប្រាក់ កំរៃតាមផ្លូវបាន ប៉ុន្តែបើសិនត្រូវគេចាប់ជ័រទឹកអាចត្រូវរឹបអូស និងមានការផាកពិន័យយ៉ាងធ្ងន់ (រហូតដល់ ១លានរៀល ឬ ២៥០ដុល្លារ) ។ ដោយមានហានិភ័យដូច្នេះ អ្នកលក់ដុំ និងអ្នកដឹកជញ្ជូនជ័រទឹក បានឱ្យថ្លៃទាបដល់អ្នកដងជ័រ ។

## ៦.២. បន្ទុកចំណាយលើពាណិជ្ជកម្ម

បន្ទុកចំនាយលើពាណិជ្ជកម្ម សំដៅដល់គ្រប់ចំនាយលើប្រតិបត្តិការ មូលធន និង ទុនបង្វិល ដែលជាប់ទាក់ទងនឹងការស្តុក ការប្រមូលទុកឱ្យបានច្រើន និងការដឹកជញ្ជូនជ័រទឹកពីភូមិរបស់អ្នកដងជ័រ (ឬពីច្រកព្រៃ) ទៅទីផ្សារចុងក្រោយ ។ ចំណាយប្រតិបត្តិការរួមមាន ចំណាយប្រចាំថ្ងៃក្នុងជំនួញ ដូចជា ការដឹកជញ្ជូន ប្រេងឥន្ធនៈ កម្មករ និង បាវផ្ទុកជ័រ ។ វិនិយោគរយៈពេលវែងដូចជា រថយន្ត ទូក ធុងធំៗ ធុងប្លាស្ទិក ជញ្ជីង និងកន្លែងឃ្លាំងស្តុក ស្ថិតក្នុងខ្ទង់ ចំណាយមូលធន ។ ទុនបង្វិល គឺជាសាច់ប្រាក់ក្នុងដៃ ទុកសំរាប់ដំណើរការរបរជំនួញ និងធ្វើពាណិជ្ជកម្ម ។ ចំពោះទុនបង្វិល នៅមានចំនាយជា "តំលៃឱកាសត្រូវបាត់បង់" មួយទៀត ដោយសារសាច់ប្រាក់នេះអាចយកទៅបំរើគោលដៅវិនិយោគផ្សេងទៀតបាន បើសិនមិនជាប់ប្រើក្នុងមុខជំនួញនេះទេ ។ ប្រាក់កំរៃលើពាណិជ្ជកម្មជ័រទឹកទាំងអស់ ត្រូវបានដកចេញពីបន្ទុកចំណាយពាណិជ្ជកម្ម ដើម្បីអាចធ្វើវិភាគបានអំពី បន្ទុកចំណាយពាណិជ្ជកម្មជាតួយ៉ាង ដោយគ្មានការជាប់ទាក់ទងទៅនឹងប្រាក់កំរៃនានាដែលបទប្បញ្ញត្តិផ្សេងៗបានតំរូវឡើង ។

បន្ទុកចំណាយពាណិជ្ជកម្មមានពី ៣២-៩០ដុល្លារ/តោន ទៅតាមផ្លូវពាណិជ្ជកម្មខុសៗគ្នា ។ ជាមធ្យម ចំនាយពាណិជ្ជកម្មមានប្រហែល ៥៦ដុល្លារ/តោន ឬ ៤០% នៃផលចំណេញខាងទីផ្សារ (ថ្លៃទីផ្សារ/ការនាំចេញ ដកថ្លៃដែលអ្នកដងជ័រទទួលបាន) ។ ចំណាយដឹកជញ្ជូន និងប្រេងឥន្ធនៈមានប្រហែល ៨០-៩០% នៃបន្ទុកចំណាយពាណិជ្ជកម្ម ។ បើប្រៀបធៀបគ្នា ចំណាយផ្សេងទៀតសំរាប់ស្តុកជ័រទឹក ពលកម្ម វិនិយោគជាមូលធន និងទុនបង្វិល មានបរិមាណតិចតួចណាស់ ។ ដូច្នេះ បន្ទុកចំណាយពាណិជ្ជកម្មជាប់ទាក់ទងយ៉ាងធំជាមួយនឹងចំងាយផ្លូវពីអ្នកលក់ដុំ ទៅទីផ្សារចុងក្រោយ ហើយបន្ទុកចំណាយខ្ពស់បំផុត (៩០ដុល្លារ/តោន) បានកើតមានឡើងចំពោះពាណិជ្ជកម្មពីខេត្តព្រះវិហារ ទៅ កំពង់ចាម/វៀតណាម ។

## ៦.៣. ប្រាក់កំរៃ

បន្ថែមទៅលើបន្ទុកចំណាយជំនួញ និងពាណិជ្ជកម្មជាតួយ៉ាង (ដឹកជញ្ជូន ពលកម្ម និង សំភារៈសំរាប់ស្តុកជ័រ) មានការតំរូវឱ្យបង់ប្រាក់កំរៃយ៉ាងច្រើនលើការរកទីផ្សារជ័រទឹក ។ ចំពោះផ្លូវពាណិជ្ជកម្មបានសិក្សាទាំងបួន, ប្រាក់កំរៃលើពាណិជ្ជកម្មជ័រទឹកមានពី ២១-៦១ដុល្លារ/តោន ។ មធ្យមភាគនៃប្រាក់កំរៃលើផ្លូវពាណិជ្ជកម្មទាំងបួន គឺប្រហែល ៣៧ដុល្លារ/តោន ឬ ២៦% នៃផលចំណេញខាងទីផ្សារ ។ បើសិនគិតលើជ័រទឹកទាំងអស់ដែលផលិត និងធ្វើពាណិជ្ជកម្មនៅកម្ពុជា ប្រមាណ ២០.០០០ តោន/ឆ្នាំ ប្រាក់កំរៃសរុបលើជ័រទឹកមានពីប្រហែល ៥០០.០០០-១លានដុល្លារ/ឆ្នាំ ។

ប្រាក់កំរៃ ត្រូវបង់នៅតាមផ្លូវ និងតាមចំណុចធ្វើពាណិជ្ជកម្មនានា ។ កំរៃទាំងអស់ ឬមួយត្រូវបង់ក្រៅផ្លូវការ ឬមួយបង់តាមមូលដ្ឋានផ្លូវការប៉ុន្តែមិនទៅតាមអត្រាផ្លូវការទេ ។ ជាមធ្យមប្រាក់កំរៃទាំងនេះ វាបន្ថែម ៦៥% ទៀត ដល់ចំនាយខាងទីផ្សារ (គឺប្រាក់កំរៃវាបន្ថែម ៣៧ដុល្លារ លើបន្ទុកចំណាយ ៥៦ដុល្លារ ធ្វើឱ្យចំណាយសរុបឡើងដល់ ៩៣ដុល្លារ/តោន) ។ ហើយវាបានកាត់បន្ថយយ៉ាងច្រើននូវប្រាក់ចំណេញក្នុងទីផ្សារជ័រទឹក ។ បច្ចុប្បន្នប្រាក់ចំណេញលើពាណិជ្ជកម្មជ័រទឹក តាំងពីភូមិរបស់អ្នកដងជ័រ ទៅដល់ទីផ្សារចុងក្រោយ មានជាមធ្យម ៤៧ដុល្លារ/តោន ប៉ុន្តែវាត្រូវកើនឡើងប្រហែល ៨០% (៨៤ដុល្លារ/តោន) ទៀត បើសិនគ្មានការយកប្រាក់កំរៃទេ ។

## ៦.៤. សង្ខេបពីប្រាក់កំរៃៈ ពាណិជ្ជកម្មជ័រទឹកចេញពីព្រះវិហារ និងមណ្ឌលគីរី

ផលប៉ះពាល់នៃប្រាក់កំរៃលើបន្ទុកចំណាយ និងប្រាក់ចំណេញលើការរកទីផ្សារជ័រទឹក គួរធ្វើវិភាគឱ្យបានល្អិតល្អន់ថែមទៀត ។ ជំពូកនេះ បានពិនិត្យលំអិតមួយលើការដឹកជញ្ជូនតាមផ្លូវពាណិជ្ជកម្មពីរគឺ ផ្លូវទី១ ពីស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ទៅស្រុកស្គន់ ខេត្តកំពង់ចាម និងបន្តទៅព្រំដែនវៀតណាម (តារាង ៦.២) និងផ្លូវទី២ ពីស្រុកកែវសីមា ខេត្តមណ្ឌលគីរី ទៅស្រុកមេមត់ ខេត្តកំពង់ចាម និងបន្តទៅព្រំដែនវៀតណាម (តារាង៦.៣) ។ ការដឹកជញ្ជូនទាំងនេះបង្ហាញពីការប្រែប្រួលខុសគ្នាក្នុងទឹកប្រាក់កំរៃ ចំនួនដងនៃការបង់ និងស្ថាប័ននានាដែលប្រមូលកំរៃ ។

ពីភូមិជងជ័រក្នុងខេត្តព្រះវិហារ ទៅព្រំដែនវៀតណាម កំរៃដែលគេតំរូវឱ្យបង់ទៅលើការដឹកជញ្ជូនជ័រទឹក ២០តោន មានទាំងអស់ ១.៣៨៤ដុល្លារ (ឬ ៦៧ដុល្លារ/តោន)។ ក្នុងពាណិជ្ជកម្មនេះ មានការបង់ប្រាក់ ៤៣ដង នៅ ១៤កន្លែងខុសៗគ្នា ទៅឱ្យស្ថាប័ន និងអាជ្ញាធរ និងស្ថាប័នថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាន ។ មន្ត្រីរុក្ខាប្រមាញ់ប្រមូលយកប្រាក់កំរៃច្រើនជាងគេនៅតាមផ្លូវពាណិជ្ជកម្មនេះ គឺមានការបង់រហូតដល់ ២០ដង អស់ប្រហែល ៧៥%នៃប្រាក់កំរៃសរុប ។ ក្រៅពីនេះមានការបង់ ១៧ដងទៀត ឱ្យដល់ប៉ូលីស ប៉ូលីសសេដ្ឋកិច្ច កងរាជអាវុធហត្ថ និងកងទ័ព ។ ឯការបង់ ៦ដងទៀត បានធ្វើទៅឱ្យមន្ត្រីខាងបរិស្ថាន គយ និងមន្ត្រីស្រុក ។ គេគួរកត់សំគាល់ថា នេះជាការដឹកជញ្ជូនតែមួយគត់ ដែលការស្រាវជ្រាវរបស់ វបសអ បានរកឃើញថា មានលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយ DFW នៅភ្នំពេញ ។ អ្នកដឹកជញ្ជូនបានត្អូញត្អែរថា ទោះបីបានបង់ប្រាក់កំរៃច្រើនគួរសមទៅឱ្យ DFW និងមានលិខិតអនុញ្ញាតហើយក្តី ក៏គាត់នៅតែត្រូវបង់ប្រាក់កំរៃក្រៅផ្លូវការជាច្រើនទៅឱ្យមន្ត្រីរុក្ខាប្រមាញ់នៅតាមផ្លូវទៀត ។ ក្នុងការដឹកជញ្ជូននេះ គ្មានអាជ្ញាប័ណ្ណនាំចេញទេ ។

**តារាង ៦.២. ការបង់កំរៃសំរាប់ការដឹកជ័រទឹក២០តោន ពីព្រះវិហារទៅវៀតណាម**

| តំបន់ | កន្លែងបង់ប្រាក់ | ស្ថាប័នប្រមូលប្រាក់កំរៃ | អត្រាបង់កំរៃជាក់ស្តែង | | | | % ប្រាក់កំរៃសរុប |
|---|---|---|---|---|---|---|---|
| | | | ៛/គ.ក | $/តោន | ៛/ដឹកជញ្ជូន | $/ដឹកជញ្ជូន | |
| ភ្នំពេញ | ១. នា.រុក្ខាប្រមាញ់ | ប្រាក់កំរៃដើម្បីទទួលបានអាជ្ញាប័ណ្ណ | 157.5 | 40.2 | 3,150,000 | 803.6 | 59.8% |
| | | ការគិតសេវាកម្មសំរាប់ការនាំចេញ (១% នៃតំលៃនាំចេញសរុប) | 0 | 0.0 | 0 | 0.0 | |
| | | អត្រាសួយសារ* | 0 | 0.0 | 0 | 0.0 | |
| ព្រះវិហារ | ២. ទីរួមខេត្តព្រះវិហារ | ការិយាល័យរុក្ខាប្រមាញ់ខេត្ត | 2.5 | 0.6 | 50,000 | 12.8 | 1.0% |
| | | ខាងរុក្ខាប្រមាញ់ | 3.5 | 0.9 | 70,000 | 17.9 | 1.3% |
| | | ប៉ូលីសសេដ្ឋកិច្ច | 2.5 | 0.6 | 50,000 | 12.8 | 1.0% |
| | | កងរាជអាវុធហត្ថ | 0.5 | 0.1 | 10,000 | 2.6 | 0.2% |
| | ៣. ជីអោក | កងរាជអាវុធហត្ថ | 1.5 | 0.4 | 30,000 | 7.7 | 0.6% |
| | | ការិយាល័យរុក្ខាប្រមាញ់ខេត្ត | 3.5 | 0.9 | 70,000 | 17.9 | 1.3% |
| | | ប៉ូលីសសេដ្ឋកិច្ច | 2.5 | 0.6 | 50,000 | 12.8 | 1.0% |
| | | ការិយាល័យបរិស្ថានខេត្ត | 1.5 | 0.4 | 30,000 | 7.7 | 0.6% |
| កំពង់ធំ | ៤. សាលាវិស័យ | ការិយាល័យរុក្ខាប្រមាញ់ខេត្ត | | | | | |
| | | កងរាជអាវុធហត្ថ | | | | | |
| | | ប៉ូលីសសេដ្ឋកិច្ច | | | | | |
| | | យោធាស្រុក | | | | | |
| | | ប៉ូលីស | | | | | |
| | | ការិយាល័យបរិស្ថានខេត្ត | 10 | 2.6 | 200,000 | 51.0 | 3.8% |
| | ៥. ស្រុកកំពង់ស្វាយ | នាយកដ្ឋានរុក្ខាប្រមាញ់ | | | | | |
| | | ការិយាល័យរុក្ខាប្រមាញ់ខេត្តចល័ត | | | | | |
| | | រុក្ខាប្រមាញ់សង្កាត់ | | | | | |
| | | ខាងរុក្ខាប្រមាញ់ | | | | | |
| | | ការិយាល័យបរិស្ថានខេត្ត | | | | | |
| | | កងរាជអាវុធហត្ថ | | | | | |
| | | ប៉ូលីសសេដ្ឋកិច្ច | 20 | 5.1 | 400,000 | 102.0 | 7.6% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៦. កុងត្រូលចល័ត | កងរាជអាវុធហត្ថខេត្ត | 2.5 | 0.6 | 50,000 | 12.8 | 1.0% |
| | ៧. កុងត្រូលចល័ត | កងរាជអាវុធហត្ថស្រុក | 2.5 | 0.6 | 50,000 | 12.8 | 1.0% |
| | ៨. កុងត្រូលចល័ត | ប៉ូលីសសេដ្ឋកិច្ច | 1.5 | 0.4 | 30,000 | 7.7 | 0.6% |
| | ៩. កុងត្រូលចល័ត | ការិយាល័យរុក្ខាប្រមាញ់ខេត្ត | 1 | 0.3 | 20,000 | 5.1 | 0.4% |
| | ១០. តាំងក្រសាំង<br>១១. ស្រុកកំពង់ថ្ម | ការិយាល័យរុក្ខាប្រមាញ់ (មិនច្បាស់)<br>នាយកដ្ឋានរុក្ខាប្រមាញ់ | 1.5 | 0.4 | 30,000 | 7.7 | 0.6% |
| | | ការិយាល័យរុក្ខាប្រមាញ់ចល័ត | | | | | |
| | | រុក្ខាប្រមាញ់សង្កាត់ | | | | | |
| | | ប៉ូលីសសេដ្ឋកិច្ច (ពីក្រសួង) | | | | | |
| | | ប៉ូលីសសេដ្ឋកិច្ចខេត្ត | 15 | 3.8 | 300,000 | 76.5 | 5.7% |
| កំពង់ចាម | ១២. ស្រុកជើងព្រៃ | ការិយាល័យរុក្ខាប្រមាញ់ខេត្ត | 1.5 | 0.4 | 30,000 | 7.7 | 0.6% |
| | | នាយកដ្ឋានរុក្ខាប្រមាញ់ | 3 | 0.8 | 60,000 | 15.3 | 1.1% |
| | | កងរាជអាវុធហត្ថខេត្ត | 1.5 | 0.4 | 30,000 | 7.7 | 0.6% |
| | ១៣. ស្រុកព្រៃឈរ | នាយកដ្ឋានរុក្ខាប្រមាញ់ | 5 | 1.3 | 100,000 | 25.5 | 1.9% |
| | ១៤. ព្រំដែន | ការិយាល័យគយ និងរដ្ឋាករ | | | | | |
| | | នាយកដ្ឋានរុក្ខាប្រមាញ់ | | | | | |
| | | ក្រសួងបរិស្ថាន | | | | | |
| | | មន្ត្រីស្រុក | | | | | |
| | | ប៉ូលីស | 22.8 | 5.8 | 27,336 | 116.2 | 8.7% |
| សរុប | ១៤ កន្លែង | ការបង់ ៤៣ដង | **263** | **67** | **4,810,000** | **1344** | **100%** |

តារាង ៦.៣. ការបង់ប្រាក់កំរៃលើការដឹកជ័រទឹក ១,២តោន (ពីកែវសីមា-ខេត្តមណ្ឌលគិរី ទៅ មេមត់-ខេត្តកំពង់ចាម)

| តំបន់ | កន្លែងបង់ | ស្ថាប័នប្រមូលកំរៃ | អត្រាជាក់ស្តែង | | | | ភាគរយ កំរៃសរុប |
|---|---|---|---|---|---|---|---|
| | | | ៛/គ.ក | $/តោន | ៛/ដឹកជញ្ជូន | $/ដឹកជញ្ជូន | |
| មណ្ឌលគិរី | ស្រុកកែវសីមា | មន្ត្រីស្រុក | 51 | 13.0 | 61,044 | 15.6 | 52.5% |
| | | មន្ត្រីស្រុក | 8 | 2.1 | 9,996 | 2.6 | 8.6% |
| | | ការិ. រុក្ខាប្រមាញ់ខេត្ត | 8 | 2.1 | 10,000 | 2.6 | 8.6% |
| | | ប៉ូលីស | 3 | 0.9 | 4,000 | 1.0 | 3.4% |
| កំពង់ចាម | ស្រុកមេមត់ | ការិ. បរិស្ថាន | 0 | 0.0 | | | |
| | | ការិ. កងរាជអាវុហត្ថស្រុក | 3 | 0.9 | 4,000 | 1.0 | 3.4% |
| | ព្រំដែន | ការិ. គយ | | | | | |
| | | ក្រសួងបរិស្ថាន | | | | | |
| | | នាយកដ្ឋានរុក្ខាប្រមាញ់ | | | | | |
| | | មន្ត្រីស្រុក | | | | | |
| | | ប៉ូលីស | 22.8 | 5.8 | 27,336 | 7.0 | 23.5% |
| សរុប | ៣កន្លែង | **ការបង់ ១១ដង** | **97.0** | **24.7** | **116,376** | **29.7** | **100%** |

តួនាទីប្រាក់កំរៃក្នុងពាណិជ្ជកម្មជ័រទឹកពីមណ្ឌលគីរីទៅព្រំដែនវៀតណាម មានលក្ខណៈខុសគ្នាច្រើន ។ កំរៃយកលើការដឹកជញ្ជូនជ័រទឹក ១,២តោន មានប្រហែល ៣០ដុល្លារ (ឬ ២៥ដុល្លារ/តោន) ។ លើផ្លូវពាណិជ្ជកម្មនេះមានការបង់ប្រាក់ ១១ដង នៅ ៣កន្លែង ។ បើធៀបនឹងពាណិជ្ជកម្មពីព្រះវិហារ នៅផ្លូវនេះមន្ត្រីរុក្ខាប្រមាញ់មានតួនាទីតិចជាងក្នុងការប្រមូលប្រាក់កំរៃ ។ នៅមណ្ឌលគីរី គឺប៉ូលីសធ្វើការជំនួសមន្ត្រីស្រុកដែលទាមទារកំរៃច្រើនជាងគេ គឺប្រហែល ២ភាគ៣នៃប្រាក់កំរៃសរុប ។ ការបង់តិចៗជាងនេះមួយចំនួនទៀតទៅឱ្យមន្ត្រីខាង រុក្ខាប្រមាញ់ បរិស្ថាន យោធា និង គយ ។

## ៦.៥. ផលប៉ះពាល់ទៅលើប្រសិទ្ធភាពពាណិជ្ជកម្ម

បន្ថែមលើប្រាក់កំរៃបានបង់ជាក់ស្តែង ផលប៉ះពាល់ នៃការបង់ប្រាក់កំរៃធ្វើឱ្យខាតបង់ដល់សេដ្ឋកិច្ច ដោយសារមានអប្រសិទ្ធភាពក្នុងពាណិជ្ជកម្ម ។ ពាណិជ្ជករជ័រទឹកតែងខិតខំខ្លាំងណាស់ដើម្បីជៀសវាងការបង់ប្រាក់កំរៃខ្ពស់ ពីព្រោះជារឿយៗវាធ្វើឱ្យជំនួញរបស់គេត្រូវខាតតែម្តង ។ ឧទាហរណ៍ ជាជាងដឹកជញ្ជូនជ័រទឹកយ៉ាងមានប្រសិទ្ធភាពតាមរថយន្តធំៗ (ហើយបង់ប្រាក់កំរៃខ្ពស់) តាមធម្មតាគេច្រើនដឹកជ័រចេញពីកំពង់ធំ និង ឧត្តរមានជ័យ ក្នុងបរិមាណតិចជាង (២០០គ.ក) ដោយដាក់ក្នុងឃ្លុបរថយន្តឡានតាក់ស៊ី ។ ការដឹកតាមរថយន្តតាក់ស៊ីច្រើនលើក ធ្វើឱ្យចំណាយដឹកជញ្ជូនកើនឡើង ប៉ុន្តែនៅថោកជាងការដឹកតាមរថយន្តធំដែលត្រូវបង់ប្រាក់កំរៃ ។

ដូចគ្នាដែរ ពាណិជ្ជករនៅមណ្ឌលគីរី ចៀសវាងច្រកព្រំដែនឡាបាកេ ដែលនៅជិតនោះ ដោយសារប្រាក់កំរៃមានកំរិតខ្ពស់ពេក ហើយសុខចិត្តជ្រើសយកផ្លូវឆ្ងាយ ដោយដឹកជ័រទឹកនាំចេញតាមស្រុកមេមត់ ខេត្តកំពង់ចាមវិញ ។ ចំងាយផ្លូវបន្ថែមនេះបានបង្កើនចំណាយដឹកជញ្ជូន និងប្រេងឥន្ទនៈ ប្រហែល ១២ដុល្លារ/តោន ទៀត ដែលស្មើនឹងប្រហែល ២០% នៃបន្ទុកចំណាយលើការរកទីផ្សារសរុប (ក្រៅពីប្រាក់កំរៃ) ។ អ្នកលក់ដុំ និងអ្នកដឹកជញ្ជូននៅមណ្ឌលគីរី បានរាយការណ៍ទៀតថា អត្រាប្រាក់កំរៃក្នុងមួយតោនបង់ទៅលើការដឹកជ័រទឹកចំនួនតិចតួច (១-២តោន) វាថោកជាងប្រហែល ពាក់កណ្តាលនៃអត្រាបង់សំរាប់ការដឹកជ័រទឹកក្នុងបរិមាណច្រើន (១០តោន) ។ រឿងនេះ បានបន្ទុចបង្អាក់ដល់ការដឹកជញ្ជូនជ័រទឹកច្រើនៗតាមរថយន្តធំដែលមានប្រសិទ្ធិភាពខ្ពស់ជាង ។

## ៦.៦. ផលប៉ះពាល់ចំពោះការគោរពតាមបទប្បញ្ញត្តិផ្លូវការនាពេលអនាគត

ដូចបានកត់សំគាល់ពីខាងលើ ប្រាក់កំរៃទាំងអស់ដែលបង់លើពាណិជ្ជកម្មជ័រទឹក ឬមួយជាប្រាក់បង់ក្រៅផ្លូវការ ឬមួយបង់តាមមូលដ្ឋានផ្លូវការ ប៉ុន្តែមិនគោរពទៅតាមអត្រាបង់ផ្លូវការដែលបានកំណត់ទេ ។ ដើម្បីដោះស្រាយការមិនអនុវត្តន៍តាមច្បាប់នេះ គេអាចលើកជាអនុសាសន៍ឡើងថា ត្រូវពង្រឹងការដាក់អនុវត្តន៍ការបង់ប្រាក់កំរៃផ្លូវការ និងលុបចោលការបង់ប្រាក់ក្រៅផ្លូវការនានា ។ ប៉ុន្តែ ក្រៅពីពាណិជ្ជកម្មជ័រទឹកពីខេត្តព្រះវិហារ (ដែលប្រាក់កំរៃសរុបខ្ពស់ដល់ ៨៦%នៃអត្រាផ្លូវការ) មួយចេញ, ការដាក់បង្ខំឱ្យបង់តាមអត្រាប្រាក់ កំរៃផ្លូវការ នឹងធ្វើឱ្យពាណិជ្ជករភាគច្រើនគ្មានផលចំណេញ (តារាង៦.៤)។ ឧទាហរណ៍ គេអាចរកចំណេញបាន ៤០ដុល្លារ/តោន លើពាណិជ្ជកម្មជ័រទឹកចេញពីខេត្តកំពង់ធំ ក្រោយបានបង់ប្រាក់កំរៃក្រៅផ្លូវការ ២១ដុល្លារ/តោនរួចហើយ ។ ប៉ុន្តែបើសិនមានការដាក់បង្ខំឱ្យបង់ប្រាក់កំរៃតាមអត្រាផ្លូវការ ៨០ដុល្លារ/តោន (និងលុបបំបាត់ការបង់ក្រៅផ្លូវការទាំងអស់ចោល) នោះជំនួញនេះនឹងក្លាយជាខាតប្រាក់ ២០ដុល្លារ/តោនវិញ ។ ដូច្នេះ មុននឹងមានការប្រឹងប្រែងកែលំអការបង់តាមអត្រាប្រាក់កំរៃផ្លូវការ ត្រូវធ្វើកំណែទំរង់ប្រព័ន្ធប្រាក់កំរៃនេះសិន ដើម្បីឱ្យការអនុវត្តន៍ប្រព័ន្ធនេះមិនដួលរលំដល់ពាណិជ្ជកម្មជ័រទឹកទេ ។

តារាង ៦.៤. ការបង់ប្រាក់កំរៃជាក់ស្តែង ធៀបនឹងការប្រាក់បង់កំរៃផ្លូវការ (បើសិនពង្រឹងការអនុវត្តន៍)

| | **ផ្លូវពាណិជ្ជកម្មទី១:** មណ្ឌលគីរី-កំពង់ចាម-វៀតណាម | **ផ្លូវពាណិជ្ជកម្មទី២:** ព្រះវិហារ-កំពង់ចាម-វៀតណាម | **ផ្លូវពាណិជ្ជកម្មទី៣:** កំពង់ធំ-ភ្នំពេញ | **ផ្លូវពាណិជ្ជកម្មទី៤:** ឧត្តរមានជ័យ-សៀមរាប |
|---|---|---|---|---|
| | ដុល្លារ/តោន | ដុល្លារ/តោន | ដុល្លារ/តោន | ដុល្លារ/តោន |
| កំរៃជាក់ស្តែង | 31 | 67 | 21 | 28 |
| កំរៃផ្លូវការ[១] | 80 | 80 | 80 | 80 |
| កំរៃជាក់ស្តែងគិតជា % នៃកំរៃផ្លូវការ | 38% | 84% | 26% | 35% |
| ផលចំណេញចរន្ត | 43 | 55 | 40 | 48 |
| ផលចំនេញ បើអនុវត្តតាមអត្រាផ្លូវការ (និងលុបចោលកំរៃក្រៅផ្លូវការ) | **-7** | **42** | **-20** | **-5** |

[១] ផ្អែកតាមអត្រាផ្លូវការលើជ័រទឹក ៣១៥ដុល្លារ/គ.ក ដែលគណនាចេញជាដុល្លារ/តោន ។

# ជំពូកទី ៧

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ថ្មីៗនេះ រដ្ឋាភិបាលបានទទួលស្គាល់បញ្ហាមួយចំនួនដែលទាក់ទិននឹងលិខិតអនុញ្ញាត និងប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ សំរាប់អនុផលព្រៃឈើ និងបានបញ្ជាក់ពីបំណងសើរើពិនិត្យប្រព័ន្ធនេះឡើងវិញ ព្រមទាំងកែលំអលក្ខខណ្ឌទីផ្សារ ។ ដូចមានចែងក្នុងឯកសារ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ របស់រដ្ឋាភិបាល :

ច្បាប់ព្រៃឈើនឹងត្រូវសើរើពិនិត្យឡើងវិញ នៅពេលប្រមូលពត៌មានបានពី ប្រសិទ្ធិភាព និងការអនុវត្តន៍ច្បាប់ ។ ប្រព័ន្ធប្រាក់កំរៃ និងលិខិតអនុញ្ញាតលើអនុផលព្រៃឈើ នឹងត្រូវពិនិត្យឡើងវិញដែរ ដោយពិគ្រោះយោបល់ជាមួយក្រុមអ្នកប្រើប្រាស់នៅមូលដ្ឋាន ។ លើសពីនេះទៀត គួរមានការប្រឹងប្រែងបំបាត់របាំងចំពោះការលក់ដូរអនុផលព្រៃឈើ (ជាពិសេសជ័រទឹក) ពីព្រោះគេអាចប្រមូលវាបានដោយមិនប៉ះពាល់អាក្រក់ដល់ព្រៃឈើ ហើយវាសំខាន់ខ្លាំងណាស់ចំពោះសេដ្ឋកិច្ចគ្រួសារនៅជនបទ ។

ក្នុងការសើរើពិនិត្យច្បាប់ស្តីពីព្រៃឈើ និងបទប្បញ្ញត្តិជាប់ទាក់ទិន រដ្ឋាភិបាលមានឱកាសដើម្បីពិចារណាថា តើត្រូវកែប្រែក្របខ័ណ្ឌបច្ចុប្បន្នយ៉ាងណាឱ្យបានប្រសើរបំផុត ដើម្បីឱ្យវាមានតួនាទីកាន់តែខ្លាំង ជួយគាំទ្រដល់គោលដៅខាងគោលនយោបាយសំខាន់ៗរបស់រដ្ឋាភិបាល ។ គោលដៅទាំងនេះរួមមាន ការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការបង្កើនពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ ការអភិវឌ្ឍន៍ជនបទ និងការកែលំអការគ្រប់គ្រងព្រៃឈើ ។ ផលប៉ះពាល់នៃការសិក្សានេះចំពោះការឈានទៅសំរេចគោលដៅនានាដូចខាងលើ គឺមានពិភាក្សាវែកញែកដូចតទៅ ។

## ៧.១. ផលប៉ះពាល់ចំពោះគោលដៅសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ

ដូចបានសិក្សាក្នុងផ្នែក១.២ ការសិក្សានេះផ្តោតលើជ័រទឹកធ្វើពាណិជ្ជកម្មចេញពីតំបន់ព្រៃជាច្រើន ដែលគេដឹងថាមានឱនភាពស្រូវអង្ករជាប្រចាំ និងមានភាពក្រីក្រខ្ពស់ និងដែលការសិក្សាថ្មីៗរបស់អង្គការស្បៀងអាហារពិភពលោក (២០០១) បានកំណត់ថាជា "ឃុំគួរព្រួយបារម្ភ" ។ គ្រួសារជាច្រើននៅតំបន់ទាំងនេះ ពឹងផ្អែកលើការប្រមូលជ័រទឹក និងផលិតផលព្រៃឈើផ្សេងទៀតដើម្បីចិញ្ចឹមជីវិត ។ ដោយសារដំណាំស្រូវមិនអាចធានាសន្តិសុខស្បៀងបានគ្រប់គ្រាន់, ចំណូលបានពីការលក់ជ័រទឹក និងផលិតផលព្រៃឈើផ្សេងទៀត ត្រូវបានប្រើប្រាស់ដើម្បីទិញអង្ករក្នុងរយៈពេលមានឱនភាព ។ ជាក់ស្តែង វបសអ បានសង្កេតឃើញអ្នកដងជ័រជាច្រើននាក់ បានដងជ័រទឹកទៅដូរយកអង្ករដោយផ្ទាល់ពីអ្នកលក់ដុំជ័រទឹក ។

ប្រាក់កំរៃដាក់អនុវត្តលើទីផ្សារជ័រទឹកចាប់ពីភូមិអ្នកដងជ័រ ទៅទីផ្សារចុងក្រោយ បានកាត់បន្ថយប្រាក់ចំណេញជាសក្តានុពលពី ៣៥-៥៥% ទៅតាមផ្លូវពាណិជ្ជកម្មខុសៗគ្នា ។ នៅពេលអ្នកធ្វើម៉ាយ៍ទិញជ័រទឹកមិនអាចស្រូបយកប្រាក់កំរៃទាំងនេះបាន គេផ្ទេរបន្ទុកចំណាយនេះទៅលើអ្នកដងជ័រតាមវិធីបន្ទាបថ្លៃជ័រទឹក ។ តាមវិធីនេះ ប្រាក់កំរៃលើការរកទីផ្សារជ័រទឹក អាចមានផលប៉ះពាល់យ៉ាងច្រើនទៅលើប្រាក់ចំណូល និងសន្តិសុខស្បៀងនៃគ្រួសារដងជ័រទឹក ។ ឧទាហរណ៍ ការសិក្សាលើ ៤ភូមិនៅ

ខេត្តមណ្ឌលគិរី ដោយអង្គការសមាគមអភិរក្សសត្វព្រៃ (២០០៣) បានប៉ាន់ស្មានថា គ្រួសារដងជ័ររកចំណូលបានជាមធ្យម ៣៨០ដុល្លារ/ឆ្នាំពីការលក់ដូរជ័រទឹក ។ គ្រួសារទាំងនេះមានដាំស្រូវផងដែរ ប៉ុន្តែបានគ្រប់គ្រាន់សំរាប់ហូបប្រហែលតែ ៤ខែ ប៉ុណ្ណោះក្នុងមួយឆ្នាំៗ ហើយត្រូវពឹងផ្អែកលើចំណូលបានពីជ័រទឹកដើម្បីទិញអង្ករហូបបន្ថែម ។ សំរាប់បរិមាណជ័រទឹកដែលគ្រួសារនិមួយៗដងបានជាមធ្យមនៅខេត្តមណ្ឌលគិរី ប្រាក់កំរៃដើម្បីនាំចេញជ័រទឹកនេះមានសរុបប្រហែល ៨២ដុល្លារ/ឆ្នាំ ។ ទឹកប្រាក់សរុបនេះ អាចទិញអង្ករថែមបានដល់ទៅ ៤០០គ.ក/ឆ្នាំ ដែលគ្រប់គ្រាន់សំរាប់ឱ្យគ្រួសារមួយមានសមាជិក ៥នាក់ អាចទិញអង្ករហូបបាន ៥-៦ខែ ។ ទោះបី គេមិនរំពឹងថា ឈ្មួញជ័រទឹកនឹងផ្ទេរផលចំណេញទាំងអស់ទៅឱ្យអ្នកដងជ័រក៏ដោយ បើសិនប្រាក់កំរៃត្រូវបានលុបបំបាត់ចោល ប៉ុន្តែ ការប្រកួតប្រជែងក្នុងដណ្តើមទិញជ័រទឹកដ៏សកម្ម បានធ្វើឱ្យមួយភាគធំនៃផលចំណេញនេះនឹងបានធ្លាក់ទៅដល់ដៃអ្នកដងជ័រ ។ តាមមតិអ្នករកទីផ្សារជ័រទឹក ការប្រកួតប្រជែងទិញជ័រទឹកកាន់តែខ្លាំងនេះ បានផុសចេញមួយចំណែកពីការថយចុះការផ្គត់ផ្គង់ជ័រទឹក ដែលជាផលវិបាកនៃការកាប់ដើមឈើផ្តល់ជ័រទឹកខុសច្បាប់នៅតាមតំបន់ជាច្រើន ។

ក្នុងរបៀបរបបអនុវត្តសព្វថ្ងៃ មានការយកប្រាក់កំរៃលើពាណិជ្ជកម្មជ័រទឹកដែលបានកាត់បន្ថយចំណូលរបស់សហគមន៏ព្រៃឈើ ហើយនៅពេលសហគមន៏ទាំងនេះជួបប្រទះនឹងឱនភាពស្រូវអង្ករ ក៏មានកិច្ចប្រឹងប្រែងដឹកជំនួយម្ហូបអាហារទៅផ្តល់ឱ្យពួកគេ ។ ដោយសហគមន៏ជាច្រើនស្ថិតក្នុងតំបន់ដាច់ស្រយាល ការចែកចាយជំនួយបែបនេះអាចពិបាកធ្វើ និងមានតំលៃថ្លៃ ។ ដូចនេះ ពិតហើយយុទ្ធសាស្ត្រកាន់តែមានប្រសិទ្ធភាពដើម្បីធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៏/ផ្តល់សិទ្ធិអំណាចដល់ជនបទ គឺត្រូវលុបបំបាត់ប្រាក់កំរៃលើពាណិជ្ជកម្មជ័រទឹក ។ ការអនុវត្តន៏បែបនេះធ្វើឱ្យសហគមន៏ព្រៃឈើទទួលបានចំណូលបន្ថែម មានមធ្យោបាយច្រើនទៀត សំរាប់ដោះស្រាយទិញអង្ករហូបក្នុងរយៈពេលមានឱនភាព និងកាត់បន្ថយការពឹងផ្អែកលើជំនួយ ។

## ៧.២. ផលប៉ះពាល់ចំពោះគោលដៅពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ

តាមប្រវត្តិសាស្ត្រ ជ័រទឹកប្រមូលបាននៅតាមតំបន់ព្រៃនានានៅកម្ពុជា តែងត្រូវបានលក់ដូរសំរាប់បំរើការប្រើប្រាស់ក្នុងស្រុកនៅតាមតំបន់នេសាទ និងសំរាប់បំរើការនាំចេញ ។ សហគមន៏ព្រៃឈើត្រូវការប្រើប្រាស់ជ័រទឹកតិចតួចណាស់ ក្រៅពីតំរូវការម្តងម្កាលដើម្បីបិទទូកផ្ទាល់ខ្លួន ឬធ្វើចន្លុះ ។ ដូច្នេះនៅតាមសហគមន៏ព្រៃឈើ ការផ្គត់ផ្គង់ជ័រទឹកតែងតែច្រើនជាងតំរូវការប្រើប្រាស់វា ។ ដើម្បីឱ្យអ្នកដងជ័រទទួលបានចំណូលបានពីជ័រទឹកផលិតលើសនេះ គឺចាំបាច់ត្រូវតែមានការធ្វើពាណិជ្ជកម្ម ។

បច្ចុប្បន្នរដ្ឋាភិបាលកំពុងលើកកំពស់យុទ្ធសាស្ត្រ "ពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ" តាមទិសដៅរបស់ក្រសួងពាណិជ្ជកម្ម ។ យុទ្ធសាស្ត្រនេះព្យាយាមពាំនាំផលប្រយោជន៏នៃឱកាសល្អខាងការនាំចេញ និងពាណិជ្ជកម្ម ទៅឱ្យអ្នកក្រតាមរយៈ ក) ការលើកទឹកចិត្តដល់ការវិនិយោគទុន និងសហគ្រិនភាព ក្នុងវិស័យផ្សេងៗដែលមានមូលដ្ឋាននៅជនបទ, ខ) ការធ្វើវិមជ្ឈការមូលដ្ឋាននាំចេញបច្ចុប្បន្ន (ភាគច្រើននៅ ភ្នំពេញ សៀមរាប និង ក្រុងព្រះសីហនុ) ឆ្ពោះទៅកាន់តំបន់ថ្មីៗផ្សេងទៀត, គ) ការបង្កើនតំលៃបន្ថែមនៃការនាំចេញ តាមរយៈ ការកែលំអផលិតភាព និងការបង្កើនសមត្ថភាពកែច្នៃ, ឃ) ការបង្កើតយុទ្ធសាស្ត្រទីផ្សារ សំរាប់ទីផ្សារក្នុងស្រុក និងក្រៅប្រទេស ។ លក្ខណៈវិនិច្ឆ័យសំរាប់ផ្តោតលើពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ រួមមានការជ្រើសរើសពាណិជ្ជកម្មដែលជំរុញការបង្កើតការងារមានប្រើកំលាំងពលកម្មច្រើន, ការបង្កើនកំណើនប្រាក់ចំណូលក្នុងតំបន់នានា ដែលផ្តោតយកចិត្តទុកដាក់បំផុតទៅប្រជាជនកម្ពុជាដែលក្រីក្រ និងការបង្កើនតំលៃបន្ថែមឱ្យកាន់តែច្រើនចំពោះទំនិញនាំចេញ (រាជរដ្ឋាភិបាលកម្ពុជា ២០០១) ។

ការរកទីផ្សារជ័រទឹកគួរក្លាយជាមុខសញ្ញាសំរាប់ការកែលំអ ពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ ។ ជ័រទឹកជាផលិតផលក្នុងស្រុកមួយដែលបានលក់ដូរសំរាប់នាំចេញក្នុងបរិមាណដ៏ច្រើនក្នុងពេលបច្ចុប្បន្ន, មានលទ្ធភាពធ្វើការកែច្នៃបង្កើតតំលៃបន្ថែម, និង អាចរកបានទីផ្សារសំរាប់នាំចេញដែលផ្តល់តំលៃខ្ពស់ ។ សំខាន់ជាងនេះទៀត ផលិតកម្មជ័រទឹកបានជួយទ្រទ្រង់ដល់ប្រជាជន

ជនបទប្រហែល ១០០.០០០នាក់នៅតាមតំបន់ដាច់ស្រយាលនានាដែលអាចមានចោទបញ្ហានៃឱនភាពស្បៀងជាប្រចាំ និងភាពក្រីក្រ ។ ការកែលំអពាណិជ្ជកម្មជ័រទឹក អាចជាគំនិតផ្តួចផ្តើម "អំណោយផលដល់អ្នកក្រ" មួយយ៉ាងពិតប្រាកដ ដោយសារវាអាចជួយទ្រទ្រង់ដល់កំណើនចំណូលនៅក្នុងតំបន់ទាំងនេះ ព្រមទាំងធ្វើពិពិធកម្មការមូលដ្ឋាននាំចេញរបស់កម្ពុជា ។

បទប្បញ្ញត្តិគ្រប់គ្រងពាណិជ្ជកម្មនិងការនាំចេញជ័រទឹកបច្ចុប្បន្ន មិនស៊ីគ្នានឹងកិច្ចប្រឹងប្រែងជំរុញពាណិជ្ជកម្មអំណោយផលដល់អ្នកក្រទេ ។ បទប្បញ្ញត្តិទាំងនេះបានបង្អាក់ដំណើរការធ្វើពាណិជ្ជកម្មជាជាងជួយជំរុញវា ។ ចំពោះបុគ្គលភាគច្រើនដែលជាប់ទាក់ទងក្នុងពាណិជ្ជកម្មជ័រទឹក ការប្រតិបត្តិតាមប្រព័ន្ធបច្ចុប្បន្នមិនអាចធ្វើបានទេ ពីព្រោះខ្វះមធ្យោបាយបង់ប្រាក់កំរៃផ្លូវការខ្ពស់ ឬធ្វើដំណើរទៅភ្នំពេញតាមការចាំបាច់ដើម្បីដាក់ពាក្យសុំលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ (សូមអានផ្នែក ៥.១) ។ ជាលទ្ធផលប្រព័ន្ធបច្ចុប្បន្នមានតួនាទីសំខាន់ដើម្បីធ្វើជាមូលដ្ឋានគ្រឹះសំរាប់ការបង់ប្រាក់កំរៃក្រៅផ្លូវការ ជាជាងការប្រមូលចំណូលផ្លូវការរបស់រដ្ឋាភិបាល ។ រឿងនេះវាមិនមែនតំណាងឱ្យអភិបាលកិច្ចល្អ ឬក៏ជួយទ្រទ្រង់ដល់ពាណិជ្ជកម្មអំណោយផលដល់អ្នកក្រទេ ។

ការកែលំអពាណិជ្ជកម្មជ័រទឹកដើម្បីជួយដល់អ្នកក្រ ត្រូវពឹងផ្អែកលើកំណែទំរង់ក្នុង ៣ផ្នែកយ៉ាងតិច។ ទី១ លិខិតអនុញ្ញាតដឹកជញ្ជូនដែល ការិយាល័យរុក្ខាប្រមាញ់ខេត្ត និង DFW បានតំរូវឡើង ជារឿយៗគេប្រើវាជាមូលដ្ឋានសំរាប់ការប្រមូលប្រាក់កំរៃក្រៅផ្លូវការ។ លិខិតអនុញ្ញាតនេះគ្មានប្រសិទ្ធភាពក្នុងលក្ខណៈជាឧបករណ៍សំរាប់ប្រមូលចំនូលផ្លូវការ ឬប្រមូលទិន្នន័យ ហើយក៏គ្មានចាំបាច់អ្វីដែរសំរាប់គោលដៅនៃការគ្រប់គ្រងព្រៃឈើ ពីព្រោះការដងជ័រមិនប៉ះពាល់អវិជ្ជមានដល់ព្រៃឈើទេ ។ តាមពិតអ្នកដងជ័រអាចខិតខំធ្វើអ្វីៗបានច្រើនណាស់ដើម្បីការពារតំបន់មានដើមឈើផ្តល់ជ័រទឹក ។ ទី២ ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណគឺពិតជាមិនដំណើរការទេ ដូចដែលការពិតជាក់ស្តែងបានបង្ហាញថា គ្មាននរណាម្នាក់ទៅសុំអាជ្ញាប័ណ្ណនាំចេញជ័រទឹកពី DFW សោះតាំងពីឆ្នាំ២០០០មក។ ទោះបីអាជ្ញាប័ណ្ណនាំចេញត្រូវបានលុបចោល ឬក៏រក្សាទុកក្នុងរូបភាពបែបណាក្តី ប៉ុន្តែពន្ធនាំចេញ ១% (ឬ "កំរៃសេវាកម្ម") គួរតែលុបចោល ពីព្រោះវាផ្ទុយពីគោលដៅជំរុញការនាំចេញ ។ ទី៣ ត្រូវខិតខំប្រឹងប្រែងច្រើនថែមទៀតដើម្បីលុបបំបាត់ការប្រមូលប្រាក់កំរៃដែលគ្មានការអនុញ្ញាត/ខុសច្បាប់ ដោយយោធា ប៉ូលីស និងអាជ្ញាធរផ្សេងទៀត តាមរយៈការថ្លែងពីគោលនយោបាយដ៏ច្បាស់លាស់មួយពីរឿងនេះ និងការត្រួតពិនិត្យយ៉ាងទៀងទាត់តាមផ្លូវផ្តល់ ។

## ៧.៣. ផលប៉ះពាល់ចំពោះគោលដៅគ្រប់គ្រងព្រៃឈើ

ដូចបានពិភាក្សាក្នុងផ្នែក២.១ ការដងជ័រមិនប៉ះពាល់ដល់ដើមឈើផ្តល់ជ័រទឹក ឬតំបន់ព្រៃឈើនៅជុំវិញនោះទេ ។ យើងមានហេតុផលល្អគ្រប់គ្រាន់ក្នុងការបង្កើតបទប្បញ្ញត្តិ ដើម្បីប្រមូលផលឈើ និងអនុផលព្រៃឈើនានានៅទីកន្លែងណាដែលមានការអនុវត្តពុំមានចីរភាព ហើយដែលអាចធ្វើឱ្យបាត់បង់ព្រៃឈើ ការបាត់បង់ពូជឈើ ឬបញ្ហាបរិស្ថានផ្សេងៗ ប៉ុន្តែ មិនគួរយកបទប្បញ្ញត្តិទាំងនេះធ្វើជាមូលដ្ឋានអះអាងដើម្បីដាក់បទប្បញ្ញត្តិទៅលើការដងជ័រ និងការធ្វើពាណិជ្ជកម្មជ័រទឹកឡើយ ។ តាមពិតបទប្បញ្ញត្តិនានាដែលធ្វើឱ្យថ្លៃជ័រទឹកថយចុះ វាអាចកាត់បន្ថយកិច្ចការពារព្រៃឈើ ដោយសារអ្នកដងជ័រមិនសូវមានការលើកទឹកចិត្តឱ្យយកជ័រ (និងការពារ) ពីដើមឈើរបស់ខ្លួន ។

កំណែទំរង់បទប្បញ្ញត្តិដែលគ្រប់គ្រងការប្រមូលផល និងការធ្វើពាណិជ្ជកម្មអនុផលព្រៃឈើ ដូចជាជ័រទឹកជាដើម វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយឱ្យកិច្ចប្រឹងប្រែងធ្វើពិពិធកម្មការការគ្រប់គ្រងព្រៃឈើតាមរយៈ "សហគមន៍ព្រៃឈើ" បានទទួលជោគជ័យ។ ជារួម សហគមន៍ព្រៃឈើមានគោលដៅផ្តល់សិទ្ធិអំណាចដល់ភូមិ និងឃុំ នៅតាមតំបន់ព្រៃឈើ ឱ្យបន្តការប្រើប្រាស់ធនធានព្រៃឈើតាមទំលាប់, ជំរុញឱ្យមានការអនុវត្តន៍ប្រកបដោយចីរភាព, និងធានាឱ្យពួកគេមានសំលេងខ្លាំងក្នុងការធ្វើសេចក្តីសំរេចអំពីការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន ។ គិតមកដល់ខែមីនា ឆ្នាំ២០០២ គេប៉ាន់ស្មានថា នៅកម្ពុជាមាន ២៣៧សហគមន៍ព្រៃឈើ ដែលភាគច្រើនទើបបានបង្កើតថ្មីៗ ដូច្នេះកំពុងស្ថិតក្នុងដំណើរការរៀបចំ កំនត់គោលដៅគ្រប់គ្រង និងកសាងផែនការគ្រប់គ្រងនានា (McKenney and Prom 2002) ។

បច្ចុប្បន្ន សហគមន៍ព្រៃឈើសឹងតែទាំងអស់នៅកម្ពុជា បានទទួលការជួយឧបត្ថម្ភក្នុងកំរិតណាមួយពីអង្គការមិនមែនរដ្ឋាភិបាល (NGO) ជាតិ និងអន្តរជាតិ ។ ខណៈដែលការជួយឧបត្ថម្ភនេះមានតួនាទីសំខាន់ក្នុងការបង្កើតសហគមន៍ព្រៃឈើ ប៉ុន្តែការជួយឧបត្ថម្ភបែបនេះមិនអាចមាននិរន្តរភាពទេ ។ គេរំពឹងថា សហគមន៍ព្រៃឈើ នឹងត្រូវដំណើរការបានដោយឯករាជ្យនៅពេលអនាគត ។ ដើម្បីធ្វើបែបនេះបាន ពួកគេត្រូវមានអ្វីៗច្រើនលើសពី ផែនការគ្រប់គ្រងព្រៃឈើ វិធាននានា និងក្រមសីលធម៌ល្អនោះទៀត ។ សមាជិកនានាត្រូវមើលឃើញពីអត្ថប្រយោជន៍ចំពោះការរស់នៅ និងប្រាក់ចំណូលរបស់ខ្លួន ហើយត្រូវមានការស្វែងរកចំណូលដើម្បីទ្រទ្រង់ដល់សកម្មភាពគ្រប់គ្រង ។ តាមក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ន ប្រាក់កំរៃប្រមូលយកលើពាណិជ្ជកម្មអនុផលព្រៃឈើ បានកាត់បន្ថយចំណូលប្រជាជនមូលដ្ឋាន ហើយប្រាក់នេះមានប្រើតិចណាស់ ប្រសិនបើមានគួរប្រើចំណូលទាំងនោះ ដើម្បីបំរើគោលដៅគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន ។

ដើម្បីឱ្យសហគមន៍ព្រៃឈើអាចដំណើរបានក្នុងរយៈពេលវែង សិទ្ធិអំណាចក្នុងការប្រមូលយកពន្ធ និងប្រាក់កំរៃលើអនុផលព្រៃឈើ ចាំបាច់ត្រូវផ្ទេរចេញពីមន្ត្រីថ្នាក់ខេត្តនិងថ្នាក់ជាតិ ទៅឱ្យមន្ត្រីជាប់ឆ្នោតនៅមូលដ្ឋានវិញ (ក្រុមប្រឹក្សាឃុំ និង/ឬ សមាជិកគណៈកម្មាធិការសហគមន៍ព្រៃឈើ) ។ ក្នុងលក្ខណៈជាអ្នករស់នៅ និងធ្វើការក្នុងឃុំ មន្ត្រីទាំងនេះអាចធ្វើការជាមួយប្រជាជនក្នុងឃុំ ដើម្បីកំណត់ពីកំរិតប្រាក់កំរៃដែលត្រូវប្រមូលដោយសមរម្យ និងយុត្តិធម៌ សំរាប់អនុផលព្រៃឈើផ្សេងៗ ក្នុងគោលគំនិតយល់ឃើញថា ចំណូលនេះនឹងយកទៅវិនិយោគឡើងវិញ នៅក្នុងសកម្មភាពគ្រប់គ្រងព្រៃឈើនៅមូលដ្ឋានរបស់ខ្លួន ។ លើសពីនេះទៀត ក្នុងលក្ខណៈជាមន្ត្រីជាប់ឆ្នោត ពួកគេត្រូវធ្វើឱ្យមានតំលាភាពលើចំណូលរកបាន និងកំរិតជឿនលឿននៃការកែលំអការគ្រប់គ្រងព្រៃឈើ ។

## ៧.៤. អនុសាសន៍

ផ្អែកតាមគំហើញនៃការសិក្សានេះ និងស្របតាមគោលដៅរបស់ជាតិដើម្បី កាត់បន្ថយភាពក្រីក្រ ធានាសន្តិសុខស្បៀង បង្កើនពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ និងកែលំអការគ្រប់គ្រងព្រៃឈើ, អនុសាសន៍ខាងគោលនយោបាយមួយចំនួនត្រូវបានបំផុសឡើងដូចតទៅ:

១) **កែលំអអភិបាលកិច្ច និងតម្លាភាពសំរាប់ការរកទីផ្សារជ័រទឹក រួមទាំងការសើរើពិនិត្យឡើងវិញទាំងស្រុង និងការធ្វើឱ្យសាមញ្ញនូវប្រព័ន្ធបទប្បញ្ញត្តិបច្ចុប្បន្ន:** ការតំរូវឱ្យមានលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗដ៏ច្រើនលើការប្រមូលផល ស្តុក ដឹកជញ្ជូន និងនាំចេញជ័រទឹក និងអនុផលព្រៃឈើផ្សេងៗ គួបផ្សំនឹងការប្រមូលយកប្រាក់កំរៃនិងសួយសារ, បានបង្កើតបរិយាកាសមិនទីងអនុផលព្រៃឈើមួយរារាំងដល់ពាណិជ្ជកម្មអំនោយផលដល់អ្នកក្រ និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ជនបទជាទូទៅ ។ ដូចមានចែងក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ ២០០៣-២០០៥ របស់រដ្ឋាភិបាល, របាំងបទប្បញ្ញត្តិទាំងនេះ ចាំបាច់ត្រូវតែលុបចោល ។ វិធានការជាគន្លឹះនានារួមមាន:

ក. ការលុបបំបាត់លិខិតអនុញ្ញាតដឹកជញ្ជូន និងប្រាក់កំរៃនានាដែលជាប់ទាក់ទិន: លិខិតអនុញ្ញាតដឹកជញ្ជូនជ័រទឹកត្រូវបានប្រើជាមូលដ្ឋានសំរាប់ប្រមូលយកប្រាក់កំរៃក្រៅផ្លូវការ ជាជាងប្រមូលចំណូលចូលរដ្ឋជាផ្លូវការ ។ លិខិតអនុញ្ញាតគ្មានប្រសិទ្ធភាពទេ ប្រសិនបើប្រើវាក្នុងគោលដៅសំរាប់ការគ្រប់គ្រងព្រៃឈើ និងការប្រមូលទិន្នន័យ ប៉ុន្តែបន្ទុកចំណាយ និងការតំរូវផ្សេងៗរបស់វា បានរារាំងដល់គោលនយោបាយនានាដែលមានបំណងបង្កើនការលូតលាស់ពាណិជ្ជកម្ម និងសេដ្ឋកិច្ច ។

ខ. ការលុបបំបាត់ការប្រមូលប្រាក់កំរៃនៅតាម កុងត្រូល/ស្ថាប័ននានា ដែលគ្មានមូលដ្ឋានស្របច្បាប់ដើម្បីប្រមូលប្រាក់កំរៃ: ការសិក្សានេះបានរកឃើញកន្លែងកុងត្រូលមួយចំនួនកំពុងធ្វើប្រតិបត្តិការនៅតាមផ្លូវពាណិជ្ជកម្មជ័រទឹក ។ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃកន្លែងកុងត្រូលទៅលើពាណិជ្ជកម្មជ័រទឹក (និងពាណិជ្ជកម្មឯទៀត) ត្រូវធ្វើការត្រួតពិនិត្យផ្លូវឱ្យបានទៀងទាត់ ដើម្បីរកឱ្យឃើញនិងលុបចោល កន្លែងកុងត្រូលគ្មានការអនុញ្ញាតនិងធានាថា កន្លែងកុងត្រូលដែលមានការអនុញ្ញាត បានធ្វើប្រតិបត្តិការស្របតាមអាណត្តិស្របច្បាប់របស់ខ្លួន ។

គ. លុបចោលពន្ធនាំចេញ និងធ្វើឱ្យសាមញ្ញនូវនីតិវិធីនានាសំរាប់សុំអាជ្ញាប័ណ្ណនាំចេញ: បច្ចុប្បន្ននេះ គ្មានរណាម្នាក់ដាក់ពាក្យសុំអាជ្ញាប័ណ្ណនាំចេញជ័រទឹកទេ ដោយសារតែចំណាយ និងបន្ទុកផ្សេងៗទាក់ទិននឹង ប្រាក់កំរៃលើពាក្យសុំ ការធ្វើដំនើរមកភ្នំពេញ និងការរត់ការស្នេគ្រស្នាញដើម្បីសុំការយល់ព្រម ។ ការលុបចោលពន្ធនាំចេញ និងការធ្វើឱ្យសាមញ្ញនូវនីតិវិធីសុំអាជ្ញាប័ណ្ណ វាដើរស្របតាមកិច្ចប្រឹងប្រែងដ៏ទូលំទូលាយរបស់រដ្ឋាភិបាល ដើម្បីជំរុញការនាំចេញ។ ការធ្វើឱ្យសាមញ្ញនូវនីតិវិធីនានា គួរមានគោលដៅធ្វើឱ្យការទទួលបានអាជ្ញាប័ណ្ណ ចំនាយអស់តិចឬគ្មានអស់ចំណាយសោះ តាមរយៈសេវាកម្ម "មួយកន្លែង" ដោយមិនចាំបាច់ធ្វើដំណើរមកភ្នំពេញ ។

២) កែលំអ និងផ្ទេរការគ្រប់គ្រងព្រៃឈើទៅឱ្យមូលដ្ឋាន តាមរយៈការធ្វើវិមជ្ឈការសិទ្ធិអំណាចត្រួតត្រាលើយន្តការរកប្រាក់ចំណូល: ដូចបានកត់សំគាល់ក្នុងផ្នែក៧.៣ សហគមន៍ព្រៃឈើសឹងតែទាំងអស់ នៅកម្ពុជាបច្ចុប្បន្នបានទទួលការជួយទ្រទ្រង់ក្នុងកំរិតណាមួយពី NGO ជាតិ និងអន្តរជាតិ។ ប៉ុន្តែការជួយឧបត្ថម្ភបែបនេះមិនអាចផ្តល់បានក្នុងរយៈពេលវែងទេ ហើយសហគមន៍ព្រៃឈើ ត្រូវតែអាចរកចំណូលបានដោយផ្ទាល់ដើម្បីផ្តល់ថវិកាទ្រទ្រង់ដល់សកម្មភាពគ្រប់គ្រងព្រៃឈើ ។ រឿងនេះតំរូវឱ្យមានការផ្ទេរសិទ្ធិអំណាចក្នុងការប្រមូលយកពន្ធ និងប្រាក់កំរៃលើអនុផលព្រៃឈើ ចេញពីមន្ត្រីថ្នាក់ខេត្តនិងថ្នាក់ជាតិ ទៅឱ្យមន្ត្រីជាប់ឆ្នោតនៅមូលដ្ឋានវិញ (ក្រុមប្រឹក្សាឃុំ និង/ឬសមាជិកគណៈកម្មាធិការការសហគមន៍ព្រៃឈើ) ។ មន្ត្រីទាំងនេះអាចធ្វើការជាមួយប្រជាជនក្នុងឃុំ ដើម្បីកំណត់ពីកំរិតប្រាក់កំរៃដែលសមរម្យ និងយុត្តិធម៌សំរាប់ប្រភេទអនុផលព្រៃឈើផ្សេងៗ ។ ម្យ៉ាងទៀត មន្ត្រីទាំងនេះ ធ្វើឱ្យមានតំលាភាពនៅក្នុងប្រាក់ចំណូលដែលរកបាន និងកំរិតជឿនលឿននៃការកែលំអការគ្រប់គ្រងព្រៃឈើ ។

៣) ដាក់ពង្រឹងការអនុវត្តន៍មាត្រា២៩ នៃច្បាប់ស្តីពីព្រៃឈើ ដែលហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹក: កិច្ចប្រឹងប្រែងកែលំអការរកទីផ្សារជ័រទឹក នឹងគ្មានន័យអ្វីទេ បើសិនការផ្គត់ផ្គង់ជ័រទឹកបានបាត់បង់ទៅដោយសារការកាប់ដើមឈើផ្តល់ជ័រទឹក ។ ដើមឈើផ្តល់ជ័រទឹក ហាក់ដូចមានសមាមាត្រធំគួរឱ្យកត់សំគាល់ ក្នុងចំណោមពូជឈើផ្សេងៗ ដែលក្រុមហ៊ុនសម្បទាន និងអង្គភាពពាណិជ្ជកម្មផ្សេងទៀតបានកាប់យក ។ បើសិនការកាប់ឈើនេះនៅធ្វើបន្តជំលោះលើដើមឈើផ្តល់ជ័រទឹកអាចកើនឡើង ហើយប្រជាជននៅជនបទកម្ពុជារាប់ពាន់នាក់ដែលពឹងផ្អែកលើការប្រមូលយកជ័រទឹក អាចបាត់បង់ប្រភពចំណូលមួយដ៏សំខាន់ ។ រដ្ឋាភិបាលគួរទទួលបានការលើកសរសើរ ចំពោះការហាមឃាត់ការកាប់ដើមឈើផ្តល់ជ័រទឹកនៅក្នុង ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ប៉ុន្តែបញ្ហាប្រឈមនៅខាងមុខទៀតគឺការពង្រឹងការអនុវត្តន៍ច្បាប់ ។

៤) កំណត់ថា ជ័រទឹក/អនុផលព្រៃឈើ គឺជាវិស័យស្នូលមួយសំរាប់គំនិតផ្តួចផ្តើមធ្វើពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ និងការកែលំអលទ្ធភាពកែច្នៃដើម្បីបង្កើតតំលៃបន្ថែម: ភាគច្រើននៃជ័រទឹកប្រមូលបាននៅកម្ពុជា ត្រូវបាននាំចេញដោយមានការកែច្នៃ/ច្រោះសំអាតតិចតួចណាស់, ភាគច្រើនឆ្ពោះទៅវៀតណាម (ដែលអាចនាំវាចេញបន្តទៀត) ។ បច្ចុប្បន្ននេះ ហាក់ដូចមានឱកាសល្អច្រើនខ្លាំងណាស់សំរាប់ធ្វើវិនិយោគក្នុងការកែច្នៃបង្កើតតំលៃបន្ថែម

និងការស្វែងរកទីផ្សារចុងក្រោយបានតំលៃខ្ពស់ ដែលកម្ពុជាអាចនាំចេញទៅទីនោះដោយផ្ទាល់បាន ។ ឧទាហរណ៍ ជ័រទឹកអាចកែច្នៃបន្ថែមនៅក្នុងស្រុក សំរាប់នាំចេញទៅលក់ឱ្យអ្នកផលិតថ្នាំលាប និងវ៉ែរនី ឬក៏អ្នកផលិតជាតិប្រេងពិសេស និងទឹកអប់ទៀតផង ។ វារឹតតែប្រសើរថែមទៀត បើសិនការកែច្នៃនេះអាចជួយទ្រទ្រង់ដល់ផលិតកម្មវ៉ែរនី និងថ្នាំលាបនៅក្នុងស្រុក ។ ជំហានដ៏ចាំបាច់ដើម្បីសំរេចគោលដៅទាំងនេះ គឺការបង្កើតបរិយាកាសអាជីវកម្ម និងពាណិជ្ជកម្មមួយ ដែលអំណោយផលល្អសំរាប់ជ័រទឹក ស្របតាមអនុសាសន៍ទី១ ខាងលើ ។ ការសើរើកែតំរូវក្របខ័ណ្ឌបទប្បញ្ញត្តិបច្ចុប្បន្ន អាចជួយកាត់បន្ថយបន្ទុកចំណាយលើការរកទីផ្សារ និងញ៉ាំងឱ្យផលិតកម្មនិងពាណិជ្ជកម្មជ័រទឹក កាន់តែមានដំណើរការស្របតាមបែបបទជាផ្លូវការ និងកាន់តែមានតម្លាភាព ដែលជួយលើកទឹកចិត្តដល់ការវិនិយោគទុន និងសហគ្រិនភាព ។

៥) ពិនិត្យ និងសើរើឡើងវិញ នូវក្របខ័ណ្ឌបទប្បញ្ញត្តិច្បាប់សំរាប់គ្រប់គ្រងអនុផលព្រៃឈើៈ ដូចមានចែងក្នុង យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ ២០០៣-២០០៥ របស់រដ្ឋាភិបាល, ប្រព័ន្ធប្រាក់កំរៃ និងលិខិតអនុញ្ញាតសំរាប់អនុផលព្រៃឈើជាទូទៅ ត្រូវសើរើពិនិត្យឡើងវិញ ហើយរបាំងនានាចំពោះការរកទីផ្សារត្រូវតែលុបចោល ។ ការសិក្សានេះបានផ្តោតលើពាណិជ្ជកម្មជ័រទឹកតែមួយមុខ ប៉ុន្តែបរិយាកាសរកទីផ្សារសំរាប់អនុផលព្រៃឈើផ្សេងៗទៀតក៏ទំនងជាស្រដៀងគ្នាដែរ ពីព្រោះមានការតំរូវនានាដូចគ្នានៅក្នុងបទប្បញ្ញត្តិ និងច្បាប់ ។ ដូច្នេះត្រូវធ្វើកំណែទំរង់លើតំរូវនានាទាំងអស់នេះ ទើបកម្ពុជាអាចបានសំរេចបាននូវគោលដៅនានានៅក្នុងការគ្រប់គ្រងព្រៃឈើ, អភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ ។

# ឯកសារយោង


Ankarfjard, R. (2000), “Ï mpacts from Tapping Oleoresin from *Dipterocarpus Alatus* on Trees and Timber Value in LAO P.D.R.”, submitted to the *Journal of Economic Botany*, May 2000

Ankarfjard, R. and M. Kegl (1998), “Tapping Oleoresin from *Dipterocarpus Alatus* in a Lao Village”, *Journal of Economic Botany*: 52(1) 7-14

BBC News (2002) “Battling Cambodia’s Illegal Timber Trade” as reported by D. Loyn, 16 May 2002

The Cambodia Daily (2003), “Borders Unclear at Kompong Thom Rubber Plantation”, as reported by P. Barron, Vol. 27, Issue 27, 2 September 2003

Cambodia Development Research Institute (2003), *The Economic Government and Strategies to Enhance Rural Livelihoods – Keynote Lecture by Samdech Hun Sen Prime Minister of the Royal Government of Cambodia*, 12 May 2003 (Phnom Penh: Cambodia Development Research Institute)

Chan, S., and S. Acharya (2003), *Facing the Challenge of Rural Livelihoods: A Perspective from Nine Villages in Cambodia*, Working Paper 25 (Phnom Penh: Cambodia Development Resource Institute)

Chea, S.A., and ARD Inc. (1998), *The Study of Effects of Forests on Rural Livelihoods in Kampong Thom Province, Cambodia*, (Phnom Penh: Department of Forestry and Wildlife)

Cock, A., P. Swift, P. Nhim, K. Uch, L. Aok, and P. Neang, (forthcoming), *(Draft) Forest Resources and Livelihoods: A case study on the production and trade of resin in context of Cambodia’s forest concession system*, (Phnom Penh: NGO Forum)

Department of Forestry and Wildlife (2003), *Cambodia: Forestry Statistics to 2002*, (Phnom Penh: Statistics Section, Planning and Accounting Office, Department of Forestry and Wildlife)

The Economist (2003), “Law of the Jungle – Just chopping it down”, 7 August 2003

Enfield, N., B. Ramangkoun, and V. Vongkhamsao (1998), *Case Study on Constraints in Marketing of Non-Timer Forest Products in Champasak Province, Lao PDR*, (Vientiane: Department of Forestry and IUCN)

Evans, T.D., P. Hourt, P. Phet, and M. Hang (2003), *A Study of Resin-Tapping and Livelihoods in Southern Mondulkiri, Cambodia, with Implications for Conservation and Forest Management* (Phnom Penh: Wildlife Conservation Society)

Foppers, J. and S. Ketphanh (1997), *The Use of Non-Timber Forest Products in Lao P.D.R*, (Lao PDR: Paper Presented at the Workshop on Protected Area Management, Xishuangbanna, 3-8 November 1997)

Gianno, R. (1986), “The Exploitation of Resinous Products in a Lowland Malayan Forest”, *Wallaceana*, Vol. 43, 1986

Gianno, R., and K.M. Kochumment (1981), “Note on Some Minor Forest Products”, *Malaysian Forester* 44: 566-568

Global Witness (2003), *Preliminary Assessment of Strategic Forest Management Plans and*

*Environmental Impact Assessment Reports – Cambodia's Forest Management Options for the Future*, (Phnom Penh: Global Witness)

Global Witness (2002), *Deforestation without limits: How the Cambodian government failed to tackle the untouchables*, (Phnom Penh: Global Witness)

Hang, S. (1995), *Non-Wood Forest Products in Cambodia*, (Phnom Penh: Planning Office, Department of Forestry and Wildlife)

Jantan, I., A.S, Ahmad, and A.R. Ahmad (1990), "Tapping of Oleo-Resin from *Dipterocarpus Kerrii"*, *Journal of Tropical Forest Science* 3(4): 348-355

Juiprik, S. and N. Kijtewachakul (2001), "Local Practices of Harvesting *Dipterocarpus* Resin and *Aranga Pinnata* Fruit in Satun, Thailand", in *Cultivating Forests: Alternative Forest Management Practices and Techniques for Community Forestry*, Proceedings of an International Seminar, RECOFTC, Report No. 17, (Bangkok: RECOFTC)

KPMG International Forestry and Environmental Advisory Services Group (2001), *(Draft) The Equitability of the Forest Taxation System in Cambodia*, (Phnom Penh: prepared for Cambodia Timber Industry Association)

McAndrew, J.P., S. Mam, K. Hong, and B. Ly (2003), *Indigenous Adaptation to a Decline in Natural Resources: The Experience of Two Phnong Communes in Northeast Cambodia*, (Phnom Penh: CIDSE)

McKenney, B. and T. Prom (2002), *Natural Resources and Rural Livelihoods in Cambodia: A Baseline Assessment,* Working Paper 23*,* (Phnom Penh: Cambodia Development Resource Institute)

Ministry of Agriculture, Forestry and Fisheries (2003), *Prakas on the Organisation and Functioning of Forest Administration,* No. 509 PK/MAFF/B, 17 September 2003, (Phnom Penh: Ministry of Agriculture, Forestry and Fisheries)

Ministry of Agriculture, Forestry and Fisheries (2003*), Food Balance Sheet – Paddy*, (Phnom Penh: Statistics Office, Department of Planning, Statistics and International Cooperation, Ministry of Agriculture, Forestry and Fisheries and Agricultural Productivity Improvement Project)

Ministry of Agriculture, Forestry and Fisheries (2000), *Circular on the Formal Fee Rate Determination for Non-Timber Forest Products,* No. 430 Kar-Sar-Kar, July 2000, (Phnom Penh: Ministry of Agriculture, Forestry and Fisheries)

Mlup Baitong (2003), *Report on Natural Resource Utilisation and Food Security in Chambok Commune, Kompong Speu Province, Cambodia*, (Phnom Penh: Mlup Baitong)

National Institute of Statistics (2000), *Report on the Cambodia Socio-Economic Survey 1999*, (Phnom Penh: Ministry of Planning)

National Institute of Statistics (2000), *General Population Census of Cambodia 1998* (Phnom Penh: Ministry of Planning)

NGO Forum, Medicam, and Cooperation Committee for Cambodia (2002), *NGO Statement to the 2002 Consultative Group Meeting on Cambodia*, (Phnom Penh: NGO Forum)

Nicholson, K. (1997), *(Draft) Marketing Feasibility Study for NTFP Exported from Lao PDR to Thailand*, NTFP Project, Marketing and Small Enterprise Development, April 1997

People's Republic of Kampuchea (1988), *Forest Practice Rules*, Kret no. 35, 25 June 1988

Phat, K.N., S. Ouk, Y. Uozumi, and T. Ueki (1999), *Stand Dynamics of Dipterocarp Trees in Cambodia's Evergreen Forest and Management Implications - A Case Study in Sandan District, Kompong Thom*, (Phnom Penh)

Ratanakiri Provincial Rural Development Department *et al*. (2000), *Cultural Resource Study: Impacts of the Hero Taiwan Company Concession on Sites of Religious and Cultural Significance in O Chum District, Ratanakiri,* (Rattanakiri)

Royal Government of Cambodia (2002), *National Poverty Reduction Strategy, 2003-2005* (Phnom Penh: Council for Social Development)

Royal Government of Cambodia (2002), *Forestry Law*, Reach Kret No. Nor-Sar/Ro-Kor-Mor/0802/016, August 2002, (Phnom Penh)

Royal Government of Cambodia (2001), *Formulation of a Pro-Poor Trade Sector Strategy for Cambodia: The Tokyo Road Map*, (Phnom Penh: Ministry of Commerce)

Seilava, R., P. Heng, and L. Emerton (2002), *Bokor, Kirirom, Kep and Ream National Parks, Cambodia: Case Studies of Economic and Development Linkages,* (IUCN- The World Conservation Union)

So, S.M., M. Cheam, B. Son, T. Em, and D. V. Samrang (2001), *Economic Valuation of Livelihoods Activities in Pourapet Village of Mondulkiri Province*, (Phnom Penh: WWF Conservation Program in Cambodia)

Sy, R., K. Hou, C. Chay, and S. Meas (2002), *Forest Use and Product Flow in Chumkiri District, Kampot Province, Cambodia*, (Singapore: EEPSEA)

World Food Programme, (2001), *Forestry and Food Security: A First Attempt at Nation-Wide Analysis*, Vulnerability Analysis and Mapping (Phnom Penh: World Food Programme)

Yim, C. and B. McKenney (2003), *Fish Export from the Great Lake to Thailand - An Analysis of Trade Constraints, Governance and the Climate for Growth*, Working Paper 27 (Phnom Penh: Cambodia Development Research Institute)

Yoshida, K., S. Chea, S. Khun, P. Lay, P. Sok, and K. Ouk (2001), *Forest Resource Utilization and Tree Planting Activities around Phnom Tamao Area, Bati District, Takeo Province, Cambodia*, (Phnom Penh: Department of Forestry and Wildlife and Japan International Cooperation Agency)

# ឧបសម្ព័ន្ធ ក: ផែនទីពាណិជ្ជកម្មជើងទឹកដែលបានសិក្សា

## ផ្លូវពាណិជ្ជកម្មទី ១. មណ្ឌលគិរី ~ មេមត់



## ផ្លូវពាណិជ្ជកម្មទី ២. ព្រះវិហារ ~ កំពង់ចាម ~ វៀតណាម



## ផ្លូវពាណិជ្ជកម្មទី ៣. កំពង់ធំ ‐ ភ្នំពេញ




## ផ្លូវពាណិជ្ជកម្មទី ៤. ឧត្តរមានជ័យ ‐ សៀមរាប



# ឧបសម្ព័ន្ធ ខ: មាត្រា ២៥ និង ២៦
# នៃច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២

**មាត្រា ២៥**

